សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciecnces Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# គោលការណ៍អនុវត្តចំពោះមន្ត្រីរាជការ នៅព្រះរាជាណាចក្រកម្ពុជាក្នុងការ គ្រប់គ្រងសេវាសាធារណៈ

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៩


រៀបរៀងដោយ

និស្សិតឈ្មោះ **ឃឹម សាម៉េង**

**ក.សរ សុជាតា**

សាស្ត្រាចារ្យណែនាំ

លោក **ឡើក ពិដោរ**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១២

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ឃឹម សារ៉េម** និង នាងខ្ញុំ **សរ សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈឆ្នាំទី ៤ ជំនាន់ទី ១២ ក្រុម $P_4C_3$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសូមសម្តែងនូវភាពកតញ្ញូតាធម៌ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

- លោកឪពុក អ្នកម្តាយ ដែលជាអ្នកមានគុណ មិនអាចកាត់ថ្លៃបាន ដោយបានផ្តល់កំណើត ដល់រូបយើងខ្ញុំ ព្រមទាំងចិញ្ចឹម បីបាច់ ថែរក្សា ដោយក្តីស្រលាញ់ ប្រកបដោយព្រហ្មវិហារធម៌ អប់រំ ទូន្មាន ប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្នែកស្មារតី និងថវិការហូតដល់យើងខ្ញុំ មានឱកាសបានបន្តការសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រនេះ ក្លាយជាធនធានមនុស្ស ដែលសង្គមជាតិមិនអាចខ្វះបាន ។
- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំបានចូលសិក្សាថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យនេះ និងបង្កភាពងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំកន្លងមក។
- លោកគ្រូ **ឡើក ពិដោរ** សាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតពេលដ៏មានតម្លៃ និងមមាញឹករបស់លោកគ្រូ ពីការបង្រៀន ដើម្បីដឹកនាំយើងខ្ញុំសរសេរសារណាបញ្ចប់ឆ្នាំសិក្សា ដោយមិនខ្លាចនឿយហាត់ ក្នុងការផ្តល់ជាគំនិត យោបល់ល្អ ពេលខ្លះលោកគ្រូបានផ្តល់នូវមតិ ឬ យុទ្ធសាស្ត្រសំខាន់ៗ តាំងពីដើមរហូតរហូតដល់សារណានេះបញ្ចប់ដោយជោគជ័យ។
- សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានផ្តល់នូវលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំនាពេលកន្លងមក។

នាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីមង្គល ក្តីសុខ ដល់លោកអ្នកដែលមានគុណ ទ្រង់ឯកឧត្តម និងលោកសាស្ត្រាចារ្យ សូមជួបនូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ជាបឋមខ្ញុំបាទ **ឃឹម សាម៉េង** និងនាងខ្ញុំ **សរ សុជាតា** មានសេចក្ដីរីករាយ សូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេសសាស្ត្រាចារ្យជាទីគោរព និងសិស្ស និស្សិតជាស្រលាញ់ និងរាប់អាន។ ក្រោយពីសិក្សារយៈពេល ៤ ឆ្នាំ យើងខ្ញុំបានទទួលចំនេះដឹងជាច្រើន និងជាកាលានុវត្តភាពដ៏វិសេសវិសាល ក្នុងការសរសេរ សារណាបញ្ចប់ឆ្នាំសិក្សា ថ្នាក់បរិញ្ញាបត្រ។

យើងខ្ញុំបានបានរៀបចំនូវសារណាបញ្ចប់ឆ្នាំសិក្សា ថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទ **គោលការណ៍អនុវត្តចំពោះមន្ត្រីរាជការនៅព្រះរាជាណាចក្រកម្ពុជាក្នុងការគ្រប់គ្រងសេវាសាធារណៈ**។ ដោយសារតែក្នុងវិស័យសាធារណៈជាវិស័យស្នូលដែលរដ្ឋត្រូវយកចិត្តទុកក្នុងការគ្រប់គ្រង ដើម្បីសម្រួលដល់ការរស់នៅរបស់រាស្ត្រប្រជា ជាងនេះរាល់ដំណើរការ និងការអភិវឌ្ឍរបស់រដ្ឋអាចដំណើរការ រីកចម្រើនទៅមុខបានលុះត្រាតែការផ្ដល់សេវាសារធារណៈរបស់រដ្ឋមានដំណើរការ ប្រកបដោយគណនេយ្យភាពខ្ពស់ក្នុងការបម្រើ ផ្ដល់ជូនអ្នកប្រើប្រាស់។ យ៉ាងណាមិញការដើម្បីឲ្យការអនុវត្តចំពោះមន្ត្រីក្នុងការគ្រប់គ្រងសេវាឲ្យមានប្រសិទ្ធភាពខ្ពស់ដូចជាទីចង់បាន ត្រូវឈរលើមូលដ្ឋាននៃគោលការណ៍នានាដែលមានស្រាប់នឹងគោលការណ៍ដែលមិនទាន់មាន។

យើងខ្ញុំជឿជាក់យ៉ាងមុតមាំថា សារណានឹងចូលរួមជម្រុញដល់ការអនុវត្តចំពោះមន្ត្រីរាជការក្នុងការគ្រប់គ្រង និងផ្ដល់សេវាជូនប្រទេសឲ្យសមស្របទៅតាមបទដ្ឋានច្បាប់ដែលមាន ជម្រុញការអភិវឌ្ឍរបស់ប្រទេស និងជាពិសេសជួយបន្លឿនដល់ការផ្ដល់សេវារបស់មន្ត្រីរាជការដែលពាក់ព័ន្ធ។ សារណានេះក៏សិក្សា និងសមស្របពីវត្ថុបំណងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍទៅលើវិស័យសេវាសាធារណៈនេះផងដែរ។ ជាងនេះទៅទៀតវាក៏ជាឯកសារស្រាវជ្រាវ ដ៏មានតម្លៃក្នុងវិស័យសេវាសាធារណៈដល់មជ្ឈដ្ឋានជនដទៃដែលមានគោលបំណងសិក្សាស្រាវជ្រាវបន្ត និងជាគន្លឹះនៃពុទ្ធិដល់សិស្ស និស្សិតក្នុងការសិក្សាបន្តដើម្បីជាចំណេះដឹងបន្ថែម។

ម្យ៉ាងវិញទៀត យើងខ្ញុំសូមអភ័យទោសផងដែរ ចំពោះកំហុសខុសឆ្គង និងភាពខ្វះចន្លោះនានាដែលកើតមាននៅក្នុងសារណានេះ ដោយអចេតនាក្នុងន័យកែលម្អទៅលើមន្ត្រី និងសេវាសាធារណៈឲ្យកាន់តែល្អ ។ ពួកខ្ញុំរីករាយ ស្វាគមន៍ និងទទួលរាល់ការរិះគន់ និងកែលម្អ នានាពីសំណាក់មិត្ត និងអ្នកអានទាំងឡាយ ។

នាចុងបញ្ចប់ យើងខ្ញុំសូមជូនពរដល់មិត្តិអ្នកអានគ្រប់រូប ឲ្យជួបតែសុភមង្គល ភាពរុងរឿង សុវត្ថិភាព និងភាពជោគជ័យជានិរន្តន៍។

## មាតិកា

## សេចក្តីផ្តើម


ក.លំនាំបញ្ហានៃការស្រាវជ្រាវ..............................................................................................................១

**១.ការប្រៀបធៀបរបបនៃការគ្រប់គ្រងមន្ត្រីរាជការក្នុងការផ្តល់សេវាសាធារណៈរបស់ប្រទេសកម្ពុជា និងបណ្តាប្រទេសដទៃ**..............................................................................................................២

**២.និយមន័យ**

- គោលការណ៍នៃការគ្រប់គ្រងសេវាសាធារណៈ..............................................................៤
- មន្ត្រីរាជការ ឬ មន្ត្រីរដ្ឋការ..............................................................................................៥
- សេវាសាធារណៈ..............................................................................................................៧

**៣.ពន្យល់ន័យរបស់ប្រធានបទ** ..............................................................................................៧

ខ.ចំណោទបញ្ហានៃការស្រាវជ្រាវ.........................................................................................៩

គ.ដែនកំណត់នៃការស្រាវជ្រាវ.............................................................................................៩

ឃ.គោលបំណង..................................................................................................................១០

ង. វិធីសាស្ត្រស្រាវជ្រាវ ..........................................................................................................១០

ច. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ..............................................................................................១១


## ជំពូក ១

## គោលការណ៍បែបប្រពៃណី


**១. គោលការណ៍និរន្តភាពនៃសេវាសារធារណៈ**.........................................................................១២

**២. គោលការណ៍សមភាពនៃសេវាសាធារណៈ**...........................................................................១៣

**៣. គោលការណ៍សម្របតម្រូវនៃសេវាសាធារណៈ**......................................................................១៦

**៤. គោលការណ៍មិនគិតថ្លៃនៃសេវាសាធារណៈ**..........................................................................១៩


## ជំពូក ២

## គោលការណ៍អនុគ្គពល


**ផ្នែកទី ១ គោលការណ៍តម្លាភាពនៃសេវាសាធារណៈ**

១.១.១ តម្លាភាព និងផលប្រយោជន៍សាធារណៈ.......................................................................២២

១.១.២ តម្លាភាពនៃសេវាសាធារណៈចំពោះសេដ្ឋកិច្ច......២៥
**ផ្នែកទី ២. គោលការណ៍គុណភាព នៃសេវាសាធារណៈ**
១.២.១ វិមជ្ឈការ និងវិសហមជ្ឈការ ( គុណប្រយោជន៍ និងគុណវិបត្តិ )......២៧
១.២.២ សនិទានកម្មមន្ត្រីរាជការ......៣១
១.២.៣ ប្រព័ន្ធមុខងាររបស់មន្ត្រីរាជការ......៣៤
១.២.៤ ប្រព័ន្ធគ្រប់គ្រងគុណផល......៣៧
១.២.៥ ការគ្រប់គ្រងតាមបែបសហគ្រាស ឬ បែបសេដ្ឋកិច្ច......៤០
**ផ្នែកទី ៣ គោលការណ៍ចូលរួមរបស់អ្នកប្រើប្រាស់សេវាសាធារណៈ**
១.៣.១ ការរិះគន់......៤៣
១.៣.២ ការចូលរួមពីអង្គការ និងសមាគម......៤៤
១.៣.៣ ការចូលរួមរបស់អ្នកប្រើប្រាស់សេវាសាធារណៈ ......៤៤
**ផ្នែកទី ៤ បញ្ហាប្រឈមក្នុងការគ្រប់គ្រងសេវាសាធារណៈ**
១. ការផ្តល់សេវាមានលក្ខណៈយឺតយ៉ាវ ......៤៧
២. អំណាចចៅហ្វាយ ( មេ )មានវិសាលភាពធំធេង......៤៧
៣. ការអនុវត្តរបស់មន្ត្រីមានលក្ខណៈបុរាណទាំងការគ្រប់គ្រងមន្ត្រី និងការផ្តល់សេវា......៤៧
៤. ទំនួលខុសត្រូវរបស់មន្ត្រីរាជការក្នុងតួនាទី និងការផ្តល់សេវានៅមិនទាន់ទទួលយកបាន..៤៨
៥. តម្លាភាពរបសមន្ត្រីរាជការ ចំពោះការគ្រប់គ្រងសេវាមានកម្រិតទាប......៤៨
**ផ្នែកទី ៥ ដំណោះស្រាយលើបញ្ហាប្រឈមនៃសេវាសាធារណៈ**......៤៩
**សេចក្តីសន្និដ្ឋាន**......៥២
**អនុសាសន៍**......៥៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ក. លំនាំបញ្ហា

ការគ្រប់គ្រងមន្ត្រីរាជការនៅព្រះរាជាណាកម្ពុជាត្រូវបានពឹងផ្អែកលើគោលការណ៍សកលផង ច្បាប់វិជ្ជមានផង និងផ្អែកតាមវិធាននៃច្បាប់សរសេរ។

យើងត្រូវញែកឲ្យដាច់រវាងការគ្រប់គ្រងតាមបែបបុរាណ មុនសម័យអាណានិគមបារាំង ឆ្នាំ ១៨៦៣ និងការគ្រប់គ្រងតាមបែបសម័យទំនើប។ តួយ៉ាងមុនសម័យអាណានិគមនិយមបារាំង ប្រទេសកម្ពុជាបានគ្រប់គ្រងប្រទេសតាមបែបរដ្ឋបាល សក្តិភូមិ ( ផ្តាច់ការ ) និងមានរបៀបទៅតាមទំនៀមទម្លាប់សាសនាព្រាហ្មណ៍ ឬ តាមគម្ពីរវេទ។ ដោយព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រងដោយមនុស្ស ៤ នាក់ ដែលរួមមាន៖ ព្រះមហាក្សត្រ ( ស្តេចផែនដី ) ឧបយុវរាជ( ស្តេចដាក់រាជ្យ ) ឧបរាជ ( ស្តេចរង ) និងមានព្រះហាក្សត្រយានី ( មាតាស្តេច ) ដែលនេះគេហៅថាប្រព័ន្ធ ចតុស្តំ។ ក្នុងការបម្រើមនុស្សទាំង ៤ នាក់ត្រូវមានមន្ត្រីរាជការ ៤ សម្រាប់ ៖ មួយសម្រាប់ សម្រាប់ព្រះមហាក្សត្រ សម្រាប់ទី១ ពោលគឺ ព្រះមហាក្សត្រមានមន្ត្រីរាជការចំនួន ៥ គឺ៖ ឧកញ៉ាមហាសេនា ឧកញ៉ាចៅវាំង ឧកញ្ញ៉ាចក្រី ឧកញ៉ាក្រឡាហោម និងយមរាជដោយមានជំនួយការពីរមន្ត្រីចំនួន ពីររូប៖ ឧកញ៉ាមហាមន្ត្រី និងឧកញ៉ា ទេព។ សម័យនោះគេចែកឋានន្តរស័ក្តិជា ១១ ហូព័ន្ធ ហើយត្រូវស្ថិក្រោមក្រមមួយហៅថា ក្រមស្រុក។

ដោយឡែកនៅសម័យអាណានិគមបារាំង បារាំងបានធ្វើការត្រួតត្រាប្រទេសកម្ពុជា និងបានធ្វើការកែទម្រង់នៃប្រព័ន្ធគ្រប់គ្រងនៅប្រទេសកម្ពុជា ឆ្នាំ១៩០៤ និងចាប់ពីឆ្នាំ ( ១៨៦៣-១៩៥៣ ) លុបបំបាត់ចោលប្រព័ន្ធនៃការគ្រប់គ្រងដែលមានលក្ខណៈ សក្តិភូមិ ឲ្យទៅជាការគ្រប់គ្រងមួយដែលមានការបែងចែកអំណាចគ្នាក្នុងការបំរើរដ្ឋការនាសម័យនោះ។ ក្នុងការបែងចែកអំណាចរបស់បារាំងនាសម័យ គឺបារាំងបានបែងចែកអំណាចតាមដែនសមត្ថកិច្ចនៃអាណាខេត្តនីមួយៗនៃប្រទេសកម្ពុជា ដូចនេះមន្ត្រីរដ្ឋការទាំងអស់ត្រូវ ប្រទេសបារាំងបានឲ្យនិយមន័យថា ជាការបង្កើតឲ្យមានប្រព័ន្ធសមត្ថកិច្ចតាមភារកិច្ច នាសម័យនោះ និងយកប្រព័ន្ធអាជីពមកអនុវត្តក្នុងការបម្រើរដ្ឋការ។ ក្នុងការរៀបចំរបៀបរបបនៃការគ្រប់គ្រងមន្ត្រីរាជការនៅប្រទេសកម្ពុជា បារាំងបានរៀបចំនៃការគ្រប់គ្រងតាមបែបបច្ចឹមប្រទេសក្នុងការបម្រើសេវាសាធារណៈ ហើយចាប់ពីឆ្នាំ ១៨៩៧ មកសូម្បីតែព្រះមហាក្សត្រក៏ត្រូវបារាំងរៀបចំឲ្យមានប្រាក់បៀវត្សរ៍ថ្វាយដែរ។ ជាងនេះទៅទៀតការរៀបចំ និងការគ្រប់គ្រងមន្រ្តីរាជការក្នុងការផ្តល់សេវានាសម័យនោះបារាំងបានអនុវត្ត នៅប្រព័ន្ធវិជ្ជាជីវៈគ្របខ័ណ្ឌ ក្នុងការគ្រប់គ្រងមន្ត្រីរាជការ ក៏ដូចជាការគ្រប់គ្រងមន្ត្រីនៅប្រទេសបារាំងដែរហើយការគ្រប់គ្រងបានទុកជាកេរ្តិ៍តំណែល បន្តជះឥទ្ធិពលក្នុងការគ្រប់គ្រងមន្ត្រីរាជការនាពេលបច្ចុប្បន្ន។

យើងអាចនិយាយបានថាការគ្រប់គ្រងរដ្ឋបាល នៅប្រទេសកម្ពុជានាសម័យនោះជាការគ្រប់គ្រងមួយដែលស្ថិតក្នុងសម័យទំនើប ណាមួយយើងអាចចាត់ទុកថាជាលើកដំបូងបង្អស់ និងជាការបើកទំព័រសករាជក្នុងការបង្កើតឲ្យមានលក្ខណៈគតិយុត្តសម្រាប់គ្រប់គ្រងមន្ត្រីរាជការខ្មែរ។ បារាំងបានបង្កើតលើកដំបូងនូវ " សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌរដ្ឋបាលសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា " ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ៣២៣ នស ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៤៧។ ហើយបារាំងបាននាំចូលមកនូវគម្រូនៃ "លក្ខន្តិកៈទូទៅ នៃមន្ត្រីរដ្ឋការថ្នាក់រដ្ឋ" ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៤៦ ដែលមានដំបូងបង្អស់នៅប្រទេសបារាំង។ ប្រទេសកម្ពុជាបាននិយមប្រកាន់ប្រព័ន្ធអាជីព ដែលជាប្រព័ន្ធសមត្ថភាពតាំងពីឆ្នាំ ១៩៤៧ ខែឧសភា មុននឹងមានរដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ ដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី ២១ ខែ ធ្នូ ទៅទៀត។ នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៥២ មានព្រះរាជក្រមមួយបន្ថែម និងកែលម្អព្រះរាជក្រឹត្យឆ្នាំ ១៩៤៧ គឺព្រះរាជក្រម ៧២៧ នស។ ប៉ុន្តែព្រះរាជក្រឹត្យទាំងពីរត្រូវបានលុបចោល និងជំនួសដោយព្រះរាជក្រមលេខ ៧៩៣ នស ចុះថ្ងៃទី ០៨ ខែ មិនា ឆ្នាំ ១៩៥៣ ស្តីពី " មន្ត្រីរាជការនៃរដ្ឋបាលសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា "។ ហើយការគ្រប់គ្រងនៃព្រះរាជាណាចក្រកម្ពុជាមានការវិវត្តតាមសម័យកាល។

## ១. ការប្រៀបធៀបរបបនៃការគ្រប់គ្រងមន្ត្រីរាជការក្នុងការផ្តល់សេវាសាធារណៈរបស់ប្រទេសកម្ពុជា និងបណ្តាប្រទេសដទៃ

តាមការសិក្សាស្រាវជ្រាវគោលការណ៍អនុវត្ត ក៏ដូចជាគ្រប់គ្រងរបស់ប្រទេសកម្ពុជាត្រូវបានទទួលឥទ្ធិពលពីបរទេសក្នុងដំណើរការផ្សេងៗ។ គួបផ្សំទៅនឹងដំណើរនៃការទទួលឥទ្ធិពលនេះជាការសង្កេតឲ្យឃើញបាននូវបណ្តាលប្រទេសបញ្ចឹមលោកមួយចំនួនមានការបង្កើតឲ្យមានប្រព័ន្ធ នៃការគ្រប់គ្រងរដ្ឋ ដែលប្រទេសទាំងនោះរួមមាន៖ ប្រទេសអង់គ្លេស ប្រទេសបារាំង ប្រទេសអាឡឺម៉ង់ និងប្រទេសអូសទ្រីសជាដើម។

ប្រព័ន្ធរដ្ឋបាលរបស់ប្រទេសអង់គ្លេសចាប់ពីឆ្នាំ ១៨៥៥ នៅប្រទេសអង់គ្លេស គេពុំទាន់មានការបែងចែកច្បាស់លាស់រវាងមុខងាររដ្ឋបាល និងមុខងារនយោបាយនៅឡើយទេ ។ ប៉ុន្តែចាប់ពី ឆ្នាំ ១៨៥៥ ប្រទេសអង់គ្លេសបានបង្កើតក្រសួងមុខងារសាធារណៈមួយ ឈ្មោះថា “ **Civil Service Commission** “ ( ប្រែតាមអក្សរថា ៖ “ គណៈកម្មការមន្ត្រីរាជការស៊ីវិល “ ) ដែលគេមិនចង់ឲ្យមានការរើសមន្ត្រី តាមលក្ខណៈនយោបាយ។ ការប្រកួតប្រជែងចំណេះវិជ្ជាជីវៈ ដើម្បីចូលធ្វើការងាររាជការ ជាគោលការណ៍មួយដែលប្រទេសអង់គ្លេសប្រកាន់យកយ៉ាងមុតមាំបំផុត តាំងពីឆ្នាំ ១៨៧០ មកម្ល៉េះ។ ប្រទេសអង់គ្លេសនិយមប្រព័ន្ធអាជីពមួយ ដែលតឹងរឹងជាងប្រទេសបារាំង និងប្រទេសអឺរ៉ុបដ៏ទៃទៀត។ ចាប់ពីឆ្នាំ ១៩៩៦ មន្ត្រីរាជការជាន់ខ្ពស់ចំនួន ៣០០០ នាក់ត្រូវបានស្ថិតក្រោមការ

គ្រប់គ្រងរបស់អង្គភាពមន្ត្រីរាជការជាន់ខ្ពស់ ( **Senior Civil Service** ) និងមិនត្រូវបានស្ថិតនៅក្រោមអំណាចនយោបាយទៀតឡើយ[1]។ បើក្រឡេកមកមើលប្រព័ន្ធគ្រប់គ្រប់របស់ប្រទេសអេស្ប៉ាញ ( **Espagne** ) វិញឃើញថាប្រទេសនេះនិយមយកប្រព័ន្ធរុះរើ ។ ប្រព័ន្ធនេះគេហៅថា " សេសង់ស៊ីយ៉ាស " ( **Cesantias** ) ដែលប្រព័ន្ធនេះត្រូវអនុវត្តន៍រហូតដល់ឆ្នាំ១៩១៨ ទើបគេបង្កើតឲ្យមានប្រព័ន្ធអាជីពរបៀបដូចជាប្រទេសបារាំង ។ ប៉ុន្តែនៅឆ្នាំ១៩៨៤ ប្រព័ន្ធអាជីពត្រូវបានរង្គោះរង្គើ ហើយត្រលប់ទៅរកប្រព័ន្ធចាស់វិញ[2]។ ចំពោះប្រព័ន្ធនៃការគ្រប់គ្រងនៅប្រទេសអូទ្រីស្រវិញក៏ត្រូវបានលើកយកមកសិក្សា និងធ្វើការប្រៀបធៀបផងដែលដោយចាប់តាំងតែពីឆ្នាំ ១៩៤៦ ដល់ឆ្នាំ ១៩៦៦ នៅប្រទេសអូទ្រីស គេមានប្រព័ន្ធនៃការគ្រប់គ្រងមួយឈ្មោះថា " ប្រ៉ប័រ្ស៍ " ( **"Proport)** សម្រាប់ធ្វើការបែងចែកកាន់កាប់មុខតំណែងរដ្ឋបាល និងនយោបាយទៅតាម " កូតា នយោបាយ "។ ចាប់ពីឆ្នាំពី ឆ្នាំ ២០០០ បន្ទាប់ពីមានការចូលរួមរវាងបក្សពីរក្នុងការគ្រប់គ្រងប្រទេស ដែលហៅថារដ្ឋាភិបាលចម្រុះមកធ្វើឲ្យមានការវិវត្តនៃការគ្រប់គ្រងព្រោះ គណបក្សមួយចង់ឲ្យមានការកាត់បន្ថយការរើសមន្ត្រីរាជការតាមលក្ខណៈវិនិច្ឆ័យនយោបាយ[3]។ ប្រព័ន្ធច្បាប់កម្មុយនីស្ត ជាប្រព័ន្ធមួយដែលយកមកអនុវត្តន៍ដល់បច្ចុប្បន្ន បើសម្លឹងមើលឲ្យឃើញច្បាស់គឺមានប្រទេសទាំងពីរ ដែលមានការគ្រប់គ្រងនៃប្រព័ន្ធនេះយ៉ាងខ្លាំងក្លាមានដូចជា៖ សហភាពសូវៀត (រុស្ស៊ី) និង ប្រទេសចិន ។ ប្រព័ន្ធនៃការគ្រប់គ្រងនេះ ប្រទេសទាំងនោះភាគច្រើននិយមប្រព័ន្ធចំណុះអំណាចនយោបាយទាំងស្រុង ដោយឈរលើគោលការណ៍ស្មោះត្រង់ ចំពោះបក្សជាធំ។ ប៉ុន្តែរយៈពេលក្រោយៗមកមានការកែតម្រូវខ្លះទៅលើប្រព័ន្ធនៃការគ្រប់គ្រង តួយ៉ាងដូចជាប្រទេសចិនដែលក្នុងសម័យដែលលោក តេង ស៊ីយ៉ាវ ពេញ គាត់ជាបិតានៃសេដ្ឋកិច្ចចិន បានធ្វើការកែប្រែរបៀបរបបនៃការគ្រប់គ្រងដែលគិតទៅលើបក្សពួក គ្រួសារនិយម មកជាការគ្រប់គ្រងដោយគិតពីសមត្ថភាព តាមមុខជំនាញនីមួយៗជាងនេះមានទ្រឹស្តីមួយលើកឡើងថា ៖ <<ទោះជាវាជា ស ឬ ខ្មៅ ក៏ដោយ ឆ្មាដែលល្អគឺជាឆ្មាដែលអាចចាប់កណ្តុរបាន>>[4]។

បើក្រឡេកមកប្រទេសបារាំង ដែលជាប្រទេសមួយដែលមានខឿនអរិយធម៌ដែលមានភាពវ័យចំណាស់ក្នុងការគ្រប់គ្រងដំណើរផ្សេងៗរបស់រដ្ឋ។ នៅក្នុងប្រទេសបារាំងបានបែងចែកអំណាចរដ្ឋបាលមូលដ្ឋានជា៣ មាន ( សង្កាត់ នាយកដ្ឋាន និងតំបន់ )។ ជាពិសេសប្រទេសបារាំបានបង្កើតឲ្យមានការគ្រប់គ្រងតាមបែបវិមជ្ឈការមុនគេក្នុងការគ្រប់គ្រងរដ្ឋ ដោយប្រទេសបារាំងបានធ្វើ

[1] សៀវភៅ " វិទ្យាសាស្ត្ររដ្ឋបាល " របស់លោក J.Chevallier ឆ្នាំ ២០០២ ទំព័រ ៣៥៥-៣៥៧
[2] សៀវភៅ " វិទ្យាសាស្ត្ររដ្ឋបាល " របស់លោក J.Chevallier ឆ្នាំ ២០០២ ទំព័រ ៣១២
[3] សៀវភៅ " វិទ្យាសាស្ត្ររដ្ឋបាល " របស់លោក J.Chevallier ឆ្នាំ ២០០២ ទំព័រ ៣៥៣
[4] ដូចទី៣

វិមជ្ឈការកម្មរដ្ឋរបស់ខ្លួនជាលើកដំបូង នៅ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ១៩៨២។ ក្នុងការធ្វើវិមជ្ឈការនេះ គេបានកំណត់យកវិធាន ៣[5] ក្នុងការអនុវត្តរួមមាន៖

- ការទទួលខុសត្រូវផ្នែករដ្ឋបាលរបស់អភិបាលត្រូវជំនួសដោយការត្រួតពិនិត្យផ្នែកច្បាប់
- អំណាចប្រតិបត្តិនាយកដ្ឋានត្រូវផ្ទេរពីអភិបាលទៅប្រធាននៃក្រុមប្រឹក្សាជាប់ឆ្នោត
- ការបង្កើតតំបន់ដែលមានអំណាចពេញលេញ និងទទួលស្គាល់ថាជាដែនដីរបស់សមាគម។

មិនតែប៉ុណ្ណោះប្រទេសបារាំងក៏បានធ្វើកំណែទម្រង់របស់ប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនជាបន្តបន្ទាប់ដូចជាមានការធ្វើកំណែទម្រង់ប្រព័ន្ធវិមជ្ឈការ នៅឆ្នាំ ២០០២ និង ២០០៤។ ជាពិសេសប្រទេសបារាំងបានទទួលយកប្រព័ន្ធនៃការគ្រប់តាមបែបទំនើប ដើម្បីដោះស្រាយនូវបញ្ហាឲ្យកាន់តែមានប្រសិទ្ធភាព និងដំណើរឲ្យកាន់តែរហ័សក្នុងការធ្វើសកលភាវូបនីយកម្ម[6]។

បន្ទាប់ពីបានសិក្សាទៅលើប្រព័ន្ធនៃការគ្រប់គ្រងនៃបណ្តាលប្រទេស អឺរ៉ុប និងប្រទេសនៅអាស៊ី ហើយប្រព័ន្ធនៃបណ្តាប្រទេសទាំងនោះសុទ្ធសឹងតែជាប្រព័ន្ធដែលប្រទេសកម្ពុជាធ្លាប់យកមកអនុវត្តក្នុងការគ្រប់គ្រងផ្សេងៗដូចជា របបចម្រុះដែលក្នុងកម្ពុជាធ្លាប់យកមកអនុវត្ត ប្រព័ន្ធនៃការគ្រប់គ្រងតាមបែបកម្មុយនីស្តដែលកម្ពុជាធ្លាប់ទទួលយកមកអនុវត្តន៍ក្នុងសម័យកម្ពុជាប្រជាធិតេយ្យ និងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា។ ប៉ុន្តែបើសិក្សាឲ្យស៊ីជម្រៅលក្ខណៈនៃការគ្រប់គ្រងរដ្ឋរបស់កម្ពុជាមានលក្ខណៈស្រដៀងគ្នាទៅនឹងការគ្រប់គ្រងរបស់ប្រទេសបារាំង ព្រោះហេតុនេះអ្នកដែលបង្កើតឲ្យមានការគ្រប់គ្រងតាមបែបរដ្ឋបាលនៅកម្ពុជាគឺ បារាំង ដែលគេហៅការគ្រប់គ្រងនេះជាការគ្រប់គ្រងសម័យទំនើបទៀតផង។ ការអនុវត្តនៃប្រព័ន្ធរដ្ឋបាលនៃប្រទេសបារាំងកំពុងបន្តការអនុវត្តមកដល់ពេលបច្ចុប្បន្ន ទាំងការគ្រប់គ្រង និងដំណើរការផ្សេងៗ គោលការណ៍ និងបទដ្ឋានដែលមានតាំងពីសម័យអាណានិគមក៏ត្រូវបានយកអនុវត្តន៍បន្ត។ ចំពោះការគ្រប់គ្រងមន្ត្រីរាជការប្រទេសកម្ពុជាបានជ្រើសរើសយកប្រព័ន្ធអាជីពមកប្រើដូចគ្នា ក្នុងការគ្រប់គ្រងការងាររបស់មន្ត្រីរាជការ បន្ថែមទៅលើការអនុវត្តនៃប្រព័ន្ធបែបវិមជ្ឈការ និងការធ្វើកំណែទម្រង់នៃប្រព័ន្ធរដ្ឋឲ្យមានលក្ខណៈបែបទំនើបដូចប្រទេសបារាំងផងដែរ។

## ២. និយមន័យ

### ➢ គោលការណ៍នៃការគ្រប់គ្រងសេវាសាធារណៈ

ពាក្យថាគោលការណ៍នៃការគ្រប់គ្រងសេវាសាធារណៈ មកពីពាក្យថា គោលការណ៍ + ការគ្រប់គ្រង។ ចំពោះពាក្យថាគោលការណ៍ បើតាមឯកសារខ្លះបានឲ្យន័យនៃពាក្យថាគោល

[5] លោក Rocheron , J.L.( 2016 ) . បទពិសោធន៍របស់ប្រទេសបារាំងអំពីវិមជ្ឈការ និងអ្នកគ្រប់គ្រងដែនដី
[6] នាយកដ្ឋានរដ្ឋបាលសាធារណៈ និងគ្រប់គ្រងការអភិវឌ្ឍ ( DPADM ) ឆ្នាំ ( ២០០៦ )

ការណ៍ខុសៗគ្នា។ ពាក្យថាគោលការណ៍អាចនិយាយបានថា ជាទ្រឹស្តីចេញជាគោលការណ៍សម្រាប់អនុវត្តតាមតួនាទី និងកាតព្វកិច្ចឲ្យត្រូវតាមបែបផែន។ គោលការណ៍ក្នុងការគ្រប់គ្រងមន្ត្រី និងសេវាមាន ២ គឺៈ

១.គោលការណ៍បែបប្រពៃណី

២.គោលការណ៍អទត្តពល

ចំពោះពាក្យថាការគ្រប់គ្រងវិញ បើតាមវចនានុក្រម Oxford Dictionary បានឲ្យនិយមន័យទៅលើពាក្យការគ្រប់គ្រង ( Management ) គឺជាការប្រព្រឹត្តទៅលើការត្រួតពិនិត្យលើវត្តការងារលើសកម្មភាពផ្ទាល់របស់នរណាម្នាក់ ការទទួលខុសត្រូវក្នុងតួនាទីម្នាក់ៗ[7]។ ម្យ៉ាងវិញទៀតការគ្រប់គ្រងគឺមានការពាក់ព័ន្ធទៅ លើការអនុវត្តច្បាប់ បទបញ្ញត្តិនានា និងសេចក្ដីសម្រេចចិត្តដែលធ្វើឡើងដោយរដ្ឋាភិបាល និងគ្រប់គ្រងទៅលើបញ្ញត្តិស្ដីពីសេវាសាធារណៈនានា[8]។

- **មន្ត្រីរាជការ ឬ មន្ត្រីរដ្ឋការ**

ពាក្យថាមន្ត្រីរាជការ ជាពាក្យមួយដែលងាយយល់ និងរាស្ត្រប្រជាឲ្យតែលឺពាក្យថាមន្ត្រីរាជការ គឺតែងនឹកគិតទៅដល់បុគ្គលដែលបំរើការជូនរាស្ត្រ និងរដ្ឋការ។ ក្នុងវចនានុក្រម **សម្តេចសង្ឃ ជួន ណាត** បានឲ្យនិយមន័យពាក្យថាមន្ត្រីរាជការថា ជាអ្នកមានគំនិត អ្នកមានសេចក្តីដឹងរាក់ជ្រៅ អ្នកប្រឹក្សាការងារផែនដី អ្នកដែលមានស័ក្តិយស[9]។

បើយោងតាមសន្ទានុក្រម ខ្មែរ - បារាំង នៃពាក្យស័ព្ទគតិយុត្តបានឲ្យនិយមន័យមន្ត្រីរាជការគឺជាបុគ្គលដែលតែងតាំងនៅក្នុងមុខតំណែងអចិន្ត្រៃយ៍ និងតាំងស៊ប់ក្នុងមុខតំណែងក្នុងឋានន្តរស័ក្តិតាមឋានានុក្រមណាមួយ[10]។

យោងតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា បានឲ្យនិយមន័យចំពោះមន្ត្រីរាជការ និងចំពោះការអនុវត្ត ពោលគឺ ៖ ចំពោះអ្នករាជការនៃព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខ័ណ្ឌទាំងពួងដែលបានបង្កើត និងរៀបចំឡើងដោយព្រះរាជក្រឹត្យ ហើយបានចូលធ្វើការនៅតាមក្រសួង ស្ថាប័ននានាដោយមានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍[11]។

[7] Oxford Dictionary

[8] សៀវភៅប្រព័ន្ធរដ្ឋបាលប្រទេសកម្ពុជា របស់សាស្ត្រាចារ្យ កៅ មុយ ថង ទំព័រ ៨៥ ឆ្នាំ ២០០៨

[9] វចនានុក្រមសម្តេចសង្ឃ ជួន ណាត ទំព័រ ៨៥៣

[10] តាមសន្ទានុក្រមបារាំង-ខ្មែរ នៃវាគស័ព្ទគតិយុត្ត

[11] ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១

យោងតាមបទអត្ថាធិប្បាយរបស់លោក **ប្រាក់ សុខ** មន្ត្រីរាជការ គឺជាអ្នកដែលបានជ្រើសរើសដោយការប្រឡងប្រជែងឲ្យចូលក្នុងក្របខ័ណ្ឌបង្កើតឡើង ដោយព្រះរាជក្រឹត្យ ដែលបានធ្វើនៅក្នុងក្រសួង/ស្ថាប័នណាមួយ និងទទួលបានប្រាក់សោធននិវត្តន៍[12]។

យោងតាមបញ្ញត្តិមុខងារសាធារណៈរបស់ប្រទេសថៃបានឲ្យនិយមន័យ មន្ត្រីរាជការខុសគ្នារវាងពាក្យថាមន្ត្រី ព្រោះមន្ត្រីរាជការជាមនុស្សដែលធ្វើការឲ្យរាជការ ហើយមន្ត្រីរាជការជាមន្ត្រីដែលបម្រើសេវាសាធារណៈ ដែលធ្វើទៅតាមការបញ្ជារបស់ថ្នាក់លើ និងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល[13]។

យោងតាមរដ្ឋធម្មនុញ្ញជាច្បាប់កំពូល នៃប្រទេសកម្ពុជាបានបែងចែកប្រភេទមន្ត្រីរាជការជា ២ ប្រភេទ គឺ៖ មន្ត្រីរាជការស៊ីវិល និងមន្ត្រីរាជាការយោធា ។ មន្ត្រីរាជការស៊ីវិលត្រូវបានគ្រប់គ្រងដោយច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឆ្នាំ១៩៩៤។ ចំណែកចំពោះមន្ត្រីរាជការយោធា ត្រូវបានបែងចែកជា ២ គឺ កងយោធពលខេមរភូមិន្ទ និង នគរបាលជាតិ។ ក្នុងក្របខ័ណ្ឌទាំងពីរត្រូវបានគ្រប់គ្រងដោយច្បាប់ និងព្រះរាជក្រឹត្យ ពោលគឺ៖ ច្បាប់ស្តីពីសហលក្ខន្តិកៈទូទៅនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ១៩៩៧ និងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនគរបាលជាតិ ឆ្នាំ២០០១។

បុគ្គលដែលមិនត្រូវបានចាត់ជាមន្ត្រីរាជការសាធារណៈ[14] រួមមាន ៖

- ស្ថិតនៅក្នុងក្រុមតុលាការ
- ជាមន្ត្រីស្ថិតនៅក្នុងក្រុមនីតិបញ្ញត្តិដែលមានលក្ខណៈពិសេសនោះស្ថិតក្នុងសហវិធានខាងលើ ។

បច្ចុប្បន្នភាពអង្គនៃមន្ត្រីរាជការត្រូវបានបែងចែកជា ៦ អង្គ ៖

- អង្គ រដ្ឋបាលទូទៅ
- អង្គ សុខាភិបាល
- អង្គ ការទូត
- អង្គ បច្ចេកទេស
- អង្គ គ្រូបង្រៀន

[12] តាមឯកឧត្តម ប្រាក់ សុខ ក្នុងបទអត្ថាធិប្បាយនៅសាលាភូមិន្ទរដ្ឋបាល ឆ្នាំ ១៩៩៥ ក្នុងខណៈដែលជាឯកឧត្តមរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

[13] តាមបញ្ញត្តិមុខងារសាធារណៈរបស់ប្រទេសថៃ ឆ្នាំ ២០០៨

[14] ច្បាប់ស្តីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២

– និង អង្គ រដ្ឋបាលស៊ីវិលក្រសួងមហាផ្ទៃ ។

➢ **សេវាសាធារណៈ**

សេវាសាធារណៈ មានអត្ថន័យច្រើនបែបបើតាមទស្សនៈយល់ឃើញរបស់បុគ្គលនីមួយៗ ពាក្យថាសេវាសាធារណៈ មកពីពាក្យថា សេវា + សាធារណៈ ។ ពាក្យថាសេវា បើយោងតាមវចនានុក្រមសម្តេចសង្ឃ បានមកពីថា សេវកៈ ឬ សេវក បានន័យថាជាអ្នកចាំទទួលបម្រើ អ្នកបម្រើ[15]។ ល ។ ចំពោះសាធារណៈសម្តេចសង្ឃក៏បានឲ្យនិយមដែលថា ជាការធ្វើទូទៅ មិនចេះអស់មិនចេះហើយ សម្រាប់ប្រើប្រាស់ទាំងអស់គ្នា[16]។ ដូច្នេះពាក្យថាសេវាសាធារណៈ គឺសំដៅដល់សកម្មភាពទាំងឡាយណាដែលបម្រើផលប្រយោជន៍ទូទៅ និងសម្រាប់ប្រើប្រាស់ទាំងអស់គ្នា។ បើក្នុងន័យនៃវិស័យសាធារណៈ គឺជាបណ្តុំវិធាននៃការផ្តល់នូវការបំពេញសេចក្តីត្រូវការរបស់រាស្ត្រប្រជាទូទៅដោយឈរលើគោលលើគោលគំនិតនៃសេវាសាធារណៈ។

សេវាសាធារណៈត្រូវបានរដ្ឋាភិបាលនៃប្រទេសកម្ពុជា ( ២០០៦ ) បានកំណត់ជា ៧ ចង្កោម[17] ៖

១.ចង្កោមសេវាពាក់ព័ន្ធ និងអធិបតេយ្យ

២.ចង្កោមសេវាពាក់ព័ន្ធផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម

៣.ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល

៤.ចង្កោមសេវាពាក់ព័ន្ធនឹងការលើកម្ពស់កិច្ចពាណិជ្ជកម្ម សហគ្រាសធនតូច និងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាងនឹងថែទាំហេដ្ឋារចនាសម្ព័ន្ធ

៥. ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី

៦.ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង

៧.ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើវចារណកម្មចំណាយ និងការបើកផ្តល់ ។

## ៣. ពន្យល់ន័យរបស់ប្រធានបទ

គោលការណ៍អនុវត្តចំពោះមន្ត្រីរាជការនៅព្រះរាជាណាចក្រកម្ពុជាក្នុងការគ្រប់គ្រងសេវាសាធារណៈដើម្បីឈានដល់ការបកស្រាយប្រធានបទខាងលើឲ្យមានន័យកាន់តែស៊ីជម្រៅ ជាដំបូងយើងត្រូវយល់ជាមុននូវន័យនៃប្រធានបទ។ ជាទូទៅគោលការណ៍អនុវត្តចំពោះមន្ត្រីក្នុងការផ្តល់សេវាសាធារណៈត្រូវបានអ្នកប្រាជ្ញមួយចំនួនបានបង្កើតឡើងនូវទ្រឹស្តី ក្នុងការអនុវត្តគោលការណ៍ការផ្តល់សេវាជូនរាស្ត្រប្រជា ដែលគោលការណ៍មួយចំនួនត្រូវបានយកមកអនុវត្តន៍មកដល់

[15] វចនានុក្រមសម្តេចសង្ឃ ជួន ណាត ទំព័រ ១៥០៤

[16] ដូចទី៦ ទំព័រ ១៣២៩

[17] ចង្កោមសេវាសាធារណៈ របស់រាជរដ្ឋាភិបាល ខែមិនា ឆ្នាំ ២០១០

សព្វថ្ងៃដូចជា ទ្រឹស្តីរបស់លោក ( **Heri Fayol** ) ក្នុងសៀវភៅ <<វិទ្យាសាស្ត្ររដ្ឋបាល>><< **Jacques Chevallier** >>បាននិយាយអំពីគោលការណ៍ក្នុងការអនុវត្តកិច្ចការរដ្ឋបាលដើម្បីឲ្យរដ្ឋបាលមានដំណើរការល្អ[18]។ ចំពោះទ្រឹស្តីរបស់លោក ( Max weber ) បាននិយាយអំពីការសនិទានកម្មមន្ត្រីរាជការក្នុងបម្រើរាស្ត្រប្រជា ឬ ក្នុងការផ្តល់សេវាជូនរាស្ត្រប្រជា[19]។ ចំណែកឯទ្រឹស្តីក្នុងសៀវភៅ <<វិទ្យាសាស្ត្ររដ្ឋបាល>> របស់លោក **J .chevallier** និង Jean-Francoise **Lachaume** ក៏បាននិយាយអំពីរដ្ឋបាលគំរូដែលលើកយកពីប្រព័ន្ធរដ្ឋបាលនាសម័យនោះ[20]។ ទ្រឹស្តីដែលបានរៀបរាប់ខាងលើនេះឆ្លុះបញ្ចាំងឲ្យយើងឃើញច្បាស់នូវគោលគំនិតមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រង និងដំណើរការផ្សេងៗ។ ប៉ុន្តែនៅមានទ្រឹស្តីមួយចំនួនទៀតដែលនឹងផ្សារភ្ជាប់ទៅគោលការណ៍នៃការគ្រប់គ្រងផ្សេងៗនៃសេវាសាធារណ: ដូចជារបស់ ( **Emile COMBES** ) ដែលលោកជាអតីតនាយករដ្ឋមន្ត្រីនៃប្រទេសបារាំង ដែលលោកមានទ្រឹស្តីពីរក្នុងការគ្រប់គ្រងមន្ត្រីរាជការ មន្ត្រីរាជការត្រូវមានចិត្តស្មោះត្រង់ចំពោះរដ្ឋ និងស្ថាប័នរបស់រដ្ឋ ហើយ លោក **Emile COMBES** ជាអ្នកដែលចាប់ផ្តើមកាត់បន្ថយនៃអំណាយ ឬ ឥទ្ធិពលនយោបាយក្នុងមុខងារសាធារណ:[21]។ នៅសហរដ្ឋអាមេរិចក៏មានអ្នកប្រាជ្ញក្នុងការបង្កើតឲ្យមានការគ្រប់គ្រងមន្ត្រីរាជការ និងសេវាសាធារណ: ដូចជា៖ លោក **Jefferson** លោកបានបង្កើតឲ្យមានប្រព័ន្ធរុះរើក្នុងក្នុងការគ្រប់គ្រងដោយគោលបំណងគឺមានសិទ្ធិជម្រុះចោលមន្ត្រីជាន់ខ្ពស់ទាំងអស់ ដែលធ្វើការនៅក្រោមអាណត្តិប្រធានាធិបតីមុនៗ[22]។ ក្រោយមកមានលោក អង់ឌ្រូ ហ្សាក់សន ( **Andrew Jackson** ) បានយកទ្រឹស្តីរបស់លោក **Jefferson " Spoils system "** មកអនុវត្ត ដើម្បីគ្រប់គ្រងមន្ត្រីរបស់មន្ត្រីទាំងនៅទូទាំងរដ្ឋ[23]។

រីឯការិយាល័យច្រកចេញចូលតែមួយវិញបង្កើតឡើងធ្វើឲ្យមានដំណើរការល្អ ក្នុងការផ្តល់សេវារបស់មន្ត្រីជូនប្រទេស ដែលប្រជាជនគាត់ទៅរកសេវាច្រកចេញចូលតែមួយដើម្បីបញ្ជាក់ និងទទួលយកលិខិតបទដ្ឋានគតិយុត្តផ្សេងដូចជា៖ ការបញ្ជាក់សញ្ញាបត្រទុតិយភូមិ សំបុត្រអត្រានុកូលដ្ឋានជាដើម។ ចំពោះច្រកចេញចូលតែមួយ គឺជាកន្លែងមួយដែលប្រមូលផ្តុំសេវាកម្ម និងនីតិវិធីរដ្ឋបាលមួយចំនួននៅកន្លែងតែមួយ មានន័យថាប្រជាជនទៅធ្វើនៅកន្លែងតែមួយ និងទទួលយកនៅកន្លែងតែមួយ។

---

[18]សៀវភៅ " វិទ្យាសាស្ត្ររដ្ឋបាល " របស់លោក J.Chevallier ឆ្នាំ ២០០២ ទំព័រ ៣១០

[19] សៀវភៅ " វិទ្យាសាស្ត្ររដ្ឋបាល " របស់លោក J.Chevallier ឆ្នាំ ២០០២ ទំព័រ ៣០៩-៣១១

[20] សៀវភៅ " វិទ្យាសាស្ត្ររដ្ឋបាល " របស់លោក J.Chevallier ឆ្នាំ ៣១២-៣៥៥

[21] Emile Comber ( 1835-1921 ) : ទ្រឹស្តីរបស់គាត់ហៅជាភាសាបារាំងថា " Le Combisme "

[22] Thomas Jefferson ( 1743-1826 ) ជាតួអង្គធំជាងគេនៃការធ្វើសេចក្តីថ្លែងការស្តីពីឯករាជ្យសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ ១៧៧៦ ។

[23] លោក J.Chevallier ទំព័រ៣១២ ដែលលោក Andrew Jackson ( 1767-1845 ) លោកជាអ្នកពង្រឹងអំណាចរបស់ប្រធានាធិបតេយ្យយ៉ាងខ្លាំង ។

ដូច្នេះ ក្នុងនាមជាមន្ត្រីរាជការដែលជាអ្នកផ្តល់សេវាជូនប្រជាជនត្រូវមានកាតព្វកិច្ច ក្នុងការទទួលយកនូវសំណើនៃតម្រូវការ និងពន្យល់ពីនីតិវិធីក្នុងការបំពេញលិខិតរដ្ឋបាលផ្សេងៗ[24]។

## ខ. ចំណោទបញ្ហា

- តើគោលការណ៍អនុវត្តចំពោះមន្ត្រីរាជការនៅព្រះរាជាណាចក្រកម្ពុជាក្នុងការគ្រប់គ្រងសេវាសាធារណៈមានការប្រព្រឹត្តទៅយ៉ាងដូចម្តេច ? និងឈរលើគោលការណ៍អ្វីខ្លះ?
- តើគោលការណ៍អនុវត្តចំពោះមន្ត្រីរាជការក្នុងការគ្រប់គ្រងសេវាសាធារណៈ មានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ ?
- តើគោលការណ៍ដែលអនុវត្តចំពោះមន្ត្រីរាជការក្នុងការផ្តល់សេវាមានប្រសិទ្ធភាព ដែលអាចឆ្លើយតបទៅនឹងតម្រូវការ ឬក៏ការវិវត្តរបស់សង្គមបានដែរឬទេ ?
- តើអ្វីខ្លះ? បញ្ហា និងដំណោះស្រាយ ចំពោះការអនុវត្តរបស់មន្ត្រីរាជការក្នុងការគ្រប់គ្រងសេវាសាធារណៈ

## គ. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដើម្បីធ្វើការស្រាវជ្រាវអោយកាន់តែស៊ីជម្រៅ និងជាក់លាក់អំពីប្រធានបទ ដែលស្តីពីគោលការណ៍អនុវត្តចំពោះមន្ត្រីរាជការនៅព្រះរាជាណាចក្រកម្ពុជា ក្នុងការគ្រប់គ្រងសេវាសាធារណៈ ក្នុងនាមយើងខ្ញុំជា និស្សិត។

បន្ទាប់ពីប្រទេសកម្ពុជាបានឆ្លងកាត់ការដាក់អាណានិគមរបស់ប្រទេសមហាអំណាច និងបានហែលឆ្លងកាត់សង្គ្រាមស៊ីវិល ច្រើនរាប់មិនអស់រួចមកនេះ ចុងក្រោយប្រទេសកម្ពុជាទទួលបាននូវ ឯករាជ្យនិង បានវិវត្តខ្លួនមកកាន់លទ្ធិប្រជាធិបតេយ្យវិញនៅឆ្នាំ ១៩៩៨។ ចាប់តាំងពីពេលនោះមក រដ្ឋាភិបាលបានយកចិត្តទុកដាក់ និង ប្រឹងប្រែងកំណែទម្រង់មន្ត្រីរាជការ រដ្ឋបាលសាធារណៈជាពិសេស បន្តការអភិវឌ្ឍសេវាសាធារណៈជូនប្រជាជន។ យ៉ាងណាមិញ ប្រធានបទស្រាវជ្រាវដែលស្តីពី គោលការណ៍អនុវត្តចំពោះ មន្ត្រីរាជការនៅព្រះរាជាណាចក្រកម្ពុជាក្នុងការគ្រប់គ្រងសេវាសាធារណៈនេះបានផ្តោតសំខាន់ ទៅលើការប្រព្រឹត្ត នៃការបំពេញការងាររបស់មន្ត្រីរាជការស៊ីវិល ទៅតាមគោលការណ៍ដែលបានកំណត់ទុកយ៉ាងជាក់លាក់ និងរៀបចំចាត់ចែង និងផ្តល់សេវាសាធារណៈ ពីមន្ត្រីរាជការ ជូនប្រជាជន ដែលត្រូវធ្វើការវិភាគវែកញែក នៅក្នុងពេលបច្ចុប្បន្ន ។

[24] អនុក្រឹត្យស្តីពី ច្រកចេញចូលតែមួយ

## ឃ. គោលបំណងស្រាវជ្រាវ

គោលបំណងក្នុងការស្រាវជ្រាវប្រធានបទនេះ គឺផ្តោតសំខាន់ទៅលើការឆ្លុះបញ្ចាំង និងធ្វើការស្វែងយល់អំពី គោលការណ៍អនុវត្តចំពោះមន្ត្រីរាជការ នៅព្រះរាជាណាចក្រកម្ពុជាក្នុងការគ្រប់គ្រងសេវាសាធារណៈ អនុវត្តនៅក្នុងសម័យអាណានិគមបារាំង និងនៅក្នុងពេលបច្ចុប្បន្ន។ បន្ថែមពីនេះទៀតការសិក្សាស្រាវជ្រាវនេះ និងបានពន្យល់បង្ហាញបន្ថែមនូវ ចំនុចវិជ្ជមាន និងអវិជ្ជមាន ទៅលើគោលការណ៍អនុវត្តចំពោះមន្ត្រីក្នុងការគ្រប់គ្រង ក៏ដូចជាបញ្ហាប្រឈម និងដំណោះស្រាយសំខាន់ៗមួយចំនួន ដើម្បីធ្វើការបង្កើន នូវប្រសិទ្ធភាពរបស់មន្ត្រី និងការរៀបចំចាត់ចែងសេវាសាធារណៈ អោយកាន់តែប្រសើរឡើងថែមទៀត។ មួយវិញទៀតគោលបំណងនៃការសិក្សា ស្រាវជ្រាវ គឺធ្វើការបកស្រាយឲ្យបានក្បោះក្បាយផងដែរ ទៅលើការប្រៀបធៀបរបបនៃការគ្រប់គ្រងមន្ត្រីរាជការក្នុងការផ្តល់ សេវាសាធារណៈរបស់ប្រទេសកម្ពុជានឹងបណ្តាប្រទេសផ្សេងទៀតនៅលើសកលលោកដូចជាប្រទេស អង់គ្លេស បារាំង ជាដើមបូករួម និងធាតុផ្សំសំខាន់ៗ នៃគោលការណ៍បែបប្រពៃណី និងគោលការណ៍អទត្តពល ដើម្បីជាជំនួយនៅក្នុង ការបន្តពង្រឹងបន្ថែមនូវសមត្ថភាពរបស់មន្ត្រីរាជការ សំរាប់ធ្វើការអភិវឌ្ឍន៍ កែលម្អ ក្នុងការគ្រប់គ្រងសេវាសាធារណៈនៅក្នុងប្រទេសកម្ពុជាអោយមានភាពរីកចម្រើនទៅមុខបន្តទៀត ។

## ង. វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងការចងក្រង និងការសិក្សាស្រាវជ្រាវសារណានេះឡើងមក ដែលចាំបាច់ត្រូវធ្វើការខិតខំស្វះស្វែងរកនូវរាល់វិធីសាស្ត្រសម្រាប់ធ្វើការប្រមូលនូវ ព័ត៌មាន ឯកសារ អត្ថបទ ដែលទាក់ទងនិងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ដើម្បីយកមកជាអំណះអំណាង និងវិភាគអោយមានគ្រប់ជ្រុងជ្រោយ។

ចំពោះការសិក្សាស្រាវជ្រាវសារណានេះ និងធ្វើការផ្អែកលើតថភាពជាក់ស្តែងមួយចំនួនដែលបានចងក្រង និងយកមកវិភាគបន្ថែមតាមរយៈវិធីសាស្ត្របែបពណ៌នាដោយប្រើនូវទិន្នន័យបន្ទាប់បន្សំ។

**ទិន្នន័យបន្ទាប់បន្សំ**

ប្រភពព័ត៌មាន ត្រូវបានប្រមូលនិងធ្វើការជ្រើសរើសចេញពី ឯកសារ អត្ថបទ សៀវភៅមេរៀន និក្ខេបបទ ទ្រឹស្តីរបស់អ្នកប្រាជ្ញមួយចំនួនសម្រាប់លិខិតបទដ្ឋានគតិយុត្ត នានាដែលអាចស្វែងរកបាននៅ បណ្ណាល័យ បណ្ណាសារដ្ឋានជាតិ គេហទំព័រដទៃទៀត ដូចជា របស់រាជរដ្ឋាភិបាល ក្រសួង គ្រឹះស្ថានដែលពាក់ព័ន្ធ និងជាពិសេសការណែនាំពី សំណាក់សាស្ត្រាចារ្យ ដែលដឹកនាំក្នុងសារណានេះ។

## ច. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឲ្យការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យល្អប្រសើរ ហើយមានគុណភាពដែលជាទីចង់បាន និងប្រកបដោយប្រសិទ្ធភាពខ្ពស់នោះ គឺចាំបាច់ក្នុងការកំណត់រចនាសម្ព័ន្ធដ៏ជាក់លាក់មួយ ដើម្បីជាពុទ្ធិជំនួយស្មារតីក្នុងការបំពេញតាមលក្ខណ:នៃវិធីសាស្ត្រស្រាវជ្រាវ និងត្រឹមត្រូវរបស់សាកលវិទ្យាល័យ ។ កិច្ចការស្រាវជ្រាវនេះរួមមាន ៖

- សេចក្តីផ្តើម
- ជំពូក១៖ គោលការណ៍បែបប្រពៃណី
  - ១. គោលការណ៍និរន្តភាពនៃសេវាសាធារណ:
  - ២. គោលការណ៍សមភាពនៃសេវាសាធារណ:
  - ៣. គោលការណ៍សម្របតម្រូវនៃសេវាសាធារណ:
  - ៤. គោលការណ៍មិនគិតថ្លៃនៃសេវាសាធារណ:
- ជំពូក២៖ គោលការណ៍បែបអទត្តពល
  - ផ្នែកទី ១ តម្លាភាពនៃសេវាសាធារណ:
  - ផ្នែកទី ២ គោលការណ៍គុណភាពនៃសេវាសាធាណ:
  - ផ្នែកទី ៣ គោលការណ៍នៃការចូលរួមរបស់អ្នកប្រើប្រាស់សេវា
  - ផ្នែកទី ៤ បញ្ហាប្រឈមនៃសេវាសាធារណ:
  - ផ្នែកទី ៥ ដំណោះស្រាយលើបញ្ហាប្រឈមនៃសេវាសាធារណ:
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូក ១

# គោលការណ៍បែបប្រពៃណី

ជាទូទៅការអនុវត្ត និងដំណើរការប្រព្រឹត្តទៅនៃសេវាសាធារណៈ ត្រូវតែស្របតាមគោលការណ៍ដែលមានចែង ដើម្បីធានាឲ្យបាននូវផលប្រយោជន៍ស្របទៅតាមគោលការណ៍នៃសេវាសាធារណៈ។ យើងសង្កេតឃើញថាគោលការណ៍សេវាសាធារណៈដែលស្របទៅតាមគោលបែបប្រពៃណីមាន បួន គោលការណ៍ធំៗ ៖ គោលការណ៍និរន្តភាពនៃសេវាសាធារណៈ គោលការណ៍សមភាពនៃសេវាសាធារណៈ គោលការណ៍សម្របតម្រូវនៃសេវាសាធារណៈ និងគោលការណ៍មិនគិតថ្លៃនៃសេវាសាធារណៈ។

## ១. គោលការណ៍និរន្តភាពនៃសេវាសាធារណៈ

ពាក្យថានិរន្តភាពនៃសេវាសាធារណៈមានន័យថា សេវាសាធារណៈតម្រូវឲ្យមានការប្រព្រឹត្តទៅយ៉ាងទៀងទាត់[25]។ និរន្តភាពនៃសេវាសាធារណៈត្រូវបានធានាដោយរដ្ឋក្នុងគោលដៅបម្រើផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋ ។ គោលការណ៍និរន្តភាពនៃសេវាសាធារណៈបានបើកសិទ្ធិឲ្យមន្ត្រីរាជការ និងអ្នកបម្រើសេវាមានសិទ្ធិធ្វើកូដកម្ម នៅពេលដែលខ្លួនមានតួនាទី និងកាតព្វកិច្ចក្នុងការប្រើសេវាសាធារណៈ[26]។ ប៉ុន្តែគោលការនិរន្តភាពនៃសេវាសាធារណៈក៏មានសិទ្ធក្នុងការបិទសិទ្ធិក្នុងការធ្វើកូដកម្ម ព្រោះយោងតាមការយល់ឃើញជាក់ស្តែងបានបង្ហាញថាការធ្វើកូដកម្មធ្វើឲ្យមានផលប៉ះពាល់ខ្លាំងដល់ដំណើរការនិរន្តភាពនៃសេវាសាធារណៈ ដូច្នេះនៅពេលដែលសេវាសាធារណៈត្រូវបានរាំងស្ទះ និងមិនដំណើរការ អ្នកដែលប៉ះពាល់ខ្លាំងគឺរាស្ត្រប្រជាអ្នកទទួលសេវាតែម្តង[27]។

និយាយជាទូទៅ ពាក្យថានិរន្តភាពមានន័យថាការធ្វើជាបន្តបន្ទាប់ដោយគ្មានការអាក់ខាន និងបន្តដំណើរការទៅមុខបើទោះជាមានបញ្ហាអ្វីក៏ដោយ។ និយាយជារួមក្នុងគោលការណ៍និរន្តភាពនៃសេវាសាធារណៈគឺមានន័យថាគឺធ្វើយ៉ាងណាឲ្យសេវាសាធារណៈប្រព្រឹត្តជាទៀងទាត់ និងធ្វើឲ្យការផ្តល់សេវាជូនរាស្ត្រប្រជាប្រកបដោយប្រសិទ្ធភាពខ្ពស់ និងអាចឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈ។

[25] សាស្ត្រាចារ្យ គង់ ប៊ុនធី សៀវភៅនីតិរដ្ឋបាលសាធារណៈ ឆ្នាំ២០១៥ ទំព័រ៩៨
[26] សាស្ត្រាចារ្យ ឌឿក ពិដោរ សៀវភៅនីតិរដ្ឋបាលទូទៅ ឆ្នាំ ២០០៩ ទំព័រ៩៧
[27] សាស្ត្រាចារ្យ ឌឿក ពិដោរ សៀវភៅនីតិរដ្ឋបាលទូទៅ ឆ្នាំ ២០០៩ ទំព័រ៩៧

បើយើងធ្វើការពិនិត្យក្នុងទិដ្ឋភាពភាពជាក់ស្តែងក្នុងគោលការណ៍និរន្តភាពនៃសេវា យើងអាចមើលឃើញដូចជា ការផ្តល់សេវាផ្នែកផ្សព្វផ្សាយតាមទូរទស្សន៍ ដែលសម្តៅទៅលើការផ្តល់សេវាសាធារណៈប្រភេទនេះ បើមានបាតុកម្មឲ្យកើតក្នុងការទាមទារផលប្រយោជន៍អ្វីមួយ ពោលគឺៈ នៅពេលមានព្រឹត្តិការណ៍កើតឡើង រដ្ឋដែលមានភារៈទទួលបន្ទុកផ្នែកនេះរដ្ឋត្រូវមានវិធានការក្នុងការត្រៀមរួចជាស្រេចក្នុងការផ្តល់សេវាកំសាន្តនានា។

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៧ បានចែងថា សិទ្ធិធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ [28]។

## ២. គោលការណ៍សមភាពនៃសេវាសាធារណៈ

គោលការណ៍នៃសមភាពនេះត្រូវបានទទួលស្គាល់ថា ជាគោលការណ៍មួយត្រូវបានអនុវត្តជាផលប្រយោជន៍រួមសម្រាប់អ្នកប្រើប្រាស់សេវា[29]។ គោលការណ៍សមភាពនេះ គឺជាគោលការណ៍មួយដែលផ្តល់នូវសេវាមួយដែលមានលក្ខណៈស្មើគ្នា រវាងគ្នា និងគ្នា រវាងអ្នកប្រើសេវា និងអ្នកប្រើសេវា ដែលចំពោះគោលការណ៍នេះត្រូវបានគេចាត់ទុកថាជាគោលការណ៍ទូទៅនៃនីតិ ដោយតុលាការកំពូលរដ្ឋបាលប្រទេសបារាំង[30]។

ផ្អែកតាមការអនុវត្តជាក់ស្តែង គោលការណ៍នេះមិនមានលក្ខណៈដាច់ខាត និងអរូបិយ៍ទេ[31]។ យ៉ាងណាមិញ គោលការណ៍ក៏មានលក្ខណៈមួយចំនួនផងដែរ ពោលគឺ សេវាសាធារណៈត្រូវមានសមភាពតាមជំពូក និងប្រភេទនៃអ្នកប្រើប្រាស់សេវា។ ចំពោះលក្ខណៈដាច់ឡែកនេះត្រូវបានកំណត់បើសិនជាលក្ខណៈនៃអ្នកប្រើប្រាស់មានលក្ខណៈដូចគ្នា ប៉ុន្តែបើអ្នកប្រើប្រាស់មានលក្ខណៈខុសគ្នា ដែរត្រូវតាមច្បាប់ដែលបានកំណត់ និងតាមអាកប្បកិរិយានៃប្រើប្រាស់សេវា[32]។ ភាពខុសប្លែកគ្នារវាងតារាងនៃតម្លៃសេវាសាធារណៈនេះហើយបានជាធ្វើឲ្យមានការលើកឡើងអំពី ការរើសអើងនៃសេវាសាធារណៈជាមិនខាន។ ចំពោះគោលការណ៍នេះ បើមើលទិដ្ឋភាពជាក់ស្តែងគឺជាការដាក់ចេញនូវតម្លៃមួយជាក់លាក់ផ្តល់ជូនដល់អ្នកប្រើប្រាស់។ ទាំងនេះជាហេតុដែលធ្វើបញ្ជាក់ច្បាស់លាស់សម្រាប់អ្នកប្រើប្រាស់សេវា ដូចជាការបំពេញបែបបទ និងលិខិតរដ្ឋបាលផ្សេង ឬ ការធ្វើស្លាកលេខម៉ូតូ និងការបញ្ជាក់លិខិតស្នាមផ្សេងៗដែលមានការបញ្ជាក់តម្លៃ និងរយៈពេលដែលត្រូវកំណត់ជាក់លាក់។ វាក៏បានស្តែងចេញពីការធ្វើលទ្ធកម្មជាសាធារណៈក្នុងការដេញថ្លៃទៅលើការគ្រប់គ្រងសេវា

[28] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៧

[29] សាស្ត្រាចារ្យ គង់ ប៊ុនធី សៀវភៅនីតិរដ្ឋបាលសាធារណៈ ឆ្នាំ២០១៥ ទំព័រ៩៩

[30] សាស្ត្រាចារ្យ ឌឿក ពិដោរ សៀវភៅនីតិរដ្ឋបាលទូទៅ ឆ្នាំ ២០០៩ ទំព័រ៩៨

[31] សាស្ត្រាចារ្យ ឌឿក ពិដោរ សៀវភៅ នីតិរដ្ឋបាលទូទៅ ឆ្នាំ ២០០៩ ទំព័រ៩៨

[32] ដូចទី៦

អ្វីមួយ ស្ថិតក្នុងគោលបំណងបម្រើដល់វិស័យសាធារណៈពន្លឿនចរន្ត នៃការផ្តល់សេវាឲ្យកាន់តែរហ័សទាន់ចិត្ត និងមិនសូវមានប្រសិទ្ធភាពនៅឡើយ។ ជាពិសេសការធ្វើលទ្ធកម្មនាពេលបច្ចុប្បន្នត្រូវបានបើកចំហរ និងផ្តល់ឱកាសឲ្យមានការចូលរួមពីវិស័យឯកជនកាន់តែធំទូលាយក្នុងការប្រកួតប្រជែងគ្នា។

តាមន័យទូលាយសមភាពនៃសេវាសាធារណៈសម្តៅដល់ការមិនរើសអើងចំពោះអ្នកប្រើប្រាស់សេវា ជាពិសេសគោលការណ៍នេះត្រូវបាននិយាយនិយាយយ៉ាងទូលាយ ជាការផ្តល់ជូនរាស្ត្រប្រជាគ្រប់រូបមិនបែងចែកបក្សពួក គឺជូនចំពោះបុគ្គលដែលមានបំណងចង់ទទួលយកសេវា។ យ៉ាងណាមិញសមភាពនេះមានត្រឹមចំពោះបុគ្គលតែប៉ុណ្ណោះ។ ប៉ុន្តែសមភាពនេះមិនមានចំពោះតម្លៃនៃសេវាឡើយពោល គឺវាអាស្រ័យទៅតាមប្រភេទនៃសេវា និងទៅលើកម្មវត្ថុជាក់ស្តែង។

យោងតាមសាលារាជធានីភ្នំពេញបានប្រកាសជាសាធារណៈពាក់ព័ន្ធ និងតម្លៃនៃការធ្វើដំណើរតាមរថយន្តក្រុង ដែលតម្លៃសំបុត្ររួមមាន[33] ៖

- សម្រាប់មនុស្ស ១ នាក់ តម្លៃ ១៥០០រ/លើក
- លើកលែងចំពោះ ព្រះសង្ឃ ចាស់ជរា ជនពិការ កម្មករ កម្មការី សិស្ស និស្សិត និងកុមារដែលមានកម្ពស់ក្រោម ១ម៉ែត្រ

បើយោងតាមសេចក្តីប្រកាសរបស់ក្រសួងសាធារណៈ និងដឹកជញ្ជូន លេខ ០៤៦ សក ធ្វើនៅថ្ងៃ២៧ ខែ មករា ឆ្នាំ ២០១៧ ស្តីពីនីតិវិធីក្នុងការចុះបញ្ជីយានយន្ត ការផ្តល់ស្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត។ សេចក្តីប្រកាសរបស់ក្រសួងសាធារណៈការដែលមានប្រការ ១៤ ប្រការ ដែលនៅក្នុងសេចក្តីប្រកាសនេះមានខ្លឹមសារ[34] ៖

ប្រការ ១ ៖ ប្រការនេះមាន គោលបំណងគ្រប់គ្រងយានជំនិះ ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងសិទ្ធិជាកម្មជាកម្មសិទ្ធិលើយានជំនិះ។

ប្រការ ២ ៖ គោលការណ៍នេះមានគោលដៅក្នុងការដូចខាងក្រោម៖

- កំណត់តាមបែបបទ និងនីតិវិធីនៃការចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់ និងផ្លាកលេខយានជំនិះ
- កំណត់នីតិវិធីនៃការលុបយានជំនិះដែលបានចុះបញ្ជីចេញពីបញ្ជីយានជំនិះ។

[33] សាលារាជធានីភ្នំពេញ

[34] សេចក្តីប្រកាសរបស់ក្រសួងសាធារណៈ និងដឹកជញ្ជូន លេខ ០៤៦ សក ធ្វើថ្ងៃ២៧ ខែ មករា ឆ្នាំ ២០១៧ ( ប្រការ១ , ប្រការ២ , ប្រការ១១ )

ប្រការ១១ ៖ ការចុះបញ្ជីយានជំនិះ ការអនុញ្ញាតចុះបញ្ជីយានជំនិះ ត្រូវបង់កម្រៃសេវាសាធារណៈ តាមការកំណត់ក្នុងប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណៈការ និងដឹកជញ្ជូន ។

យោងតាមសេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដែលបានជម្រាបជូនសាធារណៈជនឲ្យបានជ្រាប ដោយយោងតាមប្រកាសអន្តរក្រសួងលេខ ១៥៥១៥ ប្រ.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[35] បានកំណត់ថ្លៃសេវាលិខិតឆ្លងដែនធម្មតាដូចខាងក្រោម៖

១. សេវារយៈពេល២០ថ្ងៃ តម្លៃ០១ក្បាល ១០០ ដុល្លារសហរដ្ឋអាមេរិច

២. សេវារយៈពេល១០ថ្ងៃ តម្លៃ០១ក្បាល ១៥០ ដុល្លារសហរដ្ឋអាមេរិច

៣. សេវារយៈពេល០១ថ្ងៃ តម្លៃ០១ក្បាល ២០០ ដុល្លារសហរដ្ឋអាមេរិច

យោងតាមសេចក្តីប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ១៥៥១៥ ប្រក ស្តីអំពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ដែលក្នុងសេចក្តីប្រកាសនេះមានគោលបំណងក្នុងការផ្តល់សេវា រួមមាន[36]៖

ប្រការ ២ ៖ ក្រសួងមហាផ្ទៃត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវារដ្ឋបាល ក្នុងនោះរួមមាន៖ តារាងកម្រសេវារដ្ឋបាល ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ផ្តល់សេវារដ្ឋបាល និងការបង់កម្រៃសេវារដ្ឋបាល។

ក្រសួងមហាផ្ទៃត្រូវរៀបចំឲ្យមានកន្លែងទទួលពាក្យបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ មានការយឺតយ៉ាវហួសរយៈពេលអតិបរមានៃការផ្តល់សេវាជាដើម។

ចំពោះគោលការណ៍ខាងលើនេះក៏ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនូវសមភាពនៃសេវាកម្មពោលគឺ សមភាពរវាងតម្លៃនៃអ្នកប្រើប្រាស់ ដោយមានអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៦២ អនក្រ.បកដែលអនុក្រឹត្យនេះស្តីអំពី ការកំណត់ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ[37]។

[35] សេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដោយយោងតាមប្រកាសអន្តរក្រសួង លេខ ១៥៥១៥ ប្រ.ក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្តីពីការការកំណត់ថ្លៃតម្លៃលិខិតឆ្លងដែន

[36] សេចក្តីប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ១៥៥១៥ ប្រក ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ( ប្រការ ២ )

[37] អនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៦២ អនក្រ.បក ស្តីពីការកំណត់ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងតម្លៃតែមសារពើព័ន្ធ ( មាត្រា១ , មាត្រា ២ )

ចំពោះសេចក្តីប្រកាសរបស់អន្តរក្រសួងនេះផងដែលបានបង្ហាញឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់នូវគោលបំណងនៃសេចក្តីប្រកាសនេះផងដែរ គឺ៖

មាត្រា ១ ៖ ការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ នៅតាមតំបន់

មាត្រា ២ ៖ ការកំណត់ថ្លៃតែមប្រ៍សារពើព័ន្ធសម្រាប់បិទលើក្រដាសអត្រានុកូលដ្ឋាន

## ៣. គោលការណ៍សម្របតម្រូវនៃសាធារណៈ

គោលការណ៍សម្របតម្រូវ ជាគោលការណ៍ដែលបង្ហាញឲ្យឃើញថាសេវាសាធារណៈត្រូវស្ថិតនៅជាអចិន្ត្រៃយ៍ ដើម្បីបម្រើផលប្រយោជន៍សាធារណៈទូទៅ។ នៅក្នុងករណីដែលគោលការណ៍នេះទាមទារផលប្រយោជន៍ចំពោះអ្នកប្រើប្រាស់សេវា[38]។ ដូច្នេះសេវាសាធារណៈត្រូវតែមានការកែប្រែភាពអចិន្ត្រៃយ៍របស់ខ្លួន ធ្វើឲ្យមានការផ្លាស់ប្តូរ និងសម្របតម្រូវទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា។

ចំពោះមន្ត្រីរាជការ គោលការណ៍សម្របតម្រូវត្រូវបានលើកមកនិយាយអំពី ការអនុវត្តទូទៅក្នុងការបំពេញ ជាងនេះទៅទៀតគោលការណ៍នេះមានសារៈសំខាន់ក្នុងការកែប្រែតួនាទីសកម្មភាពរបស់មន្ត្រីរាជការ ដោយហេតុប្រព័ន្ធនៃការគ្រប់គ្រងមន្ត្រីការនៃប្រទេសកម្ពុជាបានជ្រើប្រព័ន្ធអាជីព ក្នុងការគ្រប់គ្រងមន្ត្រី ព្រោះមន្ត្រីជាអ្នកផ្តល់សេវាជូនប្រជារាស្ត្រ ដូច្នេះភាគច្រើននៃការផ្លាស់ប្តូរ គឺផ្លាស់ប្តូរទៅលើបទដ្ឋានគតិយុត្ត និងច្បាប់មួយចំនួនក្នុងការអនុវត្តរបស់មន្ត្រីរាជការ។ មន្ត្រីរាជការជាអាជ្ញាធរ ដែលមានលក្ខណៈទន់ភ្លន់ មិនរឹងទេក្នុងការបំពេញការងារ ដោយប្រែប្រួលទៅតាមស្ថានភាពជាស្តែងនៃច្បាប់ ដោយមានការធ្វើ និរាករណ៍ ការលុប ការដក និងការកែសម្រួលនៃសេចក្តីសម្រេច។

គោលការណ៍នេះច្រើនមានចែងក្នុងកិច្ចសន្យា ដែលជាការផ្តល់សម្បទានអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យសាធារណៈ។ ក្នុងលក្ខខ័ណ្ឌនេះរដ្ឋមានសិទ្ធិធ្វើការកែប្រែកិច្ចសន្យាដោយឯកតោភាគីក្នុងគោលបំណងបំពេញបន្ថែមនៃតម្រូវការរបស់រាស្ត្រប្រជា។ ចំពោះការធ្វើកិច្ចសន្យាក្នុងការធ្វើសម្បទាន ដោយអ្នកទទួលសម្បទានពុំមានមានសិទ្ធិផ្តាច់មុខចំពោះសេវាសាធារណៈឡើយ រាល់សកម្មភាពដែលពាក់ព័ន្ធ និងសាធារណៈត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋ។

ដូច្នេះសរុបមក គោលការណ៍នេះ គឺតម្រូវឲ្យមានការកែប្រែជាចាំបាច់ដើម្បីឆ្លើយតប និងដោះស្រាយបញ្ហាដែលកំពុងកើតមានឡើង និងមានគោលបំណងរួមក្នុងការបម្រើផលប្រយោជន៍ទូទៅ ហើយក៏ត្រូវឈរលើគោលគំនិតនៃគោលការណ៍នៃសេវាសាធារណៈផងដែរ។ ក្នុងការអនុវត្ត

[38] សាស្ត្រាចារ្យ ឌៀក ពិដោរ សៀវភៅនីតិរដ្ឋបាលទូទៅ ឆ្នាំ ២០០៩ ទំព័រ១០០

បច្ចុប្បន្នភាពនៃការសម្របតម្រូវសេវាសាធារណៈភាគច្រើនត្រូវបានរដ្ឋធ្វើសម្បទានទៅឲ្យឯកជន ។ គួយ៉ាង ដូចជាការធ្វើសម្បទាន អាកាសយានដ្ឋានអន្តរជាតិភ្នំពេញទៅឲ្យក្រុមហ៊ុនឯកជនធ្វើការគ្រប់គ្រង និងអភិវឌ្ឍ ដែលរដ្ឋមានសិទ្ធតែក្នុងការត្រួតពិនិត្យទៅលើការបំពេញកាតព្វកិច្ច មានចែងក្នុងកិច្ចសន្យា។ ការធ្វើសម្បទានទៅឲ្យក្រុមហ៊ុនឯកជនក្នុងគោលបំណងធ្វើឲ្យមានការធ្វើទំនើបកម្ម ព្រោះឯកជនសម្បូរធនធានហិរញ្ញវត្ថុ ដែលជាហេតុងាយស្រួលនៅក្នុងការអភិវឌ្ឍ និងសម្របខ្លួនឲ្យទាន់សភាពការណ៍នៃតម្រូវការរបស់របស់អ្នកប្រើប្រាស់សេវាសាធារណៈ។ ម្យ៉ាងវិញទៀតក្រុមហ៊ុនមានក្រុមហ៊ុនមួយចំនួនដែលរដ្ឋបានធ្វើសម្បទានទៅឲ្យក្រុមហ៊ុនឯកជន រួមមានក្រុមហ៊ុនផ្លូវដែក ដែលទទួលបន្ទុកក្នុងការស្ដាបនាផ្លូវដែក និងផ្ដល់សេវាដឹកជញ្ជូនតាមផ្លូវដែកក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀតក្រុមហ៊ុននេះត្រូវបានស្ថិតក្រោមការត្រួតពិនិត្យពីរដ្ឋទៅលើដំណើរការនៃការសាងសង់ និងដំណើរការផ្សេងៗ ផងដែរ។

ជាទិដ្ឋភាពក្នុងន័យទូលាយគោលការណ៍សម្របតម្រូវនៃសេវាសាធារណៈ ជាគោលការណ៍មួយដែលតម្រូវឲ្យមានការកែតម្រូវតវិយាបថរបស់សេវាធារណៈ ដែលមានលក្ខណៈអចិន្ត្រៃយ៍ ហើយការកែតម្រូវនេះជាកត្តាពិសេសមួយ ព្រោះសេវាសាធារណៈមិនអាចនៅត្រឹមតែមួយកន្លែងនិងមិនអាចមានលក្ខណៈគ្មានសកម្មភាពបានទេ បើមិនដូច្នេះសេវាសាធារណៈ និងមានលក្ខណៈចាស់កម្រិលថែមទាំងមិនអាចឆ្លើយតបទៅនឹងការវិវត្តរបស់សង្គមនាពេលបច្ចុប្បន្នបានឡើយ។ សម្របតម្រូវមានន័យថាជាការធ្វើឲ្យមានការកែប្រែទៅលើអ្វីមួយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអ្វីមួយ។

ទ្រឹស្ដីពិសេសសម្រាប់គោលការណ៍សម្របតម្រូវនៃសេវាសារណៈនេះពោល គឺមានគោលការណ៍មួយកែតម្រូវឲ្យមានការចូលរួមពីសំណាក់វិស័យឯកជន ក្នុងការកែប្រែនូវប្រព័ន្ធនៃការផ្ដល់សេវាហើយសបញ្ជាក់ឲ្យឃើញក្នុងករណីពីរគឺ៖ ទ្រឹស្ដីរាជ្យស័ក្តិ និងទ្រឹស្ដីឥតមិនបានគ្រោងទុក។

ចំពោះករណីរាជ្យស័ក្តិ គឺជាទ្រឹស្ដីដែលកើតចេញពីឆន្ទៈរដ្ឋបាល ដែលសំដៅដល់ការកែប្រែកិច្ចសន្យាដែលជាកិច្ចសន្យាឯកតោភាគីក្នុងរយៈពេលខ្លី ប៉ុន្តែភាគីរដ្ឋមានកាតព្វកិច្ចក្នុងការជួយចេញការខាត់បង់ផ្សេងទៅឲ្យឯកជនដែលជាអ្នកអនុវត្តតាមតម្រូវនៃកិច្ចសន្យារបស់រដ្ឋ។ ទ្រឹស្ដីនេះត្រូវចែងចែកជា ពីរ គឺ ៖ អនុវត្តទៅលើលក្ខន្តិកៈមន្ត្រីរាជការក្នុងប្រព័ន្ធអាជីព និងអនុវត្តសម្រាប់កិច្ចសន្យារដ្ឋបាល ។

- **ការអនុវត្តសម្រាប់កិច្ចសន្យារដ្ឋបាល**

គឺជាទ្រឹស្ដីដែលកើតចេញពីឆន្ទៈរដ្ឋបាល ដែលសម្ដៅដល់ការកែប្រែកិច្ចសន្យាដែលជាកិច្ចសន្យាឯកតោភាគីក្នុងរយៈពេលខ្លី ប៉ុន្តែភាគីរដ្ឋមានកាតព្វកិច្ចក្នុងការជួយចេញការខាត់បង់ផ្សេងៗទៅឲ្យឯកជនដែលជាអ្នកអនុវត្តតាមតម្រូវនៃកិច្ចសន្យារបស់រដ្ឋ។ ក្នុងករណីដែលមានការខាតបង់

ធ្ងន់ធ្ងររដ្ឋមានសំណងទៅលើការខូចខាតទាំងស្រុង ដែលរដ្ឋអាចជួយជាហិរញ្ញវត្ថុ ការប៉ះប៉ូវជាការមិនយកពន្ធ ជាដើម។

**ឧទាហរណ៍ ៖** រដ្ឋបានធ្វើសម្បទានទៅឲ្យក្រុមហ៊ុនមួយក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ នៅពេលដែលក្រុមហ៊ុនកំពុងអនុវត្តន៍តាមកិច្ចសន្យា ស្រាប់តែរដ្ឋធ្វើការកែប្រែកិច្ចសន្យាភ្លាមៗ ធ្វើឲ្យប៉ះពាល់ដល់ដំណើរការ និងមានការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

- **ចំពោះលក្ខន្តិកៈមន្ត្រីរាជការក្នុងប្រព័ន្ធអាជីព**

ក្នុងទ្រឹស្តីនេះផងដែលវាកើតតាមបរិបទនៃការប្រែនៃច្បាប់ ការប្រប្រែប្រួលនៃប្រព័ន្ធនៃការគ្រប់គ្រងមន្ត្រីគឺផ្អែកតាមការវិវត្តនៃសង្គម ធ្វើយ៉ាងណាឲ្យមន្ត្រីរាជការប្រុងប្រៀបខ្ពស់សម្រាប់ត្រៀមខ្លួនដែលត្រូវអនុវត្តតាមបទបញ្ជារួមដល់ថ្នាក់ខេត្តនៃមន្ត្រីរាជការ។ ចំណែកឯប្រព័ន្ធនិយោជន៍ វាមិនស្ថិតនៅក្រោមក្របខ័ណ្ឌនៃច្បាប់ទេ តែវាស្ថិតក្រោមចំណងគតិយុត្ត គឺ កិច្ចសន្យា ។

**ឧទាហរណ៍៖** ច្បាប់ចរាចរណ៍នៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៧ បន្ទាប់មកច្បាប់នេះត្រូវបានធ្វើវិសោធកម្មក្នុងឆ្នាំ ២០១៤ ដោយព្រះរាជក្រម នស/រកម/០១១៥/០០១ ហើយ ច្បាប់ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៥។ ក្នុងការធ្វើវិសោធណកម្មនេះត្រូវបានកែសម្រួលទៅលើ ជំពូក និងមាត្រានៃច្បាប់ ។

ចំណែកឯទ្រឹស្តីមិនបានគ្រោងទុកវិញ គឺជាទ្រឹស្តីមួយដែលក៏ត្រូវបានលើកយកមកដាក់បញ្ចូលបន្ថែមផងដែល ដោយទ្រឹស្តីនេះត្រូវបានបែងចែកជាពីរ យន្តការផងដែរសម្រាប់អនុវត្តន៍ចំពោះ៖ ក្នុងករណីសេដ្ឋកិច្ច និងនយោបាយ។

- **អនុវត្តចំពោះសេដ្ឋកិច្ច**

ជាទ្រឹស្តីដែលមិនកើតចេញពីគូភាគីរវាងរដ្ឋ និងឯកជនឡើយ ប៉ុន្តែវាកើតឡើងនៅពេលដែលមានវិបត្តិសេដ្ឋកិច្ចកើតឡើង។ និយាយជារួមនៅពេលដែលប្រទេសមានបញ្ហាសេដ្ឋកិច្ចកើតឡើងរដ្ឋមានភារៈកិច្ចក្នុងការជួយដល់ ការខូចខាតផ្នែកហិរញ្ញវត្ថុ ពី ៩០% ទៅ ៩៥%[39] ។

**ឧទាហរណ៍៖** ក្នុងឆ្នាំ ២០០៨ ដែលពិភពលោកកំពុងជួបវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ហើយប្រទេសកម្ពុជាក៏បានទទួលរងនៃឥទ្ធិពលនៃវិបត្តិនោះផងដែរ។ ក្នុងនេះក្នុងពេលបើមានក្រុមហ៊ុនឯកជនណាទទួលបានការធ្វើសសម្បទានពីរដ្ឋ ហើយមានបញ្ហាក្ស័យធន ដូច្នេះក្រុមហ៊ុនមានសិទ្ធិទទួលសំណងនៃការខូចខាតរបស់ដូចដែលបានរៀបរាប់ខាងលើ។

[39] សៀវភៅ " មេរៀននីតិរដ្ឋបាល " សាស្រ្តាចារ្យ យូ គូនី ឆ្នាំ ២០១៦ ទំព័រ ៥៤

➢ **ចំពោះនយោបាយ**

ជាយន្តការដែលគ្មានអ្នកណាស្មានដឹងថាវា និងកើតឡើងនៅពេលណាឡើយ យន្តការនេះវាកើតឡើងនៅពេលដែលមានគ្រោះមហន្តរាយ អសន្តិសុខសង្គម កើតសង្គ្រាម ជាដើម។ ការកើតអ្វីដែលយើងនឹកស្មានមិនដល់វាធ្វើឲ្យមានការប៉ះពាល់ដល់ដំណើរការផ្សេង និងធ្វើឲ្យមានការខាតបង់ផងដែរ។ ដូច្នេះរដ្ឋត្រូវមានវិធានការប៉ះពាល់ក្នុងការខាតបង់នេះដោយរដ្ឋអាចជួយចេញជាសំណងទៅតាមទំហំនៃការខាតបង់ពី ៩០% ដល់ ៩៥%។

## ៤. គោលការណ៍មិនគិតថ្លៃនៃសេវាសាធារណៈ

គោលការណ៍មិនគិតថ្លៃនៃសេវាសាធារណៈត្រូវបានចាត់ទុកជាវិធានទូទៅនៃសេវាសាធារណៈ ដោយសឹងតែគ្រប់វិស័យសាធារណៈរបស់រដ្ឋមិនមែនសុទ្ធតែមិនគិតថ្លៃទេ ក្នុងគោលបំណងធ្វើយ៉ាងណាបម្រើផលប្រយោជន៍ជូនរាស្ត្រប្រជា ឬ ការផ្តល់សេវាសាធារណៈដែលរដ្ឋផ្តល់ រដ្ឋតម្រូវឲ្យអ្នកទទួលសេវាបង់ថ្លៃតែលើសេវាតែប៉ុណ្ណោះ ( សេវាសាធារណៈប្រភេទនេះគេហៅថា សេវាសាធារណៈដែលមានលក្ខណៈ ឧស្សាហកម្ម ឬ សេដ្ឋកិច្ច ) ហើយការបង់ថ្លៃនៃសេវានេះធ្វើឡើងនៅក្នុងគោលបំណង រំលស់ឧបករណ៍ និងសម្ភារៈដែលបានបំពាក់ ។ ជាងនេះទៅទៀតរាល់ការផ្តល់សេវាសាធារណៈរបស់រដ្ឋទាំងអស់ គឺរដ្ឋពុំសូវគិតដល់ការខាត និងចំនេញឡើយ។ គោលការណ៍មិនគិតថ្លៃនៃសេវាសាធារណៈត្រូវបានគេទទួលស្គាល់ជាសកល ព្រោះការគ្រប់គ្រងសេវាគឺរដ្ឋជាអ្នកធ្វើការគ្រប់គ្រង ។ ដូចនេះការខាតបង់គឺជាភារៈកិច្ចរបស់រដ្ឋជាអ្នកទទួលរ៉ាប់រង[40]។

និយាយជាទូលាយ គោលការណ៍មិនគិតថ្លៃនៃសេវាសាធារណៈ គឺជាគោលការណ៍មិនផ្តល់នូវផលប្រយោជន៍ជូនប្រជាជនគ្រប់រូបទទួលបាននូវសេវាសាធារណៈដើម្បីសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ ជាពិសេសគោលជាគោលការណ៍មួយដែលរដ្ឋត្រូវទទួលបន្ទុកក្នុងការផ្តល់សេវាជូនប្រជាជនគ្រប់រូប និងរដ្ឋជាអ្នកទទួលរ៉ាប់រងលើការចំណាយទាំងអស់។ ការមិនគិតថ្លៃចំពោះសេវាសាធារណៈនេះត្រូវអនុលោមតាមរដ្ឋធម្មនុញ្ញ និងបទដ្ឋានគតិយុត្តផ្សេងៗ។

ចំពោះការមិនគិតថ្លៃលើសេវាសាធារណៈ យើងអាចសង្កេតឃើញមានដូចជា រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញ ដែលរដ្ឋបានផ្តល់ប្រជាជនធ្វើដំណើរដោយឥតគិតថ្លៃ ចំពោះ កុមារ ស្ត្រីមានផ្ទៃពោះ ចាស់ជរា ជនពិការ ព្រះសង្ឃ គ្រូបង្រៀន និងកម្មកររោងចក្រ។ នេះជាសក្ខីភាពបញ្ជាក់ឲ្យឃើញថាការផ្តល់សេវាសាធារណៈជូនរាស្ត្រប្រជា ជាភារកិច្ចរបស់រដ្ឋក្នុងការផ្តល់ជូនរាស្ត្រ។ យ៉ាងណាមិញ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបាន

[40] សាស្ត្រាចារ្យ ឌៀក ពិដោរ សៀវភៅនីតិរដ្ឋបាលទូទៅ ឆ្នាំ ២០០៩ ទំព័រ១០២

ចង្អុលបង្ហាញឲ្យឃើញយ៉ាងច្បាស់ពាក់ព័ន្ធ និងការផ្ដល់សេវាសាធារណៈដោយឥតគិតថ្លៃពីសំណាក់រាជរដ្ឋាភិបាល។

យោងតាម មាត្រា៦៨ ចែងថា ៖ រដ្ឋផ្ដល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋ ត្រូវបានទទួលបានការអប់រំយ៉ាងតិច ប្រាំបួនឆ្នាំ ។ រដ្ឋជួយផ្សព្វផ្សាយ និង លើកតម្កើងសាលាបាលី និងពុទ្ធិកសិក្សា[41]។

ចំណែកឯ មាត្រា៧២ ចែងថា ៖ សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ការការពារជម្ងឺ និងព្យាបាលជម្ងឺ ។ ប្រជារាស្ត្រក្រីក្រ ត្រូវបានទទួលការពិនិត្យរោគដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។ រដ្ឋរៀបចំឲ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ[42]។

នៅក្នុងគោលការណ៍មិនគិតថ្លៃនៃសេវាសាធារណៈ ត្រូវបានសរបង្ហាញឲ្យឃើញឡើងក្នុងប្រកាសសេចក្ដី។ ជាងនេះទៅទៀត បូករួមទាំងប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសលេខ ១៤៣៤២ ប្រក ស្ដីពីការផ្ដល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ[43]

ប្រការ ៤ ៖ ការកំណត់តម្លៃសេវារដ្ឋបាល ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវពិចារណាការកំណត់តម្លៃអនុគ្រោះ ចំពោះប្រជាពលរដ្ឋដែលមានប័ណ្ណក្រីក្រនៅមានសុពលភាព ដែលបញ្ជាក់ដោយ មេឃុំ ចៅសង្កាត់។

ប្រការ ៥ ៖ ពាក្យស្នើសុំរដ្ឋបាល នឹងត្រូវផ្ដល់ជូនដោយមិនយកកម្រៃ ។ រាល់សំណុំបែបបទ និងឯកសារនៃការផ្ដល់សេវារដ្ឋបាលមិនត្រូវឲ្យបិទតែមប្រ៍សារពើពន្ធឡើយ។

តាមសេចក្ដីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាលបានប្រកាសពាក់ព័ន្ធស្ដីពីការលុបចោលការយកថ្លៃសេវាលើការធ្វើលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលគោលដៅដើម្បីងាយស្រួល និងសម្រួលដល់ជីវភាពរបស់ប្រជាជន។ ក្នុងការលុបចោលទៅលើការមិនយកថ្លៃនៃលិខិតបទដ្ឋានគតិយុត្តទាំងនោះរួមមាន[44]៖

- សំបុត្រកំណើត
- សំបុត្រអាពាហ៍ពិពាហ៍

[41] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៦៨

[42] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រ ៧២

[43] សេចក្ដីប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសលេខ ១៤៣៤២ ប្រក ស្ដីពីការការផ្ដល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ ( ប្រការ ៤ , ប្រការ ៥ )

[44] សេចក្ដីប្រកាសពតិមានរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ០៨ មេសា ឆ្នាំ ២០១៨

- ការផ្តល់សៀវភៅគ្រួសារ
- ការស្នើសុំបន្ថែម ឬ បន្ថយសមាជិកក្នុងសៀវភៅស្នាក់នៅ
- ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

ដូច្នេះរាល់ ការស្នើ និងការធ្វើលិខិតបទដ្ឋានដូចដែលមានចែងខាងលើ គឺមិនត្រូវបានគិតថ្លៃឡើយ បើមានការធ្វើខុសពីពីបទបញ្ជាត្រូវទុកជានិរាករណ៍។

# ជំពូក ២

# គោលការណ៍អទត្តពល

គោលការណ៍អទត្តពល អាចកើតមានឡើងបានលុះត្រាតែមានអត្ថបទថៃង។ ដើម្បីឲ្យមានភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវា សាធារណៈកាន់តែមានប្រសិទ្ធភាព និងគុណភាព ការគ្រប់គ្រងរដ្ឋបាលបែបទំនើប មានការកកើតឡើង និងត្រូវបានយកមកអនុវត្តនាពេលបច្ចុប្បន្ន។ គោលការណ៍ថ្មីនេះត្រូវបានគេហៅថាជា គោលការណ៍អទត្តពល។ គោលការណ៍នេះរួមមានគោលការណ៍ធំៗចំនួន បី ដូចជា៖គោលការណ៍តម្លាភាពនៃសេវា គោលការណ៍គុណភាព និងគោលការណ៍សាធារណៈចូលរួមរបស់អ្នកប្រើប្រាស់សេវាសាធារណៈ។

## ផ្នែកទី ១ គោលការណ៍តម្លាភាពនៃសេវាសាធារណៈ

ជាគោលការណ៍រួមពាក្យថាតម្លាភាពនៃសេវាសាធារណៈបានឲ្យនិយម ក៏ដូចជាន័យផ្សេងៗពីគ្នាក្នុងការបកស្រាយ។ តម្លាភាព គឺជាភាពគ្មានលាក់បាំងចំពោះមុខនរណាម្នាក់ឡើយ។ ភាពត្រឹមត្រូវ ការស្មោះត្រង់ និងបើកចំហរព័ត៌មានជាសាធារណៈដល់សាធារណៈជន ក្នុងការផ្តល់សេវាសាធារណៈ។ នៅក្នុងសេវាសាធារណៈទាមទារផងដែរនូវតម្លាភាព និងផ្សារភ្ជាប់ទៅគណនេយ្យភាពផងដែរ។ គោលការណ៍នេះត្រូវបានបែងចែកជាចង្កោមតូចៗ ក្នុងគោលការណ៍តម្លាភាពនៃសេវាសាធារណៈ គឺ តម្លាភាព និងផលប្រយោជន៍ទូទៅ និងតម្លាភាពសេដ្ឋកិច្ច ។ ល ។

### ១.១.១. តម្លាភាព និងផលប្រយោជន៍សាធារណៈ

តម្លាភាពនៃសេវាសាធារណៈមានគោលដៅជាចម្បងក្នុងរង្វង់នៃសេវាសាធារណៈ អំណាចសាធារណៈក្នុងការធ្វើឲ្យកាន់តែប្រសើរឡើងរវាងទំនាក់ទំនងរបស់រដ្ឋបាល និងរដ្ឋបាល ក្នុងការកែលម្អនូវភាពមិនល្អ និងអាក្រក់នៃទំនាក់ទំនាក់ទំនង។ ជាងនេះទៅទៀតវាក៏ជាទំនាក់ទំនងរវាងរដ្ឋបាល និងរាស្ត្រប្រជាផងដែរ ក្នុងការផ្តល់សេវាជូនប្រជារាស្ត្រប្រកបដោយតម្លាភាពផងដែរ។

តម្លាភាព និងផលប្រយោជន៍សាធាណៈត្រូវបានស្តែងឡើងចាប់ពីដើមទស្សវត្សឆ្នាំ ១៩៧០ មកម្ល៉េះ ដោយបណ្តាប្រទេសនៅអឺរ៉ុប ចាប់ផ្តើមធ្វើកំណែទម្រង់ជាបន្តបន្ទាប់ ដើម្បីធ្វើយ៉ាងណាកាត់បន្ថយ ការសម្ងាត់ដាច់ខាតនៃការប្រព្រឹត្តទៅរបស់មន្ត្រីរដ្ឋការក្នុងការផ្តល់សេវាសាធារណៈ។ ជាងនេះតម្លាភាព និងផលប្រយោជន៍ទូទៅត្រូវបានផ្តល់ឲ្យមានសិទ្ធិទទួលបាននូវព័ត៌មានឲ្យទូលំទូលាយ ការទទួលឲ្យមានការកែលម្អ និងសិទ្ធិក្នុងការចូលរួមពិភាក្សាពិគ្រោះយោបល់ពាក់ព័ន្ធ និងដំណើរការរដ្ឋបាលផ្សេងៗ។ ចំពោះតម្លាភាពនេះផង ក៏ទាមទារឲ្យមានគណនេយ្យភាពក្នុងការបម្រើ និងការប្រព្រឹត្តទៅនៃដំណើរការរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលនីមួយៗ។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងមាត្រា ៥១ ( វាក្យខ័ណ្ឌ១ ) បានចែងអំពីការទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ ក្នុងនោះបានចែងថា ៖

មាត្រា ៥១ ៖ ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាការប្រជុំ[45]។

បើយោងតាមអនុក្រឹត្យ លេខ ១៨ អនប្រ.កប ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីអំពី ការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់កក្រោមជាតិ ដោយយោងតាម[46] ៖

មាត្រា ១ ៖ អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវានៅថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយដើម្បីបង្កភាពងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅតាមតម្រូវការរបស់ប្រជាជន។

មាត្រា ២ ៖ អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីយន្តការ គោលការណ៍ បែបបទ និងនីតិវិធីនៃការផ្តល់សេវានៅថ្នាក់ក្រោមជាតិ ព្រមទាំងការគាំទ្រតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការផ្តល់សេវារដ្ឋបាលទាំងនោះ។

មាត្រា ២៩ ៖ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវធានាឲ្យមានការតាមដាន ការត្រួតពិនិត្យ និងតាវាងតម្លៃជាប្រចាំ ព្រមទាំងដោះស្រាយនូវរាល់ភាពមិនប្រក្រតីក្នុងការផ្តល់សេវារដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

យោងតាមអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីក្រសួងមុខងារសាធារណៈមានមុខងារ និងភារកិច្ចដូចខាងក្រោម [47]៖

- រៀបចំ និងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដើម្បីគ្រប់គ្រងវិស័យមុខងារសាធារណៈ
- ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាព នៃប្រព័ន្ធគ្រប់គ្រងមុខងារសាធារណៈ តាមរយៈការតាមដានការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

[45] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥១ ( វាក្យខ័ណ្ឌ១ )

[46] អនុក្រឹត្យ លេខ ១៨ អនប្រ.កប ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការ បង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ( មាត្រា១ , មាត្រា២ , មាត្រា២៩ )

[47] យោងតាមអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីក្រសួងមុខងារសាធារណៈមានមុខងារ និងភារកិច្ច

• ដឹកនាំ នឹងជម្រុញការអនុវត្តគោលនយោបាយធនធានមនុស្ស ក្នុងរដ្ឋបាលសាធារណៈ និងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈព្រមទាំងធ្វើការវាយតម្លៃ និងជម្រុញការកែលម្អគុណភាពធនធានមនុស្ស និងសេវាសាធារណៈ

• សិក្សាស្រាវជ្រាវ និងលើកសំណើរអំពីការធ្វើទំនើបកម្ម និងសនិទានកម្មវិស័យមុខងារសាធារណៈ

• សិក្សាស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តនៃមុខងារសាធារណៈ

• ពិនិត្យ និងផ្តល់យោបល់លើសំណើពាក់ព័ន្ធនឹងការបង្កើត ការកែសម្រួល ការរៀបចំនឹងការប្រព្រឹត្តទៅរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

• ពិនិត្យ និងដោះស្រាយពាក្យបណ្តឹងតវ៉ារបស់មន្ត្រីរាជការស៊ីវិលដែលមានវិវាទពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ

• ដឹកនាំ តាមដាន និងជំរុញការគ្រប់គ្រងនឹងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈឲ្យឆ្លើយតបទៅនឹងតម្រូវការអភិឌ្ឍជាតិស្របតាមការរីកចម្រើនក្នុងតំបន់ និងសកលលោក

• រៀបចំ និងគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិតាមប្រព័ន្ធព័ត៌មានវិទ្យា។

យោងតាមប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៣៨៧១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត [48]៖

ប្រការ១ ៖ ប្រកាសមានគោលបំណងកំណត់អំពីការរៀបចំ និងាការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីប្រមូលផ្តុំសេវារដ្ឋបាលនៅកន្លែងតែមួយប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ស្របតាមគោលការណ៍បែបបទ និងនីតិវិធីដែលមានលក្ខណៈសាមញ្ញ និងច្បាស់លាស់ សំដៅឆ្លើយតបទៅនឹងសំណើ សំណូមពរ និងតម្រូវការរបស់ប្រជាពលរដ្ឋ។

ប្រការ ២ ៖ ប្រកាសនេះមានគោលដៅកំណត់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ការរៀបចំបុគ្គលិក របៀបរបបធ្វើការងារ ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត។

ប្រការ ២៦ ៖ រដ្ឋបាលរាជធានី ខេត្តត្រូវរៀបចំតារាងតម្លៃសេវារដ្ឋបាល និងត្រូវបិទផ្សាយតារាងនេះនៅតាមអង្គភាពច្រកចេញចូលតែមួយ និងនៅតាមទីសាធារណៈ។

[48] ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៣៨៧១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧

រដ្ឋបាលរាជធានី ខេត្តត្រូវផ្សព្វផ្សាយឲ្យបានទូលាយដល់សាធារណៈជន ស្តីអំពីយន្តការផ្តល់សេវារដ្ឋបាល ប្រភេទ តម្លៃរយៈពេល សុពលភាពនៃសេវារដ្ឋបាល ទម្រង់បែបបទ នីតិវិធី និងលក្ខខ័ណ្ឌភ្ជាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ និងការផ្តល់សេវារដ្ឋបាល ។ ការផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម លិខិតប័ណ្ណ វេទិកាសាធារណៈ និងកិច្ចប្រជុំនានាជាដើម។

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំឲ្យមានមធ្យោបាយនានាទទួលមតិយោបល់ សំណើ និងសំណូមពរនានាពីប្រជាពលរដ្ឋ។

ក្នុងការផ្សព្វផ្សាយព័ត៌មាន និងការប្រមូលមតិយោបល់ រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវខិតខំកៀងគរការចូលរួម និងកសាងភាពជាដៃគូរជាមួយមន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកដែលពាក់ព័ន្ធនានា។

បើយោងតាមការប្រកាសផ្សព្វផ្សាយរបស់ក្រសួងមហាផ្ទៃ ក្រោមអធិបតេយ្យ សម្តេចក្រឡាហោម **ស ខេង** ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋជួយលើកកម្ពស់ការផ្តល់សេវា និងដោះស្រាយបណ្តឹងតវ៉ាទាក់ទង និងការផ្តល់សេវាសាធារណៈបានដាក់ឲ្យប្រើប្រាស់នាថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ ដែលសិក្ខាសាលាផ្សព្វផ្សាយ ដែលមានយន្តការដូចជា [49]៖

- ការផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តនូវអនុក្រឹត្យ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ
- បង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាល និងបង្កើតការិយាល័យប្រជាពលរដ្ឋសម្រាប់ទទួល និងសម្រុះសម្រួល និងដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាជន
- ជាឯកសារបច្ចេកទេសដ៏មានសារៈសំខាន់ ក្នុងការចូលរួមសម្រេចនូវគោលនយោបាយសេវាសាធារណៈរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ប្រសិទ្ធភាព គុណភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាជូនប្រជាជនឲ្យកាន់តែប្រសើរ។
- ការបង្កើតឲ្យមាននូវយុទ្ធសាស្ត្របន្ថែម និងសម្របទៅតាមយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលក្នុងការសម្រេច និងបំពេញតម្រូវការនៃវត្ថុបំណងរបស់ប្រជាជន។

### ១.១.២. តម្លាភាព និងសេវាសាធារណៈសេដ្ឋកិច្ច

តម្លាភាព និងសេវាសាធារណៈសេដ្ឋកិច្ចពាក់ព័ន្ធទៅលើការធ្វើកិច្ចសន្យារដ្ឋបាល ការធ្វើលទ្ធកម្ម ឬ ការធ្វើកិច្ចសន្យាលើទ្រព្យសម្បត្តិសាធារណៈ និងការធ្វើរបាយការណ៍ផ្សេងៗពាក់ព័ន្ធ

[49] បណ្ណាល័យ គ.ជ.អ.ប ចុះថ្ងៃពុធ ទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧

លំហូរនៃចរន្តហិរញ្ញវត្ថុសាធារណៈ ដើម្បីធ្វើយ៉ាងណាឲ្យមានការទទួលព័ត៌មានជាក់ច្បាស់ដល់អ្នកប្រើប្រាស់សេវា។

សហគ្រាស ឬ គ្រឹះស្ថានសាធារណៈត្រូវបានទទួលនូវប្រតិភូកម្មក្នុងការធ្វើរបាយណ៍គណនេយ្យ ដើម្បីបញ្ជាក់ពីដំណើរការប្រព្រឹត្តទៅរបស់សេវាសាធារណៈ និងការវិភាគផ្សេងៗ។ ដើម្បីឲ្យមានតម្លាភាពទៅលើសេវាសាធារណៈសេដ្ឋកិច្ចតម្រូវឲ្យមានការចូលត្រួតពិនិត្យពីសំណាក់អង្គភាពពាក់ព័ន្ធ ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បូករួមអង្គភាពប្រឆាំងអំពើពុករលួយ។ ការត្រួតពនិត្យនេះ ត្រូវធ្វើជាសាធារណៈ និងផ្តល់ព័ត៌មានជាក់លាក់ជូនប្រជាជន។ ជាងនេះតម្លាភាពនេះក៏តម្រូវឲ្យមានគណនេយ្យភាព ចំពោះទង្វើ និងចំពោះមុខច្បាប់ផងដែរ។

**ឧទាហរណ៍ ៖** ក្នុងការគ្រប់គ្រងសេវាសាធារណៈឲ្យបានល្អ និងគ្រប់គ្រងផ្នែកហិរញ្ញវត្ថុក្នុងការគ្រប់គ្រងចំណូល ចំណាយ ចំពោះការផ្តល់សេវាជូនប្រជាជននៅថ្នាក់ក្រោមជាតិឲ្យមានប្រសិទ្ធភាព រដ្ឋត្រូវមានការធ្វើសវណកម្មជាតិ ក្នុងការត្រួតពិនិត្យរបាយការណ៍ការងារ និងហិរញ្ញវត្ថុ ពីសំណាក់ក្រសួងពាក់ព័ន្ធ។ ជាងនេះការប្រយុទ្ធប្រឆាំងចំពោះអំពើពុករលួយចំពោះមន្ត្រីរាជការដែលជាអ្នកផ្តល់សេវាជូនប្រជារាស្ត្រត្រូវតែមានការត្រួតពិនិត្យ និងលុបបំបាត់ចោលរាល់ភាពអសកម្ម។

យោងតាមរបាយការណ៍ពីអង្គការតម្លាភាពកម្ពុជា ( TRANSPARENCY INTERNATIONAL Cambodia ) បានធ្វើការស្ទង់មតិថ្នាក់ជាតិស្តីពីគណនេយ្យភាព និងតម្លាភាពនៃដំណើរការថវិកា[50]។ ការធ្វើការស្ទង់មតិនេះក្នុងគោលបំណងចង់ឲ្យមានការយល់ដឹងបន្ថែម និងជាឯកសារបន្ថែមដែលពាក់ព័ន្ធ និងក្រសួងស្ថាប័ននៅក្នុងប្រទេស អំពីទំហំថវិកាសាធារណៈ ជូនដល់ប្រជាជន។

តាមការស្ទង់មតិក៏បានឲ្យដឹងថាការយល់ដឹងពីថវិកាជាតិ ពីសំណាក់ប្រជាជននៅមានកម្រិតទាបនៅឡើយ ដោយការយល់ដឹងរបស់ប្រជាជនមានតែ ០.៣% ក្នុងការស្រេងមតិ។ ជាងនេះប្រជាជនដែលយល់ដឹងពីស្ថាប័នដែលទទួលបន្ទុករៀបចំថិវិកាជាតិ មានតែ ៥% ប៉ុណ្ណោះ។

ចំពោះការទទួលព័ត៌មានទាក់ទងថិវិការជាតិដែលធ្លាប់បានឃើញឯកសារពាក់ព័ន្ធមានតែ ០.១%ប៉ុណ្ណោះ ។

[50] អង្គការតម្លាភាពកម្ពុជា ធ្វើការប្រមូលទិន្នន័យក្នុង ខែ តុលា ឆ្នាំ ២០១៧

## ផ្នែកទី ២ គោលការណ៍គុណភាព នៃសេវាសាធារណៈ

### ១.២.១. ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ

នៅក្នុងឆ្នាំ២០១៧ មានការបោះឆ្នោតជាសកលនៅប្រទេសកម្ពុជាដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណិត្តទី ៤ នឹងត្រូវរៀបចំឡើង ដែលជាដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈការកែទម្រង់តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។ បន្ថែមពីនេះទៀតនោះ ដោយយោងតាមសុន្ទរកថារបស់ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាស្តីពី "យុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា បានថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី ៖ លើកទីមួយ នីតិកាលទី៣ នៃរដ្ឋសភានៅទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ នូវគ្រង់ចំណុចយុទ្ធសាស្ត្រចតុកោណចំនុចទី៣បានចែងផងដែលអំពីកំណែទម្រង់រដ្ឋបាលសាធារណៈ រួមមាន តាំងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល គឺជាយុទ្ធសាស្ត្រដែលមានភាពប្រទាក់ក្រឡាគ្នា ស្នូលនៃយុទ្ធសាស្ត្រនេះ គឺ អភិបាលកិច្ចល្អ ដែលមាន បួន វិស័យ គឺ៖ ទី១ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ទី២ ការធ្វើកំណែទម្រង់តុលាការ និងច្បាប់ ទី៣កំណែទម្រង់រដ្ឋបាលសាធារណៈ ។

ក្នុងនោះមានវិមជ្ឈការ និងវិសហមជ្ឈការ និងទី ៤ គឺ កំណែទម្រង់កងកំលាំងប្រដាប់អាវុធជាពិសេសការរំសាយកងទ័ព[51]។

#### ក. ប្រព័ន្ធវិមជ្ឈការ

វិមជ្ឈការគឺជាការធ្វើទំនាក់ទំនងទៅនឹងការបែងចែកឡើងវិញនូវអំណាចទំនួលខុសត្រូវនឹងធនធានហិរញ្ញវត្ថុសម្រាប់ផ្តល់សេវាកម្មសាធារណៈក្នុងចំណោមលំដាប់ថ្នាក់ផ្សេងៗ នៃអង្គការចាត់តាំងរបស់រដ្ឋ។ វាសម្តៅទៅលើការផ្ទេរទំនួលខុសត្រូវ លើការរៀបចំផែនការហិរញ្ញវត្ថុ និងការចាត់ចែងមុខងារសាធារណៈខ្លះៗ ពីអំណាចរដ្ឋបាលកណ្តាល និងទីភ្នាក់ងាររបស់ខ្លួនទៅឲ្យអង្គភាពមូលដ្ឋាន អង្គភាពក្រោម ឱវាទអាជ្ញាធរ សាជីវកម្មសាធារណៈពាក់កណ្តាលស្វយ័ត ឬ អាជ្ញាតំបន់[52]

[51] សុន្ទរកថារបស់ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាស្តីពី "យុទ្ធសាស្ត្រចតុកោណ "ដើម្បីកំណើនការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ នីតិកាលទី៣ នៃរដ្ឋសភានៅទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៤ស្តីអំពី**អភិបាលកិច្ចល្អ** គឺជាបុរលក្ខណៈវិនិច្ឆ័យសំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រកប ដោយចីរភាព មានសមធម៌ និងយុត្តិធម៌សង្គម។ អភិបាលកិច្ចល្អ តម្រូវឱ្យមាននូវការ ចូលរួមយ៉ាងទូលំ ទូលាយ មានការលើកកម្ពស់ ការចែករំលែកព័ត៌មាន មានគណនេយ្យភាព និងតម្លាភាព មានលក្ខណៈស្មើភាព និង ការមិន បោះបង់ចោល នូវបុគ្គលណាម្នាក់ ហើយនឹងមានការប្រតិបត្តិតាមវិធានច្បាប់

[52] សាស្ត្រាចារ្យ កៅ មុយថង សៀវភៅ រដ្ឋបាលសាធារណៈទំនើប ឆ្នាំ ២០០៧ ទំព័រ ២០៦

នៅក្នុងន័យម៉្យាងទៀតប្រព័ន្ធវិមជ្ឈការគឺជាប្រព័ន្ធមួយដែលអាជ្ញាធររដ្ឋបាលកណ្ដាល ទទួលស្គាល់នូវសិទ្ធិ អំណាច ក្នុងការសម្រេច របស់អាជ្ញាធររដ្ឋបាលមូលដ្ឋាន ដោយមានចែង នៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នានា។ វិមជ្ឈការជាប្រព័ន្ធ រដ្ឋបាលមួយដែល អនុញ្ញាត អោយសមូហភាពដែនដី ឬ សេវាសាធារណៈធ្វើការគ្រប់គ្រង ដោយខ្លួនឯង ក្នុងក្របខ័ណ្ឌនៃកាគោរពគោលការណ៍ នីត្យានុកូលភាព។ ប្រព័ន្ធវិមជ្ឈការចែកចេញជាពីរប្រភេទគឺៈ

- បើនីតិបុគ្គលនៃនីតិសាធារណៈនេះជាគ្រឹះស្ថានសាធារណៈ គេហៅថា វិមជ្ឈការបច្ចេកទេស។
- ប្រសិនបើនីតិបុគ្គលនៃនីតិសាធារណៈនោះជាសមូហភាពដែនដី គេហៅថាវិមជ្ឈការដែនដី។

នៅប្រទេសកម្ពុជា មានមណ្ឌលរដ្ឋបាលវិមជ្ឈការមានខេត្ត ក្រុង ឃុំ សង្កាត់។ ខេត្ត ក្រុង គឺជាមណ្ឌលរដ្ឋបាលវិសហមជ្ឈការដោយសារមានប្រតិភូកម្មអំណាច[53]ពីរដ្ឋាភិបាល។ អភិបាលខេត្ត ក្រុងតែងតាំង ផ្លាស់ប្ដូរ ឬ ដកតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។

**ឧទាហរណ៍ ៖** រាជរដ្ឋាភិបាលបានផ្ទេរថវិកាចំនួន ៤០ លានរៀល សម្រាប់ជាថវិការបស់រដ្ឋបាលស្រុកមួយក្នុងគោលដៅនៃការអភិវឌ្ឍ។ ក្រុមប្រឹក្សាស្រុកនោះមានភាពជាម្ចាស់ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកានោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអាទិ៍ភាពរបស់ស្រុកដោយផ្អែកតាមកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍស្រុក ដែលបានអនុម័តដោយក្រុមប្រឹក្សា ដូចជាសម្រាប់ជីអណ្ដូងទឹកស្អាត ជួសជុលផ្លូវលំ និងផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនៅក្នុងសហគមន៍តាមតម្រូវការរបស់ប្រជាពលរដ្ឋជាដើម។ ក្នុងន័យនេះ ថវិកា ៤០ លានរៀល រដ្ឋាភិបាលបានផ្ដល់នូវភាពជាម្ចាស់ក្នុងការគ្រប់គ្រងដល់ក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាមានភាពម្ចាស់ក្នុងការជ្រើសរើសគម្រោងមួយចំនួនដើម្បីផ្ដល់សេវាជូនប្រជាពលរដ្ឋ ដោយប្រើប្រាស់ថវិកា និងក្រុមប្រឹក្សាត្រូវតែអនុវត្តតាមនីតិវិធីដែលបានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានស្ដីពីថវិកាស្រុក[54]។

[53] **ប្រតិភូកម្មសមត្ថកិច្ច** គឺជាការផ្ទេរនូវសិទ្ធអំណាច តាមរយៈលិខិតបទដ្ឋានច្បាប់ច្បាស់លាស់ធ្វើការក្នុងនាមខ្លួនដែលជាថ្នាក់លើ និងការចុះហត្ថលេខាពីស្ថាប័នមួយទៅ ស្ថាប័ន ឬ អាជ្ញាធរមួយទៀតមិនមែនប្រតិភូកម្មអំណាចឱ្យទៅនរណាម្នាក់ឡើយ ហើយប្រតិភូកម្មហត្ថលេខាមិនប៉ះពាល់ដល់ការបែងចែកសមត្ថកិច្ចទេ ។ដោយយោងទៅលើលិខិតបទដ្ឋានច្បាប់អាជ្ញាធរដែលបានទទួលការធ្វើប្រតិភូកម្មអំណាចនឹងមានសិទ្ធិសំរេចដោយឆាប់រហ័ស និង មានប្រសិទ្ធភាពសំដៅឱ្យសម្រេចបាននូវ គោលដៅថ្នាក់លើបានដាក់ចេញផែនការដ៏ច្បាស់លាស់ ។

[54] **SHARES** អំពីប្រព័ន្ធមជ្ឈការ ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ

### ក.១ គុណសម្បត្តិ និង គុណវិបត្តិ

ជាការពិតណាស់ គ្មានប្រព័ន្ធរដ្ឋបាលណាមួយដែលល្អឥតខ្ចោះទេ។ យ៉ាងណាមិញវិមជ្ឈការទន្ទឹមនឹងនេះមានគុណសម្បត្តិក៏មានគុណវិបត្តិផងដែរ ដូចជា៖

- **គុណសម្បត្តិ**
  - ប្រជាពលរដ្ឋចូលរួមសម្រេចនូវអ្វីមួយដែលជាប្រយោជន៍ទូទៅក្នុងមូលដ្ឋានរបស់ខ្លួន
  - នាំឱ្យមានការអភិវឌ្ឍន៍ រីកចម្រើន និងប្រកបដោយចីរភាព
  - នាំឱ្យមានរបៀបគ្រប់គ្រងរដ្ឋបាលដែលរាស្ត្រខ្លួនឯងស្គាល់ច្បាស់ ហើយថ្នាក់រដ្ឋបាលនោះបានស្គាល់ ឬ ដឹងពីតម្រូវការជាក់ស្តែងនៅតាមមូលដ្ឋាន
  - ចំណាយពេលវេលាតិចក្នុងការ ទទួលសេវានាំអោយមានការអភិវឌ្ឍន៍ ហើយប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការរស់នៅ
  - មានស្វ័យភាពការងារនាំអោយមានកម្លាំងចិត្ត
  - ជាគ្រឹះនៃលទ្ធិប្រជាធិបតេយ្យតាមមូលដ្ឋាន
  - មានលទ្ធិប្រជាធិបតេយ្យស៊ីជម្រៅព្រោះមានការចូលពីប្រជាពលរដ្ឋក្នុងការ សម្រេចនូវអ្វីៗ ដែលជាប្រយោជន៍រាស្ត្រ[55]។
- **គុណវិបត្តិ**
  - បាត់បង់ការឯកភាពជាតិតែមួយ ដោយសារមានការីកចម្រើនមិនស្មើគ្នានៅមូលដ្ឋាន។ ជាមួយនេះ នៅមូលដ្ឋាននីមួយៗអាចនឹងលែងគិតគូទៅដល់សេចក្តីត្រូវការពិតប្រាកដរបស់ប្រទេសជាតិ។
  - អនុវត្តវិធានការរដ្ឋបាលខុសៗគ្នានៅតាមមូលដ្ឋាននីមួយៗ ដូចជាករណីការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានលើការងារអភិវឌ្ឍន៍។ ករណីនេះមិនដូចគ្នាទាំងអស់ទេ អាស្រ័យដោយចំនួនមនុស្សដែលមាននៅក្នុងមូលដ្ឋាននីមួយៗ
  - អាចបែកបាក់សាមគ្គីរវាងសមូហភាព និងសមូហភាព

[55] គេហទំព័រ Ank News សារព័ត៌មានអនាគតថ្មី អំពី៖ តើ ប្រព័ន្ធមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ មានន័យដូចម្តេច?

- ធ្វើឲ្យអាជ្ញាធរកណ្តាលមានការទន់ខ្សោយការអភិវឌ្ឍ អាចតាមរបៀបអាណាធិបតេយ្យព្រោះ ការអភិវឌ្ឍន៍មានការប្រកួតប្រជែងនាំឲ្យមានការប៉ះពាល់ដល់សម្ញហាភាពរៀងៗខ្លួន។

ម្យ៉ាងវិញទៀតប្រសិនបើមានការបរាជ័យនៃគណនេយ្យភាព តម្លាភាព និងការរីកចម្រើនយ៉ាងយឺតនូវដំណើរការកសាងនីតិរដ្ឋថែមទៀតផងនោះ វានឹងធ្វើឱ្យបរាជ័យយ៉ាងខ្លាំងទៅដល់ការកសាង អភិបាលកិច្ចមិនល្អធ្វើឱ្យចុះថមថយនូវលទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សេវាសាធារណៈជាមូលដ្ឋាន ពោលគឺ សេវាសំខាន់ៗ ដែលមានភាពចាំបាច់សម្រាប់ការវិនិយោគទុនលើធនធានមនុស្ស។

## ខ. វិសហមជ្ឈការ

វិសហមជ្ឈការមានន័យថារាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័នធ្វើប្រតិភូកម្មលើមុខងារសិទ្ធិអំណាច និងធនធាន ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក ទៅអង្គភាពក្រោមបង្គាប់ ឬ ទៅក្រុមប្រឹក្សាប្រភេទណាមួយដើម្បីអនុវត្តន៍មុខងារនេះក្នុងនាមរាជរដ្ឋាភិបាលស្ថាប័ន[56]។ ក្នុងន័យម្យ៉ាងទៀតថាវាជាបច្ចេកទេសរដ្ឋបាលមួយ ដែលអាជ្ញាធររដ្ឋបាលកណ្តាល រំលែកអំណាច ឬ កិច្ចការមួយចំនួនឲ្យទៅរដ្ឋបាលមូលដ្ឋានធ្វើការសម្រេចដោយខ្លួនឯងផ្ទាល់ មានន័យថា វាបច្ចេកទេសមួយក្នុងការៀបចំរដ្ឋ ដើម្បីជួយសម្រួលដល់ប្រព័ន្ធមជ្ឈការ ហើយបានផ្តល់ឲ្យនៅអំណាចខ្លះៗ ដែលពីមុនវាជាអំណាចរបស់រដ្ឋបាលកណ្តាល[57]។

**ឧទាហរណ៍** ៖ " ច្រកចេញចូលតែមួយ " ជាយន្តការសម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ត្រូវបាននាំយកទៅអនុវត្តមុខងារខាងសេវារដ្ឋបាលមួយចំនួនដែលបានការផ្ទេរអាណត្តិពីរាជរដ្ឋាភិបាល និងក្រសួង។ ហេតុនេះ ការិយាល័យច្រកចេញចូលតែមួយ ត្រូវបានបង្កើតឡើងនៅគ្រប់សាលាស្រុក-ខណ្ឌ ដែលជាទីកន្លែងប្រជាពលរដ្ឋអាចទទួលបានឯកសារសំណុំបែបបទគ្រប់ប្រភេទ និងព័ត៌មានពេញលេញស្តីពីការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ បន្ទុកសេវា និងតម្លៃពាក់ព័ន្ធនៅគ្រប់វិស័យ[58]។

### ខ.១ គុណសម្បត្តិ និង គុណវិបត្តិ

- **គុណសម្បត្តិ**

- កាត់បន្ថយការប្រើប្រាស់អំណាចហួសហេតុរបស់អាជ្ញាធរកណ្តាល

[56] ដកស្រង់ចេញពី ចំណេះដឹងទូទៅ ស្តីពីនិយមន័យវិសហមជ្ឈការ

[57] SHARES អំពីប្រព័ន្ធមជ្ឈការ ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ

[58] អង្គការទិន្នន័យអំពីការអភិវឌ្ឍ(Open Development Cambodia) ថ្ងៃទី៨ ធ្នូ ២០១៧ អំពីវិមជ្ឈការនិងវិសហមជ្ឈការ

- អាជ្ញាធរមូលដ្ឋានសម្រេចបញ្ហានៅនឹងកន្លែង
- ការងាររឆាប់រហ័សចំណេញពេលវេលា និងថវិកា[59]

• **គុណវិបត្តិ**

- ខ្វះលទ្ធិប្រជាធិបតេយ្យរាល់ការសម្រេចស្ថិតនៅលើអំណាចថ្នាក់កណ្តាល
- នៅបន្តគោរពអំណាចឋានានុក្រម
- អាជ្ញាធរជាអាជ្ញាធររដ្ឋ គឺជានីតិបុគ្គល ឬ ជាអង្គការដែលចាត់តាំងឡើង ឬ ដកហូតដោយរដ្ឋបាលកណ្តាលបានគ្រប់ពេល
- រាល់ប្រព័ន្ធការងារ គឺតាំងតំណាង រដ្ឋបាលកណ្តាលដោយគ្មានការបោះឆ្នោតជ្រើសតាំងអ្វីទេពោល គឺអាជ្ញាធរមូលដ្ឋានកើតមានឡើងនូវសិទ្ធិក្នុងការសម្រេចអាស្រ័យដោយសប្បុរសធម៌របស់អាជ្ញាធររដ្ឋបាលកណ្តាលប៉ុណ្ណោះ
- អាជ្ញាធរមូលដ្ឋានគ្មានថវិកាផ្ទាល់ខ្លួនទេគឺប្រើថវិការបស់ជាតិហើយក៏គ្មានសិទ្ធិក្នុងការជ្រើសរើសបុគ្គលិកដែរ។

## ១.២.២. សនិទានកម្មមន្ត្រីរាជការស៊ីវិល

ចាប់តាំងពីអាណត្តិមុននៃណរាជរដ្ឋាភិបាល គណៈរដ្ឋមន្ត្រីបានអនុម័តនូវយុទ្ធសាស្ត្រនេះក្នុងចំណោមយុទ្ធសាស្ត្រដទៃទៀត ដែលជាសសរគ្រឹះសំរាប់កិច្ចខិតខំប្រឹងប្រែងក្នុងការបន្តការងារកំណែទម្រង់រដ្ឋបាល និងមុខងារសាធារណៈ។

នៅក្នុងនេះផងដែរក៏បានបូករួមនូវយុទ្ធសាស្ត្រនិទានកម្មមុខងារសាធារណៈខែតុលាឆ្នាំ ២០០៩ដែលរៀបចំឡើងសំរាប់ពង្រឹងសមត្ថភាពនៃមុខងារសាធារណៈឱ្យក្លាយទៅជាដៃគូអភិវឌ្ឍប្រកបដោយក្តីសង្ឃឹមទុកចិត្ត និងអាចជឿជាក់បាន។ គំនិតផ្តួចផ្តើមជាអាទិ៍ភាពដែលពាក់ព័ន្ធទៅនឹងបញ្ហាបៀវត្សរ៍ ប្រព័ន្ធនិយោជន៍ និងការផ្តល់សេវាកំពុងត្រូវបានអនុវត្តសមស្របទៅតាមមធ្យោបាយដែលមានស្រាប់។ គោលដៅនៃកំណែទម្រង់ គឺដាច់ខាតត្រូវធានាឱ្យបាននូវនិរន្តភាពជាចាំបាច់។ គឺជាការផ្លាស់ប្តូររដ្ឋបាលឱ្យទៅជាដៃគូអភិវឌ្ឍន៍ប្រកបដោយថាមពល គឺជាអាទិ៍ភាពមួយក្នុងចំណោមអាទិ៍ភាពនានាដទៃទៀត។ ការធ្វើកំណែទម្រង់ បៀវត្សរ៍ និងការជម្រុញល្បឿនក្នុងការធ្វើកំណែទម្រង់មួយនេះត្រូវបានចាប់ផ្តើមឡើងនៅក្នុងគម្រោងសារពើពន្ធដែលបានកំណត់ និងត្រូវចៀសវាងធ្វើយ៉ាងណា កុំអោយប៉ះពាល់ដល់ស្ថេរភាពសារពើពន្ធ និងហិរញ្ញវត្ថុ។

[59] ដូចទី៥

- **ការគិតគូរដល់អ្នកពាក់ព័ន្ធ**

កំណែទម្រង់រដ្ឋបាល គឺជាកិច្ចខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងចំណោមកំណែទម្រង់រដ្ឋទាំងមូល។ ការប្រែប្រួលនៅក្នុងមុខងារសាធារណៈ គឺមានការជះឥទ្ធិពលដោយផ្ទាល់ដល់ស្ថាប័ន ផ្សេងៗទៀតផងដែរ ជាពិសេសគឺទាក់ទងនឹងកត្តាប្រាក់បៀវត្សរ៍ ។

- **ទម្លាប់ និង ការសំរេចមុន**

នៅក្នុងក្របខ័ណ្ឌគតិយុត្តដែលស្ថិតនៅជាធរមានសម្រាប់មុខងារសាធារណៈ ត្រូវបានបង្កើតឡើងតាមទម្លាប់បុរាណ និងដោយផ្អែកតាមប្រព័ន្ធអាជីពដែលធ្លាប់បានអនុវត្តន៍ពីមុនមក។ នាពេលបច្ចុប្បន្ន ប្រព័ន្ធនេះកំពុងត្រូវបានដាក់ឱ្យដំណើរការ។ កន្លងមក រាជរដ្ឋាភិបាលបានសម្រេចចិត្តជ្រើសរើសយកមូលដ្ឋានដ៏រឹងមាំមួយសមស្របសំរាប់ការធ្វើកំណែទម្រង់មួយនេះ។ ដោយផ្អែកតាមយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រសនិទានកម្មមន្ត្រីរាជការកំណែទម្រង់រដ្ឋបាល និងត្រូវធ្វើការងារមួយចំនួនជាជំហានៗដូចខាងក្រោម :

- ខិតខំរក្សាទំហំមន្ត្រីរាជការសរុបដែលមានបច្ចុប្បន្នឱ្យមានទំហំថេរ។ ទោះជាយ៉ាងនេះក្តី ទំហំមន្ត្រីរាជការនេះនឹងប្រែប្រួលច្រើនចំពោះវិស័យអាទិ៍ភាព និងចំពោះក្រុមការងារជួរមុខដែលនៅមួយតំបន់ឆ្ងាយមួយ ។ ការចាត់តាំងមន្ត្រីរាជការឱ្យទៅបំរើការនៅគ្រប់ទីកន្លែងតាមតម្រូវការចាំបាច់នឹងមានសារៈសំខាន់យ៉ាងខ្លាំងដល់ការអនុវត្តគម្រោងនានា ដើម្បីសម្របសម្រួល និងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងជាពិសេសចំពោះកម្មវិធីពង្រាយមន្ត្រីរាជការ ។
- ពង្រឹងការគ្រប់គ្រងបុគ្គលិក និងយន្តការត្រួតពិនិត្យដើម្បីបង្វែធនធានមនុស្សឱ្យទៅធ្វើការតាមកន្លែងដែលត្រូវការជាអាទិ៍ភាព និងដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរទម្លាប់ជាបណ្តើរៗ។ ទាំងនេះនឹងត្រូវរួមបញ្ចូលនូវវិធានការចាប់បង្ខំមួយចំនួនតាមផ្លូវច្បាប់និងការដាក់ចេញនូវវិធានការគ្រប់បែបយ៉ាងដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងធនធានមនុស្សឱ្យបានកាន់តែប្រសើរឡើង ។ ការបញ្ចប់ និងការដាក់ឱ្យធ្វើវិសហាមជ្ឈការប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមបច្ចេកវិទ្យាព័ត៌មាន គឺជាអាទិ៍ភាពជាចម្បងមួយ។
- ជាបណ្តើរ ទី១ លាភការរបស់មន្ត្រីរាជការនឹងកើនឡើងពី ១០% ទៅ ១៥% ក្នុងមួយឆ្នាំដោយស្របតាមមធ្យោបាយដែលប្រើប្រាស់ដោយរដ្ឋាភិបាល។ គោលការណ៍ ស្ថិរភាព និងដើម្បីទាំងអស់គ្នា គឺស្ថិតនៅក្នុងគំនិតនៃយុទ្ធសាស្ត្រ។ ដំណោះស្រាយជាដំបូង គឺធ្វើឲ្យបានប្រសើរឡើងចំពោះការប្រើប្រាស់នូវធនធានរបស់រដ្ឋាភិបាលដែលមានស្រាប់ និងទី២ គឺកំណត់នូវរបៀប និងមធ្យោបាយដើម្បីបង្កើននូវធនធានដែលមានស្រាប់ឱ្យលើសពីទំហំនៃ

គម្រោងសារពើពន្ធដែលបានគ្រោង ។ យុទ្ធសាស្ត្រនេះ អនុវត្តបានត្រូវមានធាតុផ្សំសំខាន់ៗ ដូចជាការកំណត់មុខងារអាទិ៍ភាព ( ថ្នាក់ដឹកនាំជាន់ខ្ពស់ និងអ្នកមានជំនាញ ជំនាញឯកទេស គ្រូបង្រៀន សេវាសុខភាព ការគ្រប់គ្រងហិរញ្ញវត្ថុ ) កន្សោមអាទិ៍ភាព និងកម្មវិធីនានា ដូចជាហ៊ីវ/អេដស៍ ) ជាមធ្យោបាយ ដើម្បីជំរុញការអនុវត្តការងារ ។ បៀវត្សរ៍មូលដ្ឋាននឹងកើនឡើង ខណៈដែលធនធាននានាអាចប្រមូលបានការសិក្សាផ្សេងៗ និងបង្ហាញឱ្យឃើញទៅតាមជំនាញ ។

- រដ្ឋបាលសាធារណៈ នឹងក្លាយជារដ្ឋបាលមួយមានការិយាធិបតេយ្យតិចជាងមុន មានប្រសិទ្ធភាព មានតម្លាភាព និងងាយទទួលបានសេវាជាងមុនតាមរយៈការអនុវត្តដូចជារបបកិច្ចសន្យាក្រៅ ការធ្វើឯកជនភាវូបនីយកម្ម ការធ្វើវិសហមជ្ឈការ និង ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។ ឧបករណ៍ដែលធ្វើឱ្យប្រសិទ្ធភាពផ្លាស់ប្តូរមានកន្សោមអាទិ៍ភាព (ដើម្បីដោះស្រាយអ្វីដែល មានការអភិវឌ្ឍន៍យឺត)សេវាច្រកចេញចូលតែមួយ ( ដើម្បីសម្រួលដល់ការទទួលសេវាសាធារណៈ និងឱ្យមានតម្លាភាព ការបង្កើតសភារដ្ឋបាល និង ការិយាល័យប្រជាពលរដ្ឋ (ដើម្បីធានាដល់សមភាព សមធម៌ និងសម្របសម្រួល ដោះស្រាយវិវាទ ) រដ្ឋាភិបាលអេឡិចត្រូនិច ( ដើម្បីប្រសិទ្ធភាព និង តម្លាភាព) និងការចាប់ផ្តើមដំណើរការរបៀបគ្រប់គ្រងដោយប្រើប្រាស់រដ្ឋបាលពិសេស ( ដើម្បីសម្របសម្រួលរបៀបរបបថ្មីដែលត្រូវកាត់បន្ថយចំណាត់ការដែលមិនចាំបាច់ និងកែលម្អប្រព័ន្ធលាភការ ) ។
- វិសហមជ្ឈការនឹងត្រូវយកមកអនុវត្ត ក្នុងគោលបំណង ២ ៖

ទី១ ៖ គឺពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពនៃខេត្ត.ក្រុង ស្រុក.ខណ្ឌដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការធ្វើវិសហមជ្ឈការលើសេវាដែលពាក់ព័ន្ធនឹងមុខងារទ្រទ្រង់ ( សេវាទ្រទ្រង់ ) កំពុងដំណើរការ។

ទី២ ៖ គឺទាក់ទងនឹងការបង្វិតសេវាសាធារណៈ ( តាមរយៈសេវាជួរមុខ ) ឲ្យទៅជិតនឹងប្រជាពលរដ្ឋ ។ ធ្វើដូច្នេះបាន ប្រជាពលរដ្ឋនឹងមានភាពងាយស្រួលក្នុងការប្រើប្រាស់សេវា និង តាមរយៈការអនុវត្តវិសហមជ្ឈការនៅខេត្ត ក្រុងស្រុក ខណ្ឌ ឃុំ.សង្កាត់ ធ្វើឱ្យថ្នាក់នីមួយៗកាន់តែមានការទទួលខុសត្រូវ និង ឆ្លើយតបបានតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរ វិស័យបច្ចេកវិទ្យាព័ត៌មាននឹងត្រូវដើរតួនាទីយ៉ាងសំខាន់ដើម្បីបម្រើឱ្យការផ្តល់សេវានេះ។

- អភិវឌ្ឍន៍សមត្ថភាពមនុស្ស ដោយប្រើប្រាស់ឧបករណ៍គ្រប់បែបយ៉ាងដើម្បីលើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ និងកែលម្អរបៀបរបបធ្វើការ ។ គម្រោងសំខាន់ៗ និងត្រូវផ្តល់

នូវក្របខ័ណ្ឌអនុវត្តការងារចាំបាច់មួយចំនួនក្នុងរដ្ឋបាល និងជាមួយដៃគូក្នុងការអភិវឌ្ឍ។ អាទិ៍ភាពសំខាន់មួយក្នុងការអភិវឌ្ឍធនធានមនុស្សនឹងត្រូវផ្តោតទៅលើជំនាញសំខាន់ៗ មួយចំនួនពាក់ព័ន្ធនឹងការងារគ្រប់គ្រងការធ្វើផែនការ ការត្រួតពិនិត្យ និងលើជំនាញបច្ចេកទេស។

- បម្រើឱ្យកិច្ចការទាមទាររួម និងបំរើឱ្យការកែលម្អរបៀបរបបក្នុងការដល់សេវា។ ក្រសួងវិស័យនានា និងបន្តទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលបុគ្គលិកជំនាញឯកទេស ទៅតាមវិស័យនៃការទទួលខុសត្រូវរបស់ខ្លួន ។
- ការធ្វើឱ្យមានស្វ័យប្រវត្តិភាពជាបណ្តើរៗនូវដំណើរការគ្រប់គ្រង និងការផ្តល់សេវាតាមប្រព័ន្ធបច្ចេកវិទ្យាព័តមានដើម្បីបង្កើនគុណភាពសេវាសាធារណៈ និងដើម្បីដាក់ឱ្យប្រតិបត្តិបានពេញលេញនូវ ប្រព័ន្ធគ្រប់គ្រង ប្រព័ន្ធនៃការធ្វើផែនការ និងត្រួតពិនិត្យបែបវិសហាមជ្ឈការ ដូចជា ការប្រើប្រាស់របៀបគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យាជាដើម។ អាទិ៍ភាពចម្បង គឺ និងត្រូវរៀបចំប្រមូលចងក្រងសេវាសាធារណៈនានាទៅក្នុងប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ។
- កម្មវិធីសិក្សាមួយចំនួនកំពុងដំណើរការ ហើយនឹងជូនជាព័ត៌មានអំពីលទ្ធផល តាមជំនាញនៅពេលក្រោយ ។

### ១.២.៣. ប្រព័ន្ធមុខងារសាធារណៈ

ជាធម្មតា នៅក្នុងបណ្តាប្រទេសជឿនលឿនជាច្រើននៅលើពិភពលោក គេមិនបញ្ចូលអ្នកនយោបាយ អ្នកធ្វើការក្នុងវិស័យពាណិជ្ជកម្ម ឬ ឧស្សាហកម្មឯកជនរាប់ចូលក្នុងប្រព័ន្ធមុខងារសាធារណៈឡើយពោលគឺមានតែអ្នកដែលធ្វើការអោយរាជការតែប៉ុណ្ណោះ ដែលស្ថិតនៅក្នុងមុខងារសាធារណៈ។ អ្នករាជការ ទាំងនេះអាចជា អ្នករាជការរបស់រដ្ឋ ឬ ជាអ្នករាជការរបស់សមូហភាពដែនដី។

ប្រព័ន្ធមុខងារសាធារណៈមានពីរប្រភេទគឺ ៖

**ក. ប្រព័ន្ធនិយោជន៍ ឬ ប្រព័ន្ធបើកចំហ**

ប្រព័ន្ធនេះពឹងផ្អែកទៅលើមុខនាទី។ ប្រព័ន្ធនេះបើកចំហដល់ការចូលទៅបំរើការងារក្នុងមុខនាទីផ្សេងៗទាំងមន្ត្រីចាស់និងអ្នកជ្រើសរើសថ្មី។ បន្ថែមពីទៀតប្រព័ន្ធនេះពឹងផ្អែកលើមុខនាទីមានន័យថា មានធ្វើការជ្រើសរើសបុគ្គលិក ដែលមានលក្ខណៈសមស្របបំផុតឲ្យបំពេញមុខនាទីដែលគេត្រូវការតាមរយៈការជ្រើសរើសបុគ្គលិកពីខាងក្រៅ ឬ ការផ្លាស់ប្តូរ តម្លើងមន្ត្រីខាងក្នុងផ្ទាល់។ ប្រជាពលរដ្ឋអាចចូលធ្វើការទាំងការងាររដ្ឋ និងការងារឯកជនពោលគឺ ប្រព័ន្ធនេះលើកទឹកចិត្តដល់ប្រជាពលរដ្ឋអោយខិតខំអភិវឌ្ឍន៍សមត្ថភាព និងបំពេញការងារអោយបានល្អមានឱកាសក្នុងការទទួលបានការងារដែលមានមុខនាទីខ្ពស់ទាំងក្នុងផ្នែកឯកជន និងរដ្ឋបាន។

ប្រព័ន្ធនេះមានលក្ខណៈបត់បែនដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រងចាត់ចែង ហើយទាមទារនូវជំនាញ វិជ្ជាជីវៈច្បាស់លាស់តាមការវិភាគមុន និងអោយចូលធ្វើការ ពោលគឺ ជាការកំណត់មុខងារតាមកិច្ចការនិងការទទួលខុសត្រូវយ៉ាងច្បាស់លាស់ និងតម្រូវតាមការចាំបាច់របស់ក្រសួងស្ថាប័នរួចគេរើសមនុស្សដែលសមស្រប តាមលក្ខណៈនេះសំរាប់មកកាន់មុខងារដោយគ្មានធានាអំពីរឿងឋានន្តរស័ក្តិ ឬ ថ្នាក់។

តាមគោលការណ៍របស់ប្រព័ន្ធនេះ យើងអាចសង្កេតឃើញមានចំណុចគួរអោយកត់សម្គាល់ដូចខាងក្រោម ៖

- អ្នកត្រូវបានជ្រើសរើសត្រូវធ្វើការងារ ឬ តំណែងកំណត់មួយមិនអាចធ្វើការផ្លាស់ប្តូរការងារបានទេ ពោលគឺ គេអាចដោះដូរការងារបានតែនៅពេលដែលគេត្រូវបានធ្វើការជ្រើសរើសការងារជាថ្មីប៉ុណ្ណោះ។
- រើសអោយចូលធ្វើការតាមរយៈកិច្ចសន្យា។ អ្នកធ្វើការនេះអាចធ្វើការក្នុងរាជការសំរាប់តែរយៈពេល ដែលកំណត់ក្នុងកិច្ចសន្យាប៉ុណ្ណោះ លើកលែងតែមានការធ្វើកិច្ចសន្យាបន្ត ឬ ធ្វើកិច្ចសន្យាថ្មីសំរាប់ការងារថ្មីមួយទៀត។ កិច្ចសន្យារបស់គេធ្វើរវាងរាជការជាមួយបេក្ខជន ហើយកិច្ចសន្យានេះអាចស្ថិតក្រោមច្បាប់សាធារណៈ ឬ ច្បាប់ឯកជន ។
- ការចូលបម្រើការងារក្នុងរាជការគ្មានការធានាអាជីព និងពុំមានការឡើងឋានន្តរស័ក្តិ ឬ ថ្នាក់ច្បាស់លាស់ទេ និងមិនគិតពីអាយុ។
- អ្នកត្រូវបានគេជ្រើសរើសអាចចរចាអំពីលក្ខខណ្ឌការងារ និងប្រាក់ខែដែលត្រូវទទួល។
- រាជការអាចបញ្ឈប់មន្ត្រីដែលត្រូវបានជ្រើសរើសអោយចូលធ្វើការមុនចប់កិច្ចសន្យាបាន បើគេរកឃើញថា គ្មានសមត្ថភាព មិនគោរពទៅតាមលក្ខខណ្ឌ និងការទទួលខុសត្រូវនៅក្នុងកិច្ចសន្យា ឬ ក្នុងករណីចាំបាច់។

ប្រព័ន្ធនេះត្រូវបានគេអនុវត្តន៍នៅក្នុងប្រទេសមួយចំនួនដូចជា សហរដ្ឋអាមេរិក ប្រទេសស្វីស ប្រទេសកាណាដាជាដើម លើកលែងបណ្តាប្រទេសសង្គមនិយមមួយចំនួន ។ នៅប្រទេសបារាំងវិញនោះរដ្ឋាភិបាលអនុវត្តប្រព័ន្ធនេះតែចំពោះភ្នាក់ងាររាជការដែលគ្មានក្របខ័ណ្ឌ ។

**ខ. ប្រព័ន្ធវិជ្ជាជីវៈក្របខ័ណ្ឌ ឬ ប្រព័ន្ធអាជីព ឬប្រព័ន្ធបិទ**

នៅព្រះរាជាណាចក្រកម្ពុជា បានប្រកាន់យកប្រព័ន្ធវិជ្ជាជីវៈក្របខ័ណ្ឌតាមការសម្រេច របស់រាជរដ្ឋាភិបាលកម្ពុជានាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៤។ ប្រព័ន្ធនេះគឺសម្តៅ ការផ្តល់មុខនាទី ក្នុងស្ថាប័នរដ្ឋ តែចំពោះមន្ត្រីរាជការក្របខ័ណ្ឌប៉ុណ្ណោះ ពោលគឺមិនបើកចំហដល់សិស្ស

និស្សិត ឬ អ្នកធ្វើការនៅវិស័យឯកជនដែលទើបត្រូវបានជ្រើសរើសថ្មីទទួលមុខនាទីនេះឡើយ ឬ ធ្វើការជ្រើសរើសមន្ត្រីសំរាប់មុខនាទីណាមួយឡើយ។

គោលការណ៍ប្រព័ន្ធនេះធ្វើការជ្រើសរើសមន្ត្រីរាជការអោយចូលបម្រើការងារ នៅក្នុងមុខងារសាធារណៈតាមការប្រលងប្រជែងចូលទៅក្នុងក្របខ័ណ្ឌមួយដែលគ្រប់គ្រងដោយរដ្ឋ ហើយការជ្រើសរើសនោះត្រូវកំណត់តាមសេចក្តីត្រូវការរបស់ក្រសួង ស្ថាប័ន ដែលកំណត់នៅក្នុងផែនការរដ្ឋ។ អ្នករាជការត្រូវបានជ្រើសរើសចូល តាំងពីឋានន្តរស័ក្តិជាន់ដំបូងនៃក្របខ័ណ្ឌ ទៅតាមប្រភេទក្របខ័ណ្ឌដែលខ្លួនប្រលងជាប់ ដែលមានមូលដ្ឋានលើកម្រិតសញ្ញាបត្រ ហើយអាចឡើងឋានន្តរស័ក្តិ ឬ ថ្នាក់និងអាចកាន់កាប់មុខតំណែងជាបន្តបន្ទាប់រហូតដល់ចូលនិវត្តន៍លើកលែងតែក្នុងករណីបាន ប្រព្រឹត្តនូវកំហុសធ្ងន់ធ្ងរដែលត្រូវបណ្តេញចេញ ឬ ស្លាប់ ( ដោយជំងឺ ឬ ក្នុង បេសកកម្ម )។

ប្រព័ន្ធនេះមានការបែងចែករចនាសម្ព័ន្ធជា អង្គ ប្រភេទ ក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សរ៍ ដោយមានមូលដ្ឋានលើកម្រិតនៃការបណ្តុះបណ្តាល អតីតភាពការងារ ឧបនិស្ស័យកាន់មុខតំណែង និង សក្តានុពលមន្ត្រី។ ប្រព័ន្ធនេះពឹងផ្អែកលើ សក្តានុពលរបស់មន្ត្រីម្នាក់ៗ ជាជាងពឹងផ្អែកលើមុខងារបច្ចុប្បន្នរបស់គេ។ មន្ត្រីអាចរក្សាក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់គេ ទោះបីមុខងារត្រូវបានគេលុបចោល ឬ លែងមានក៏ដោយ។

តាមគោលការណ៍ នៃប្រព័ន្ធនេះ យើងអាចសង្កេតឃើញមានចំណុចមួយចំនួនដូចជា:

- មន្ត្រីត្រូវបានជ្រើសរើសតាមរយៈការប្រលងប្រជែងចូលក្របខ័ណ្ឌរដ្ឋ
- មន្ត្រីរាជការមិនមែនជ្រើសរើសសំរាប់ការងារឬតំណែងមួយជាក់លាក់ទេ ពោលគឺគេត្រូវបានជ្រើសរើស ក្នុងក្របខ័ណ្ឌមួយ ដែលគេអាចទទួលការងារបានច្រើនប្រភេទ។ នៅក្នុងរយៈពេលប្រតិបត្តិការងារ របស់គេ។ ជាទូទៅ គេអាចធ្វើការងារបានច្រើនយ៉ាងនៅក្នុងក្របខ័ណ្ឌរបស់គេ និងអាចទទួលការងារនៅក្នុងក្របខ័ណ្ឌផ្សេងក៏មានតាមការចាំបាច់ឬតាមយៈការប្រលងប្រជែង
- មន្ត្រីរាជការធ្វើការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ដោយលិខិតផ្លូវការចេញដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងរដ្ឋបាលសាធារណៈពោល គឺមិនមែនដោយកិច្ចសន្យាឡើយ ព្រោះពួកគេត្រូវស្ថិតនៅក្រោមនីតិសាធារណៈ ដែលគ្រប់គ្រងមុខងារសាធារណៈ ពោលគឺ គេទទួលបានការឡើងឋានន្តរស័ក្តិថ្នាក់ទទួលមុខតំណែងបន្តបន្ទាប់រហូតដល់ចូលនិវត្តន៍ ។
- ប្រព័ន្ធនេះមានការធានាអាជីព និងការពារអាជីព ពោលគឺ ហាក់ដូចជាមានភាពអនុគ្រោះដល់មន្ត្រីរាជការគឺគេអាចស្ថិតនៅក្នុងក្របខ័ណ្ឌរបស់គេរហូតដល់ចូលនិវត្តន៍ ទោះបីគេពុំមានសមត្ថភាពវិជ្ជាជីវៈគ្រប់គ្រាន់សំរាប់ការងាររបស់គេក៏ដោយ ប្រព័ន្ធនេះក៏

ត្រូវបានអនុវត្តន៍នៅក្នុងបណ្តាប្រទេសមួយចំនួនដូចជាប្រទេសបារាំង អង់គ្លេស និងបណ្តាប្រទេសមួយចំនួននៅក្នុងអឺរ៉ុបខាងលិច និងអាហ្វ្រិចជាដើម។

សរុបមក តាមរយៈការបកស្រាយខាងលើនេះ យើងសង្កេតឃើញថាប្រទេសមួយចំនួនបានជ្រើសរើសយកប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធទាំងពីរជាមូលដ្ឋាន ហើយយកប្រព័ន្ធមួយទៀតសំរាប់អនុវត្តក្នុងករណីពិសេស ឬ លើប្រភេទមន្ត្រីមួយចំនួនតាមកាលៈទេសៈជាក់ស្តែងរបស់ប្រទេសគេដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងមុខងារសាធារណៈនៅក្នុងប្រទេស។ ដោយឡែកនៅបច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជាដោយផ្អែកតាមការអនុវត្តជាក់ស្តែងឆ្លងតាមរយៈការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈជាបន្តបន្ទាប់ៗ និងការអនុវត្តគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងមុខងារសាធារណៈ បើទោះបីជាប្រទេសកម្ពុជា យើងបានប្រកាន់យកប្រព័ន្ធវិជ្ជាជីវៈគ្របខ័ណ្ឌជាមូលដ្ឋានក៏ពិតមែន តែយើងក៏បានយកប្រកាន់យកការគ្រប់គ្រងតាមបែបប្រព័ន្ធនិយោជន៍មកអនុវត្តផងដែរ។ ចំពោះមន្ត្រីជាប់កិច្ចសន្យា ពលករអណ្តែតនិងអនុវត្តលើមន្ត្រីនៅ ក្នុងគម្រោងមួយចំនួនក្នុងការគ្រប់គ្រងប្រសិទ្ធភាព និងគណនេយ្យភាពការងារ។

### ១.២.៤. ប្រព័ន្ធគ្រប់គ្រងគុណផល

សម្តៅដល់ការប្រមូលផ្តុំនូវសមាសធាតុសំខាន់ៗដែលរៀបចំឡើងដើម្បីសម្រេចបាននូវគោលបំណងរួមរបស់ក្រសួងស្ថាប័នអង្គភាពក្រុមការងារ និងមន្ត្រីមានដូចជាការបង្កើតវត្ថុបំណង និងទិសដៅការងារ ការពិពណ៌នាមុខតំណែង ផែនការការងារប្រចាំឆ្នាំការព្រមព្រៀងអនុវត្តការងារប្រចាំឆ្នាំរបស់មន្ត្រីដែលទាំងអស់នេះជាការងារសំខាន់នៃការគ្រប់គ្រងការងារប្រចាំថ្ងៃ។ ប្រព័ន្ធគ្រប់គ្រងគុណផល មានការជាប់ទាក់ទងដោយផ្ទាល់ទៅនឹងដំណើរការនៃការគ្រប់គ្រងធនធានមនុស្ស ដូចជាការកំណត់ពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការគិតគូរលើការវិវត្តអាជីព[60]។

យោងតាមសុន្ទរកថារបស់ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាស្តីពី "យុទ្ធសាស្ត្រចតុកោណ "ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ នីតិកាលទី៣ នៃរដ្ឋសភានៅទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ "ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្សរួមមានយុត្តិ

[60] សាលាត្រាជ្ញ វាក្យស័ព្ទ ការគ្រប់គ្រងគុណផល ដកស្រង់ចេញពី ឧបសម្ព័ន្ធ៣ នៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥

សាស្ត្រចំនួន៤ គឺៈ ការលើកកម្ពស់ និងពង្រឹងគុណភាពនៃវិស័យអប់រំការ លើកស្ទួយសេវាសុខាភិបាល ការអនុវត្តន៍ គោលនយោបាយយេនឌ័ និងការអនុវត្តន៍គោលនយោបាយប្រជាជន”[61]។

ចំនែកឯផែនការសកម្មភាព គឺជាគោលការណ៍ ឬ ក្របខណ្ឌការងារសំរាប់ការដាក់ឱ្យដំណើរការនូវយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ។ លទ្ធផលដែលមានចំណងទាក់ទងគ្នាទៅវិញទៅមកលើ៥វិស័យត្រូវបានលើកយកមកបង្ហាញ ដើម្បីប្រមូលផ្តុំការខិតខំប្រឹងប្រែង ពុះពារសម្រេចឱ្យបានជោគជ័យ។

**ក. ការកែលម្អដល់ការផ្តល់សេវាសាធារណៈ**

ដើម្បីធ្វើឱ្យរដ្ឋបាលសាធារណៈក្លាយជាដៃគូអភិវឌ្ឍន៍គួរឱ្យទុកចិត្តបានគុណភាព និងការចូលទទួលយកសេវាត្រូវតែធ្វើការកែលម្អឱ្យបានឆាប់។ នៅចុងអាណត្តិ មុននេះមានការងារជាច្រើនដែលត្រូវបានគេមើលឃើញថាមានការរីកច្រើនគួរឱ្យកត់សម្គាល់ ជាពិសេសនៅតាមក្រសួងដែលទទួលបានថវិកាកម្មវិធីសកម្មភាពជាអាទិ៍ភាព ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងអប់រំ ក្រសួងអភិវឌ្ឍន៍ជនបទ និងនៅក្រសួងខ្វះទៀតដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាដើម [62]។

**ខ. ការបង្កើតបៀវត្សរ៍ និង និយោជក**

ការពង្រឹងប្រព័ន្ធលាភការ គឺជាបេះដូងនៃយុទ្ធសាស្ត្រសនិទានកម្មមុខងារសាធារណៈដែលត្រូវបានអនុវត្តមកដោយរាជរដ្ឋាភិបាលលនៅខែតុលា ឆ្នាំ២០០១។ បន្ទាប់ពីនោះមក ក្នុងក្របខ័ណ្ឌសារពើពន្ធរំពឹងទុក រាជរដ្ឋាភិបាលបានកំណត់ចេញនូវប្រព័ន្ធលាភការមួយ និងបានរិះរកវិធីសាស្ត្រល្អៗគ្រប់បែបយ៉ាងដើម្បីពន្លឿនដំណើរការរបស់ខ្លួន ដោយការរក្សាឱ្យបាននូវគោលការណ៍ស្នូលពីរចម្បង គឺ ធានាបាននូវតុល្យភាពក្នុងចំណោមស្ថាប័នរដ្ឋ និង និរន្តភាពនៃដំណើរការ [63]។

យុទ្ធសាស្ត្រចតុកោណដែលទើបបានអនុម័តដោយរាជវរដ្ឋាភិបាលថ្មីបានបញ្ជាក់ច្បាស់ថា រាជរដ្ឋាភិបាលនឹងបង្កើនប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការជាបណ្តើរៗឱ្យបានពី ១០% ទៅ ១៥% ក្នុងមួយឆ្នាំ ដើម្បីអោយពួកគេ មានជីវភាពរស់នៅសមរម្យនៅថ្ងៃអនាគត។ ការតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ គឺជាកិច្ចការដ៏ពិបាកបំផុតមួយ ជាពិសេសសំរាប់អ្នកទាំងឡាយណា ដែលរស់នៅតាមទីក្រុង និងទីប្រជុំជនធំៗឱ្យដល់កម្រិតមួយដែលអាចផ្គត់ផ្គង់ជីវភាពរស់នៅបានសមរម្យ។ លើសពី

---

[61] យោងតាមសុន្ទរកថារបស់ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាស្តីពី "យុទ្ធសាស្ត្រចតុកោណ" ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ នីតិកាលទី៣ នៃរដ្ឋសភានៅទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៤

[62] សាស្ត្រាចារ្យ កៅ មុយថង សៀវភៅ រដ្ឋបាលសាធារណៈទំនើប ឆ្នាំ ២០០៧ ទំព័រ ២៥០

[63] ដូចទី៣

នេះទៅទៀតការលំបាកដែលសឹងតែមិនអាចទប់ស្កាត់បាននោះគឺការហូរចេញនូវធនធានមនុស្សសំខាន់ៗ ពីផ្នែកសាធារណៈទៅវិស័យឯកជន ។

**គ. ការពង្រាយមន្ត្រីរាជការស៊ីវិល**

បៀវត្សរ៍ និងនិយោជនពីប្រៀបដូចជាផ្នែកទាងពីរនៃប្រាក់កាក់មួយ។ ការគ្រប់គ្រងនិយោជនដូចជាការធ្វើឱ្យប្រសើរឡើងនូវការរៀបចំរចនាសម្ព័ន្ធការងារ និង ការដាក់ពង្រាយមន្ត្រីរាជការទៅលើគោលនយោបាយ និងគោលបំណងរបស់កម្មវិធី។ យុទ្ធសាស្ត្រសនិទានកម្មមុខងារសាធារណៈដែលត្រូវបានអនុម័តរួចបាន និងកំពុងប្រឹងប្រែងរក្សាទំហំមន្ត្រីក្នុងមុខងារសាធារណៈជារួមក្នុងរង្វង់ ១៦៥០០០ នាក់រហូតដល់ឆ្នាំ ២០០៦ ហើយត្រូវសម្រួលបន្តិចបន្តួចសំដៅឆ្លើយតបបានតាមតម្រូវការអាទិ៍ភាពនានា ដែលជាគោលដៅចង់បាននៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។

**ឃ. ការពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងការត្រួតពិនិត្យ**

ប្រព័ន្ធមុខងារសាធារណៈនៅកម្ពុជាធ្វើតាមប្រព័ន្ធអាជីព។ ការងារពង្រឹងសមត្ថភាពក្នុងការធ្វើផែនការ ការគ្រប់គ្រង និងការត្រួតពិនិត្យ គឺជាគន្លឹះនៃការកែលម្អសេវាជូន ប្រជាពលរដ្ឋឱ្យបានជោគជ័យ ។ ក្នុងកំឡុងពេលប៉ុន្មានឆ្នាំមកនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងបណ្តាក្រសួងនានាបានធ្វើការកែទម្រង់ របៀបធ្វើការ និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរបស់ខ្លួនយ៉ាងច្រើន សមិទ្ធិផលនេះមានយ៉ាងច្រើនតាំងពីការបញ្ចប់កិច្ចការរៀបចំ លិខិតបទដ្ឋានគតិយុត្តរហូតដល់ការដាក់ឱ្យអនុវត្តរបបចំណាត់ថ្នាក់ថ្មី និងបៀវត្សរ៍ថ្មី ដែលមានផលប្រយោជន៍ច្រើនដល់ការជម្រុញឲ្យមានភាពល្អប្រសើរអាជីព និង ការអភិវឌ្ឍស្មារតីសាមគ្គីរួមក្រុម តាមរយៈការអភិវឌ្ឍន៍ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា តាមរយៈការធ្វើស្វ័យប្រវត្តិកម្មនៃបៀវត្ស៍ និងតាមរយៈការរៀបចំឡើងវិញនូវដំណើរការ តារាងទូទាត់បៀវត្សរ៍តាមប្រព័ន្ធព័ត៌មានវិទ្យា គ្រប់គ្រងធនធានមនុស្ស ដូចជា កិច្ចសន្យាការងារ ការតម្លើងការប្រាក់ ការតែងតាំងតម្លើងថ្នាក់ និង ជារបបសោធននិវត្តន៍ជាដើម។ល។

**ង.ការអភិវឌ្ឍនិសមត្ថភាព**

ការពង្រឹងសមត្ថភាពរបស់ស្ថាប័ន និងមន្ត្រីរាជការក្នុងជួររដ្ឋបាលសាធារណៈ គឺត្រូវគិតចាប់តាំងពីការគ្រប់គ្រងជំនួយអភិវឌ្ឍជាផ្លូវការ និងការគ្រប់គ្រងបុគ្គលហិរញ្ញវត្ថុកិច្ចរហូតដល់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ការសិក្សាថ្មីមួយទើបតែបានរៀបចំឡើងដោយក្រុមការងារស្តីពីការពង្រឹងសមត្ថភាពអនុវត្តការងារនៅកម្ពុជារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍបាន ពិនិត្យមើលអំពីស្ថានភាពលើវិស័យចំនួន ៥ ដែលមានផលប៉ះពាល់ ដោយផ្ទាល់លើសមត្ថភាព របស់មន្ត្រីរាជការ ដូចជា ការបណ្តុះបណ្តាល មធ្យោបាយ និងឧបករណ៍សំរាប់បំពេញការងារ ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ជំនួយ

បច្ចេកទេស និងការប្រើប្រាស់មន្ត្រីក្នុងស្រុក និងមន្ត្រីអន្តរជាតិ ។ កម្មវត្ថុនៃការពង្រឹងសមត្ថភាព គឺដើម្បីបង្កើនប្រសិទ្ធភាព និងការប្រតិបត្តិការងារក្នុងរដ្ឋបាលសាធារណៈឱ្យបានល្អប្រសើរក្នុងលក្ខខណ្ឌមួយសមស្រប និងប្រកបដោយនិរន្តភាព[64] ។

**ច. ការពង្រីកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង**

បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងអាចជាឧបករណ៍ដ៏មានឥទ្ធិពលសំរាប់កំណែទម្រង់ តាមរយៈការពង្រឹងសមត្ថភាព និងការកែប្រែបែបបទរបស់រដ្ឋាភិបាលក្នុងការផ្តល់សេវាសាធារណៈព្រមទាំងកំណត់ពីអ្វីដែលត្រូវធ្វើ។ បច្ចេកវិទ្យាព័ត៌មានដើរតួនាទីដ៏សំខាន់ក្រៃលែងស្ទើរតែរាប់មិនអស់គិតតាំងពីការងារសាមញ្ញក្នុងការបង្កើនប្រសិទ្ធភាពរហូតដល់ការប្រើប្រាស់បច្ចេកវិទ្យា ដែលនាំឱ្យប្រែប្រួលជាសារវន្តន៍នូវសារជាតិនៃការទំនាក់ទំនងរវាងរដ្ឋ និងអតិថិជនរបស់ខ្លួន។

នាពេលនេះបច្ចុប្បន្ន ការងារកំណែទម្រង់រដ្ឋបាលបានផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើត និង ការអនុវត្តប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមព័ត៌មានវិទ្យា និងការបង្កើនទំនាក់ទំនងតាមរយៈការចែកចាយព្រឹត្តិប័ត្រ និង ដាក់ឱ្យដំណើរការ website របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។ដូច្នេះហើយបានជាបច្ចេកវិទ្យាបានក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការប្រមូលផ្តុំទិន្នន័យស្ថិតិការផលិតទិន្នន័យ ដែលមានទំហំដូចជា៖ តារាងបៀវត្សរ៍ និង ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់[65]។

ជារួមមក ប្រព័ន្ធគ្រប់គ្រងគុណផលបានកំពុងដើរតួនាទីយ៉ាងសំខាន់ធ្វើយ៉ាងណាដើម្បីកែលម្អ និងជួយស្ថាបនាទាំងមន្ត្រី និងសេវាដែលជាកិច្ចក្នុងការសម្រេចឲ្យបាននូវការកែទម្រង់ក្នុងការគ្រប់គ្រងរដ្ឋបាលសាធារណៈ។

## ១.២.៥. ការធ្វើកំណែទម្រង់រដ្ឋបាលនៃការគ្រប់គ្រងឲ្យទៅជារដ្ឋបាលដែលមានលក្ខណៈបែបសហគ្រាស និងបែបសេដ្ឋកិច្ច

- **សហគ្រាសសាធារណៈ**

សហគ្រាសសាធារណៈគឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងវិស័យសាធារណៈទាំងក្នុងប្រទេសដែលកំពុងមានការរីកចំរើននិងប្រទេសដែលមានការរីកចម្រើន។ ទស្សនៈពីរត្រូវបានលើកឡើងក្នុងការសិក្សាអំពីសហគ្រាសសាធារណៈដែលជាផ្នែកនៃការគ្រប់គ្រងផ្នែកសាធារណៈ។ ទស្សនៈទីមួយគឺវិស័យសហគ្រាសសាធារណៈ គឺមានសារៈសខាន់ក្នុងការអះអាងនូវទំហំសកម្មភាពរបស់រដ្ឋភិបាលការពិភាក្សា និងលទ្ធផលនៃការធ្វើឯកជនភាវូបនីយកម្មទៅលើសហគ្រាសសាធារណៈ គឺមានការជាប់ជំពាក់ទៅនឹងសហគ្រាសសាធារណៈទាំងមូល។ ទស្សនៈទី ពីរ សហគ្រាសសាធារណៈបង្ក

[64] ដូចទី៣

[65] ដូចទី៣

ឡើងនូវបញ្ហាជាពិសេសការគ្រប់គ្រងបើមានការប្រៀបធៀបទៅនឹងការត្រួតពិនិត្យ និងគណនេយ្យភាពរបស់រដ្ឋាភិបាលក្នុងគោលដៅរកប្រាក់ចំណេញ។

ជាទូទៅសកម្មភាពសាធារណៈស្ថិតក្រោមបរិយាកាសប្រកួតប្រជែង និងក្រោមឥទ្ធិពលនៃតម្លៃទីផ្សារ។ សហគ្រាសសាធារណៈមាននីតិបុគ្គលភាព និងស្វ័យភាពហិរញ្ញវត្ថុហើយធ្វើសកម្មភាពតែលើផ្នែក ឧស្សាហកម្ម ឬ ពាណិជ្ជកម្មតែប៉ុណ្ណោះ។ សហគ្រាសសាធារណៈអនុវត្តគោលដៅក្រោមរូបភាពផលប្រយោជន៍រួមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងក្របខណ្ឌនេះសហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោម អាណាព្យាបាលរបស់រដ្ឋហើយអាចទទួលបុព្វសិទ្ធិនៃអំណាចសាធារណៈ។ គោលការណ៍នេះបាននាំឲ្យមានការបង្កើតច្បាប់សម្រាប់សហគ្រាសសាធារណៈដោយត្រូវគ្រោង អំពីបែបទដោយឡែកនៃការចាត់តាំង និងការត្រួតពិនិត្យ។

ជាក់ស្តែង សំរាប់ប្រទេសកម្ពុជាបានធ្វើការជ្រើសរើសយករបបសេដ្ឋកិច្ចទីផ្សារសេរី ទាំងរដ្ឋ និងឯកជនសុទ្ធតែអាចធ្វើការប្រកួតប្រជែងសេដ្ឋកិច្ច ក្នុងការប្រកបរបរបានពាណិជ្ជកម្ម។ ប៉ុន្តែទាំងរដ្ឋ ទាំងក្រុមហ៊ុនឯកជនត្រូវគោរពច្បាប់រួមមួយ ឬ តាមគោលការណ៍ និងនីតិក្រុមហ៊ុនពាណិជ្ជកម្មទូទៅ។

យោងតាមព្រះរាជក្រម ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ខែមិថុនាឆ្នាំ១៩៩៦ បានប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ ដែលសភាបានអនុម័តកាលពីថ្ងៃទី២២ ឆ្នាំ១៩៩៦ នាសម័យប្រជុំលើកទី៦ នីតិកាលទី១ បានបញ្ញត្តិថា សហគ្រាសសាធារណៈ សហគ្រាសសាធារណៈគឺជាសហគ្រាសដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ ឬភាគច្រើនជារបស់រដ្ឋ។ សហគ្រាសសាធារណៈត្រូវមានលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។ យ៉ាងណាមិញគេអាចធ្វើការសំគាល់បានផ្សេងទៀតថាសហគ្រាសសាធារណៈគឺមានលក្ខណៈស្វ័យភាពហិរញ្ញវត្ថុ។

សហគ្រាសសាធារណៈត្រូវមានកាតព្វកិច្ចផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរព្យាបាលនូវឯកសារដូចជា កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល ថវិកា សម្រាប់ការប្រព្រឹត្តទៅ និងការវិនិយោគ របាយការណ៍ស្តីពីសកម្មភាព និងគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធ និងរបាយបាយការណ៍ស្តីពីការត្រួតពិនិត្យគណនីនានា។

សហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច គឺជានីតិបុគ្គលនៃនីតិសាធារណៈ មានស្វ័យភាពហិរញ្ញវត្ថុ ដែលមានទំរង់ជាពទំម្រង់ដូចជា ទីមួយគ្រឹះស្ថានសាធារណៈដែលមាន លក្ខណៈសេដ្ឋកិច្ច ទីពីរក្រុមហ៊ុនរដ្ឋ (និងទីបីក្រុមហ៊ុនចម្រុះ ) ឯកជន និង រដ្ឋ ហើយដែលរដ្ឋត្រូវមានភាគហ៊ុនលើស ពី ៥១ ភាគរយនៃដើមទុនសរុប ។

**១. គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច**

គ្រឹះសាធារណៈនេះជានីតិបុគ្គលដែលមានលក្ខន្តិកៈគតិយុត្តចំរុះ គឺមានបុព្វសិទ្ធិសាធារណៈផង ដែលស្ថិតនៅក្រោមនីតិសាធារណៈ មានកម្មវត្ថុធ្វើឧស្សាហកម្ម និងពាណិជ្ជកម្មផង ដែលស្ថិតនៅក្រោមនីតិឯកជន។ គ្រឹះស្ថានសាធារណៈជាលក្ខណៈសេដ្ឋកិច្ច ស្ថិតនៅក្នុងសណ្ឋានដូចតទៅៈ មានសម្មភាពជាលក្ខណៈសេដ្ឋកិច្ចដែលការងារតំរូវឲ្យប្រើបុព្វសិទ្ធនៃអំណាចសាធារណៈ។ មានសកម្មភាពជាលក្ខណៈសេដ្ឋកិច្ចដែលត្រូវមានទំនាក់ទំនងជាមួយសកម្មភាពរដ្ឋបាល និងមានបេសកម្មសម្រួលសកម្មភាពសេដ្ឋកិច្ច និងជីវភាពសង្គម។

ការបង្កើត ឬ ការលុបចោល គេអាចធ្វើបានដូចវិធានគ្រឹះស្ថានសាធារណៈដែរ គឺដោយច្បាប់ ក្រម និងអនុក្រឹត្យ ។ដោយយោងតាមព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈមាត្រា៣ "សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ។ សហគ្រាសមានបេសកកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច" ...។

**២. ក្រុមហ៊ុនរដ្ឋ**

ក្រុមហ៊ុនរដ្ឋដែលមូលធនកាន់កាប់ដោយរដ្ឋ អាចចាត់ចូលក្នុងប្រភេទ សកម្មភាពសេដ្ឋកិច្ច ហើយ ដែលរដ្ឋចង់រក្សាទុកទាំងស្រុង និងមិនស្ថិតក្នុងលក្ខណៈវិនិច្ឆ័យនៃ គ.ស.ស ទេ។

**៣. ក្រុមហ៊ុនចំរុះ**

ក្រុមហ៊ុនចំរុះដែលនៅក្នុងនោះ ភាគកម្មសាធារណៈមានចំនួនស្មើ ឬលើសពី ៥១ %នៃដើមទុនរបស់ ក្រុនហ៊ុន ឬសិទ្ធិបោះឆ្នោត។ ភាគកម្មសាធារណៈត្រូវបានកំណត់ជាភាគហ៊ុន ដែលបានចូលដោយឡែកពីគ្នា ឬ រួមគ្នាដោយ ឡែកពីគ្នាដោយរដ្ឋ គ.ស.សក្រ.រ ឬ អង្គការសាធារណៈផ្សេងទៀតដែលមាននីតិបុគ្គលភាពគតិយុត្ត។

ជារួមមកសហគ្រាសសាធារណៈដែលមានទម្រង់ជាគ្រឹះស្ថានធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ជាក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនចំរុះរដ្ឋដែលក្នុងនោះ រដ្ឋកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលលើសពី ៥១%នៃដើមទុកក្រុមហ៊ុន ឬ សិទ្ធិបោះឆ្នោត និងត្រូវអនុលោមតាមគោលការណ៍ និងទៅតាមបែបបទទាំងឡាយ នៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ដូចក្រុមហ៊ុនឯកជនដទៃទៀតដែរ ។ លើសពីនេះប្រសិនបើមិនមានច្បាប់ពិសេសចែកទេ សហគ្រាសសាធារណៈត្រូវស្ថិតនៅក្រោមរបបនីតិរួមចំពោះពន្ធ និងអាករ ។

## ផ្នែកទី ៣ គោលការណ៍នៃការចូលរួមរបស់អ្នកប្រើប្រាស់សេវាសាធារណៈ

ការចូលរួមរបស់អ្នកប្រើប្រាស់សេវា គឺជាកត្តាសំខាន់ ក្នុងដំណើរការរបស់សេវាសាធារណៈ បើគ្មានអ្នកចូលរួមក្នុងសេវាសាធារណៈទេនោះសេវាសាធារណៈ និងមិនមានការរីកចម្រើនទៅមុខឡើយ។ ការចូលរួមនេះធ្វើឲ្យមានការអភិវឌ្ឍ និងប្រកបដោយនិរន្តភាព ហើយយើងត្រូវធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋមានាការចូលពេញលេញព្រោះប្រជាពលរដ្ឋជាអ្នកទទួលយកសេវា ដែលមន្ត្រីរាជការជាអ្នកបំពេញតួនាទីរបស់ខ្លួន។ ការចូលរួមរបស់ប្រជាពលរដ្ឋនោះរួមមានទាំងពីការតាក់តែងគោលនយោបាយសាធារណៈ ការអនុវត្តកម្មវិធី ការតាមដាន និងការត្រួតពិនិត្យ។ ការចូលរួមនេះពាក់ព័ន្ធ និងការសម្រេចក្នុងការតាក់តែងគោលនយោបាយសេវាសាធារណៈ ឬជួនកាលជាងនេះទៅទៀតអាចចូលរួមជាសកម្មភាពសាធារណៈ។

ការចូលរួម គឺជាការបញ្ចូលគំនិតនៃលិទ្ធិប្រជាធិបតេយ្យ ក្នុងប្រព័ន្ធរដ្ឋបាល។ គោលការណ៍មានចរិក លក្ខណៈក្នុងការទាមទារតម្លាភាព គណនេយ្យភាព និងសុច្ចរិតភាព របស់មន្ត្រីរាជការក្នុងការអនុវត្តម្មវិធី និងគោលនយោបាយដែលពាក់ព័ន្ធនឹងការផ្តល់សេវាជូនរាស្ត្រប្រជា។ ការចូលរួមរបស់អ្នកប្រើប្រាស់សេវា មានធាតុចូលរួមជាច្រើនក្នុងគោលបំណងកែលម្អ ដូចជា ការរិះគន់ សំណូមពរ ការចូលរួមពីអង្គការ ការធ្វើសមាជជាតិជាដើម។

### ១.៣.១. ការរិះគន់

ការរិះគន់ជាកត្តាចាំបាច់ដែលខ្វះមិនក្នុងការចូលរួមកែតម្រូវ ដើម្បីធ្វើឲ្យមានផ្លាស់ប្តូរនូវចំណុចអវិជ្ជមាន។ ការរិះគន់ភាគច្រើនត្រូវទទួលយកពីសំណាក់អ្នកប្រើប្រាស់ គឺប្រជាជន ព្រោះប្រជាជនជាអ្នកដែលប្រើប្រាស់ផ្ទាល់។ ការរិះត្រូវបានសម្តៅទៅលើបញ្ហា ដែលត្រូវចែកជា បី គឺ[៦៦] ៖

ទី១ ៖ មានចំនួនច្រើនក្នុងវិស័យសេវាសាធារណៈ ដែលធ្វើឲ្យមានការចំណាយហួសហេតុដែលត្រូវឲ្យអ្នកគ្រប់គ្រងសេវាមានការកាត់បន្ថយចំណាយដែលឥតប្រយោជន៍មួយចំនួន។ ដែលបញ្ហាទាំងអស់នេះត្រូវបានកើតឡើងនៅបណ្តាប្រទេសមួយចំនួនរួចមកហើយ ដូចជាប្រទេសអង់គ្លេស អាឡឺម៉ង់ ជាដើម។

ទី២ ៖ បញ្ហាវិសាលភាពរបស់អ្នកនយោបាយគ្រប់ដណ្តប់ដោយការគ្រប់គ្រងសេវាសាធារណៈរបស់មន្ត្រីរាជការក្នុងការផ្តល់សេវា ធ្វើឲ្យមានគ្មានតម្លាភាព និងមានអំពើពុករលួយកើតឡើង ។

ទី៣ ៖ ការរិះគន់ទៅលើគោលនយោបាយរបស់រដ្ឋាភិបាលដែលបានដាក់ឲ្យអនុវត្តន៍ ដែលការអនុវត្តភាគច្រើនមានតែលទ្ធផល តែគ្មានប្រសិទ្ធភាព។

[៦៦] សៀវភៅ រដ្ឋបាលសម័យទំនើប សាស្ត្រាចារ្យ កៅ មុយចង ទំព័រ ៧៥ ឆ្នាំ ២០០៧

ការផ្លាស់ប្តូរសេវាសាធារណៈ ត្រូវបានគេជឿជាក់ថាមានការពាក់ព័ន្ធនឹងនយោបាយ ឬ គណបក្សនយោបាយ ដែលឈ្នះឆ្នោតហើយការជ្រើសរើសមន្ត្រីក្នុងការផ្តល់សេវា គឺជាមន្ត្រីដែលស្មោះត្រង់នឹងគណបក្ស។ ដូច្នេះក្នុងប្រការដដែលនិយាយខាងលើវាបានប្រាសចាក និងគោលការណ៍បែបបុរាណដែលមានវត្ថុបំណងក្នុងការញែកឲ្យដាច់រវាងអំណាចនយោបាយ និងអំណាចរដ្ឋបាល។

### ១.៣.២. ការបង្កើតអង្គការ ឬ សមាគម

ការបង្កើតឲ្យមានការចូលរួមរបស់អង្គការ ឬ សមាគមរបស់ប្រជាជននៅតាមតំបន់នីមួយៗជារឿងដែលសំខាន់ និងជារឿងដែលចាំបាច់ដែរត្រូវតែធ្វើក្នុងការជួយពន្លឿនដល់ការផ្តល់សេវាឲ្យដល់ប្រជាកាន់តែ និងជួយបំពេញភាពខ្វះចន្លោះនៃការផ្តល់សេវារបស់មន្ត្រីរាជការ។ ក្នុងសង្គមប្រជាធិបតេយ្យលើកកម្ពស់ឲ្យមានការចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាល ( NGO ) និងសមាគមផ្សេងៗ។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤២ បានចែងថា[67] ៖

ប្រជាពលរដ្ឋខ្មែរមានសិទ្ធបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការ មហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផលជាតិ និងសណ្តាប់ធ្នាប់សង្គម។

ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រះរាជក្រម នស/រកម/ ០៨១៥/០១០ ចុះថ្ងៃទី ១២ សីហា ឆ្នាំ ២០១៥ [68]។

### ១.៣.៣. ការចូលរួមរបស់អ្នកប្រើប្រាស់សេវាសាធារណៈ

ការចូលរួមនេះសំដៅដល់ការចូររួមរបស់អ្នកប្រើប្រាស់ផ្ទាល់ពីសំណាក់ប្រជាជនដែលជាអ្នកទទួល បាននូវរាល់សេវា ដែលមន្ត្រីរាជការជាអ្នកផ្តល់សេវា ដូច្នេះហើយការចូលរួមពីសំណាក់ប្រជាជនពិតជាមានសារៈសំខាន់។ គោលគំនិតរបស់ប្រទេសប្រជាធិបតេយ្យយកប្រជាជនជាធំដូច្នេះរាល់ការសម្រេចបានសមិទ្ធិផលរបស់ជាតិត្រូវមានការចូលរួមរបស់ប្រជាជន ដែលការចូលរួមនោះគេហៅថា សមាជជាតិ។ ការធ្វើសមាជជាតិត្រូវបានផ្តល់ឪកាសឲ្យប្រជាជនបានចូលរួមក្នុងការពិភាក្សាកិច្ចការរបស់ប្រទេសជាតិ ជាពិសេសជាអ្នកដែលតាមដាន ត្រួតពិនិត្យរាល់ដំណើរការ និងសកម្មភាពរបស់មន្ត្រីជាអ្នកផ្តល់សេវា ហើយមានតែការចូលរួមរបស់ប្រជពលរដ្ឋ ដែលធ្វើឲ្យមាន

[67] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤២

[68] ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រះរាជក្រម នស/រកម/ ០៨១៥/០១០ ចុះថ្ងៃទី ១២ សីហា ឆ្នាំ ២០១៥

តម្លាភាព និងសុក្រឹត្យភាពក្នុងការវាយតម្លៃរួម ។ ការចូលរួមក្នុងសេវាសាធារណៈត្រូវបានធានាធ្វើយ៉ាងណាឲ្យសេវាដែលផ្ដល់ជូនប្រជាជនមាន តម្លាភាព និងគុណភាព ដើម្បីឲ្យបាននូវវត្ថុបំណងដូចដែលបានរៀបរាប់ យើងត្រូវមានការចូលរួមយ៉ាង ហើយការចូលរួមនោះវាមានសម្ដែងចេញច្រើនរូបភាព ដូចជា ៖

– ពេលខ្លះការចូលរួមរបស់អ្នកប្រើប្រាស់អាចធ្វើឡើងតាមរយៈការរើសតំណាង ដើម្បីចូលរួមក្នុងការដោះស្រាយបញ្ហាផ្សេងៗ។ ដោយអ្នកតំណាងធ្វើការជួបប្រជុំពិគ្រោះយោបល់ ការផ្លាស់ប្ដូរយោបល់គ្នាទៅវិញទៅមក ដើម្បីជាគុណប្រយោជន៍សាធារណៈ។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៣៤ វាក្យខ័ណ្ឌ ៣ បានចែងថា ៖ ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំអាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសជាតំណាងរាស្ត្រ [69]។

– ការសរសេរជាលាយលក្ខអក្សរ ក្នុងការសំដែងការមិនពេញចិត្តទៅលើស្ថាប័ន ឬអង្គភាពដែលបានផ្ដល់សេវាសាធារណៈ ឬ មួយក៏សម្ដែងការមិនចិត្ត និងផ្ដល់ជាមតិយោបល់ ក្នុងការកែតម្រូវទៅលើអ្វីមួយដែលគិតថាវាមានផលប៉ះពាល់ ឬ សកម្មភាពនោះមិនបានបម្រើដល់ផលប្រយោជន៍សាធារណៈ។ ដោយការសរសេរជាលាយលក្ខអក្សរត្រូវបានដាក់ ជូនឧត្តមក្រុមប្រឹក្សាពិគ្រោះយោបល់ ឬក៏ ក្រុមប្រឹក្សាវិន័យក្នុងការត្រួតពិនិត្យមើលលើករណីមិនប្រក្រតីណាមួយ ។

– ក្នុងការចូលរួមរបស់អ្នកប្រើប្រាស់អាចមានលក្ខណៈជាបណ្ដឹង ក្នុងប្ដឹងទៅលើករណីខ្លះដែលគិតថាវាប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍សាធារណៈ ។ ការប្ដឹងនេះអាចធ្វើជាលក្ខណៈនៃរូបវន្តបុគ្គល ឬក៏ ជាបណ្ដុំនៃរូបវ័ន្តបុគ្គល ។ ការប្ដឹងអាចតាមរយៈ សហជីព អង្គការ សមាគម និងយន្តច្បាប់ផ្សេងៗ ដែលមានចែង ។

**ឧទាហរណ៍ ៖** អាជ្ញាធរអគ្គីសនីកម្ពុជា មានភារកិច្ចក្នុងការផ្គត់ផ្គង់អគ្គីសនីជូនប្រជាជន ឬអ្នកប្រើប្រាស់។ អគ្គីសនីកម្ពុជាមានភារកិច្ចក្នុងការផ្ដល់សេវាក្នុងការចែកចាយចរន្ត និងធានឲ្យបាននូវគុណភាព និងតម្លាភាពនៃចរន្តអគ្គីសនី ការកំណត់តម្លៃជាមូលដ្ឋាន ។ អគ្គីសនីកម្ពុជាបានបើកទូលាយក្នុងការទទួលពាក្យបណ្ដឹងពីសំណាក់អ្នកប្រើប្រាស់សេវា ដែលបានដែលមានអាជ្ញាប័ណ្ណដែលសមស្របទៅច្បាប់ និងបទដ្ឋានគតិយុត្តដែលមានចែង។

[69] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៤ ( វាក្យខ័ណ្ឌ ៣ )

យោងតាមព្រះរាជក្រមលេខ នស/រកម/ ០២០១/០៣ ច្បាប់ស្តីពី អគ្គីសនីនៃព្រះរាជាណាចក្រកម្ពុជា[70]៖

មាត្រា ៣ ៖ ការរៀបចំ និងគ្រប់គ្រងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាលលើវិស័យអគ្គីសនី ជាសមត្ថកិច្ចទទួលខុសត្រូវទូទៅរបស់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

ការធានាឲ្យការផ្តល់សេវាកម្មអគ្គីសនី និងការប្រើប្រាស់អគ្គីសនី ប្រព្រឹត្តទៅដោយប្រសិទ្ធភាព គុណភាព និងតម្លាភាព ជាសមត្ថកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរអគ្គីសនីកម្ពុជា។

មាត្រា ២៥ ៖ អាជ្ញាធរអគ្គីសនីកម្ពុជា ត្រូវទទួលខុសចំពោះផលវិបាកដែលកើតឡើង ដោយការបំពេញភារកិច្ចរបស់សមាជិក ឬ មន្ត្រីរបស់ខ្លួនក្នុងក្របខ័ណ្ឌសមត្ថកិច្ចស្របច្បាប់នេះ ព្រមទាំងអនុក្រឹត្យ និងបញ្ញត្តិនានាសម្រាប់អនុវត្តច្បាប់នេះ។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៩ បានចែងថា ៖ ប្រជាពលរដ្ឋខ្មែរមានសិទ្ធប្តឹងបរិហា ប្តឹងតវ៉ា ឬ ប្តឹងទារសំណង ជូលជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរបស់រដ្ឋរបស់អង្គការសង្គម និងបុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលកាខូចខាតជាមួយសមត្ថកិច្ចតុលាការ[71] ។

– ការធ្វើប្រជាមតិ ឬការធ្វើរបាយការណ៍ស្រាវជ្រាវផ្សេងដែលជាគោលគំនិតចម្បងក្នុងការធ្វើឲ្យមានតម្លាភាព និងគុណភាពរបស់សេវាសាធារណៈដែលបានផ្តល់ទៅឲ្យប្រជាជន។ ការធ្វើប្រជាមតិនេះត្រូវបានបានអនុវត្តន៍ជតាំងពីសម័យអាណានិគម មកម្ល៉េះ។

យោងតាមរដ្ឋធុនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ១៤ ថ្មី អំពី សមាជជាតិ មាត្រា ១៤៧ ថ្មី ដល់ មាត្រា ១៤៩ ថ្មី ។

មាត្រា ១៤៧ ថ្មី ( មាត្រា ១២៨ ចាស់ ) បានចែងថា ៖ សមាជជាតិ បើកឲ្យប្រជារាស្ត្រដោយផ្ទាល់អំពីកិច្ចការផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទ មានសិទ្ធក្នុងសមាជជាតិ [72]។

[70] ព្រះរាជក្រមលេខ នស/រកម/ ០២០១/០៣ ច្បាប់ស្តីពី អគ្គីសនីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១

[71] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៩

[72] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៤៧ ថ្មី ( មាត្រា ១២៨ ចាស់ )

## ផ្នែកទី ៤ ៖ បញ្ហាប្រឈមរបស់មន្ត្រីរាជការក្នុងការគ្រប់គ្រងសេវាសាធារណៈ

### ១. ការផ្តល់សេវាមានលក្ខណៈយឺតយ៉ាវ

ផ្តល់សេវាឲ្យទាន់ពេលវេលាដល់ប្រជាជនពិតជារឿងដែលសំខាន់សម្រាប់ជីវភាព និងការប្រកបរបរប្រចាំថ្ងៃ។ ក្នុងសកម្មភាពរបស់មន្ត្រីរាជការសព្វថ្ងៃមានការយឺតយ៉ាវខ្លាំងក្នុងការបំពេញ និងផ្តល់សេវាជូនប្រជារាស្ត្រឲ្យទាន់ពេលវេលា។ កត្តានេះបណ្តាលមកពីភាពសកម្មរបស់មន្ត្រីក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន ដែលតែងគេចវេសពីការងារ ការចំណាយពេលវេលាយូរក្នុងការបំពេញបទដ្ឋានគតិយុត្តនានា ដែលជាហេតុនាំឲ្យរាំងស្ទះដល់ដំណើរការប្រព្រឹត្តកិច្ចការផ្សេងៗ។

ចំពោះសេវាសាធារណៈវិញក៏មានការការយឺតយ៉ាវផងដែរ និងមានភាពខ្វះចន្លោះក្នុងបំពេញតម្រូវការរបស់រាស្ត្រប្រជា។ សេវាសាធារណៈខ្លះមានតែបទបញ្ញត្តិចែង ប៉ុន្តែចំពោះប្រសិទ្ធភាព និងប្រសិទ្ធផលគឺគ្មានតុល្យភាពរវាងគ្នា។

### ២. អំណាចចៅហ្វាយ ( មេ )មានវិសាលភាពធំធេង

ចំពោះមន្ត្រីរាជការ តែងតែឈរលើលគោលការណ៍មេជាធំ និងអនុវត្តទៅតាមការណែនាំបញ្ជាពីថ្នាក់លើ ទោះបីជាមានបញ្ញត្តិច្បាប់ចែងក៏ដោយ ដោយហេតុមន្ត្រីបំពេញការងារដើម្បីតម្រូវចិត្តចៅហ្វាយនាយ ឬ មេ។

ចំពោះសេវាសាធារណៈវិញ ដោយមន្ត្រីរាជការជាអ្នកផ្តល់ និងអនុវត្តទៅលើកម្មវិធីនៃសេវាដោយមន្ត្រីរាជការ ដោយហេតុនេះធ្វើឲ្យសេវាដែលបានដាក់បំរើដល់ប្រជារាស្ត្រ មិនសូវមានប្រសិទ្ធ និងសេវាសាធារណៈពុំសូវមានវិសាសភាពធំទូលាយសម្រាប់បំរើប្រជារាស្រ។

### ៣. ការអនុវត្តរបស់មន្ត្រីមានលក្ខណៈបុរាណទាំងការគ្រប់គ្រងមន្ត្រី និងការផ្តល់សេវា

ការអនុវត្តរបស់មន្ត្រីរាជការនូវមានលក្ខណៈបុរាណដោយហេតុថា ៖

ចំពោះមន្ត្រីរាការមានលក្ខណៈបុរាណ ព្រោះមន្ត្រីរាជការនៅតែបន្តអនុវត្តទៅតាមទំនៀមទម្លាប់ដែលធ្វើឲ្យផ្នត់គំនិរបស់មន្ត្រីរាជការនៅមានលក្ខណៈចាស់កម្រិល ក្នុងការអនុវត្តដោយមន្ត្រីរាជការពុំសូវទទួលយកការរិះគន់ និងគំនិតយោបល់ថ្មីៗទេ ហើយគេតែឈរលើគោលគំនិត "អញនិយម"។ ការទទួលព័ត៌មាននៅមានកម្រិតរបស់មន្ត្រី ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក៏នៅមានកម្រិតទាបនៅឡើយ។ ជាពិសេសការគ្រប់ទៅលើប្រសិទ្ធភាពការងាររបស់មន្ត្រីរាជការក្នុងការផ្តល់សេវា និងបំពេញតួនាទីរបស់ខ្លួននៅមានភាពខ្វះចន្លោះ ។

ចំពោះសេវាសាធារណៈវិញក៏មានលក្ខណៈចាស់កម្រិលផងដែរ ដោយសារសេវាខ្លះពុំសូវបានសិក្សាឲ្យបានច្បាស់លាស់ ផ្អែកតាមទំនៀមទម្លាប់ និងមិនសូវត្រូវចំគោលដៅនៃតម្រូវការ។ កង្វះខាតការទទួលព័ត៌មានពីសេវាជូនប្រជាជននៅមានកម្រិតទាបនៅឡើយ។

## ៤. ទំនួលខុសត្រូវរបស់មន្ត្រីរាជការក្នុងតួនាទី និងការផ្តល់សេវានៅមិនទាន់ទទួលយក

ការមានទំនួលខុសត្រូវគឺជាការចាំបាច់របស់មន្ត្រីរាជការក្នុងការអនុវត្ត និងការផ្តល់សេវាជូនប្រជារាស្ត្រ។ ដោយប្រទេសកម្ពុជាបានយកប្រព័ន្ធអាជីពក្នុងការគ្រប់គ្រងមន្ត្រី។ ដូច្នេះបានជាមន្ត្រីរាជការមួយចំនួនមិនសូវយកចិត្តទុកដាក់ទៅលើការបំពេញការងាររបស់ខ្លួន ដោយធ្វើការមានការធ្វេសប្រហែសលើកិច្ចការងាររបស់ខ្លួនច្រើន។ កត្តានៃការគ្រប់គ្រងនេះបានធ្វើឲ្យមន្ត្រីរាជការដែលមានភារកិច្ចក្នុងការផ្តល់សេវា ដោយពេលខ្លះប្រព្រឹត្តខុសឆ្គង ឬក៏ ប្រាសចាក់ទៅនឹងវិធាននៃច្បាប់ មន្ត្រីរាជការទាំងនោះតែងតែគេចវេសនឹងកំហុសរបស់ខ្លួន មិនប្រឈមមុខការពិត ដោយសំអាងខ្លួនជាមន្ត្រីធ្វើអ្វីក៏ត្រឹមត្រូវ ។

## ៥. តម្លាភាពរបស់មន្ត្រីរាជការ ចំពោះការគ្រប់គ្រងសេវាមានកម្រិតទាប

កត្តាតម្លាភាពនៃមន្ត្រីរាជការក្នុងប្រកបវិជ្ជាជីវៈរបស់ខ្លួន ក៏ដូចការផ្តល់សេវាសាធារណៈគឺជារឿងចាំបាច់ក៏ត្រូវតែមាន។ កង្វះខាតតម្លាភាពនៅតែមានដែលបង្កើតឲ្យមានអំពុករលួយក្នុងវិស័យសាធារណៈ ជាងនេះវាធ្វើឲ្យជំនឿទុកចិត្តរបស់ប្រជាជនទៅលើសេវាសាធារៈកាន់អន់ថយ និងជាចុងបញ្ចប់ធ្វើសេវាសាធារណៈគ្មានប្រសិទ្ធភាព សម្រេចមិនបានគោលដៅ និងមានភាពមិនប្រក្រតីជាច្រើនកើតឡើង។

## ផ្នែកទី៥ ដំណោះស្រាយលើបញ្ហាប្រឈមនៃសេវាសាធារណៈ

ក្រោយពីបានស្វែងយល់អំពីបញ្ហាប្រឈមសំខាន់ៗនៅក្នុងស្ថានភាពសង្គមសព្វថ្ងៃរួមមក ដែលនេះបានឆ្លុះបញ្ចាំងអោយឃើញពីភាពចាំបាច់នូវការរិះរកវិធានការ រឺ ដំណោះស្រាយដែលសមស្របត្រឹមត្រូវ និងច្បាស់លាស់ដើម្បីធ្វើការឆ្លើយតបអោយមានប្រសិទ្ធភាព និង ទាន់ពេលវេលា។ ដំណោះស្រាយដែលនិងត្រូវយកមកធ្វើការត្រិះរិះពិចារណាដែលនិងត្រូវធ្វើការផ្អែកសំខាន់និងជាចំបងទៅលើបទដ្ឋានគតិយុត្តមួយចំនួនដែលត្រូវបានបង្កើត និងកែសម្រួលជាបន្តបន្ទាប់ ដើម្បីសម្រេចឲ្យមាននូវកំណែទម្រង់របស់រដ្ឋាភិបាល អោយមានភាពស៊ីជម្រៅ និងប្រសិទ្ធផលខ្ពស់ដូចដែលបានគ្រោងទុក។

- ដំណោះស្រាយដោយផ្អែកតាមតថភាពច្បាប់ និងលិខិតគតិយុត្តនានា ដំណោះស្រាយជាក់លាក់ក្នុងការដំណោះស្រាយទៅលើបញ្ហាប្រឈមរបស់មន្ត្រីក្នុងការគ្រប់គ្រង សេវាដែលនិងត្រូវយកការយកចិត្តទុកដាក់ទៅលើ

- មន្ត្រីត្រូវធ្វើការសុំច្បាប់ មានមូលហេតុត្រឹមត្រូវ និងមានការអនុញ្ញាតពីថ្នាក់លើរបស់ខ្លួនដើម្បីបញ្ចៀសនូវការគេចវេសមិនបំពេញតួនាទីក្នុងការផ្តល់សេវា និងជំនួសដោយភាពទៀងទាត់[73]
- គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈត្រូវបំពេញមុខងារ ដែលបានកំណត់ និងបានចែង ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈអោយបានខ្ជាប់ខ្ជួន និងដើម្បីបង្កើនភាពសកម្មក្នុងការសម្រេចភារកិច្ច ដែលអាចបង្កើតគណៈកម្មាធិការ ឬ ក្រុមបច្ចេកទេសដើម្បីធ្វើការដឹកនាំការកែទម្រង់តាមវិស័យនីមួយៗ[74]
- រៀបចំក្របខណ្ឌមន្ត្រីរាជការស៊ីវិលនៅក្រោមឪវាទដោយកំណត់ច្បាស់លាស់នូវមន្ត្រីដែលស្ថិតនៅក្រោមក្របខណ្ឌ[75] កំណត់អោយច្បាស់លាស់នូវមន្ត្រីដែលបិតនៅក្នុងឋានន្តរសក្តិនីមួយៗ
- បង្កើតនូវ វគ្គបណ្តុះបណ្តាល អំពីការកែលម្អ និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដែលអនុវត្តនៅក្នុងរដ្ឋបាលសាធារណៈ និងជាស្នូលនៃយុទ្ធសាស្ត្រចតុកោណនិងផែនការ

[73] ដូចទី ១ មាត្រា ៣៤

[74] អនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មាត្រា៥ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៨

[75] សារាចរណែនាំលេខ ០២ សរណន របស់រាជរដ្ឋាភិបាល ស្តីពី កំណត់ក្របខណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក ចំនុច១ ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០០៤

អភិវឌ្ឍជាតិ ផ្តល់ការបំប៉នដល់មន្ត្រីដោយបង្កើតនូវសិក្ខាសិលាស្តីពីការអភិវឌ្ឍសមត្ថភាព មន្ត្រីរាជការនៅកម្ពុជា លើប្រធានបទ (ការគ្រប់គ្រងវដ្តនៃគម្រោង និងវិធីសាស្ត្ររៀបចំករណីសិក្សា) ដើម្បីធ្វើការឆ្លើយតបទៅរដ្ឋបាលសាធារណៈឲ្យកាន់តែមានតម្លាភាព ភាពឆ្លើយតបប្រសិទ្ធ និង លើកកម្ពស់ឆន្ទៈម្ចាស់ការ ភក្តីភាពមនសិការវិជ្ជាជីវៈ និងវប្បធម៌ សេវាសាធារណៈ[76]

- ធ្វើការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលជាកំណែទម្រង់អភិបាលកិច្ចល្អដែលសម្រាប់
    - ថ្នាក់ជាតិ: ច្បាប់និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលសម្រាប់ថ្នាក់ជាតិត្រូវពង្រឹង យន្តការនៅក្នុងស្ថាប័នខ្លួនក្រោមការដឹកនាំ និង ការទទួលខុសត្រូវ ដោយផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងនីមួយៗ
    - ថ្នាក់ក្រោមជាតិ: ថ្នាក់ក្រោមជាតិដែលត្រូវរៀបចំបង្កើតនូវ គណៈកម្មាការដឹកនាំការងារកំណែទម្រង់ដើម្បីដឹកនាំសម្របសម្រួលកិច្ចដំណើរការជាទូទៅនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន[77]។
- ការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតម្រូវអោយមានការចូលរួមពីប្រជាពលរដ្ឋផ្ទាល់ដើម្បីសម្រេចឲ្យបានអភិបាលកិច្ចល្អ[78]
- លើកកម្ពស់ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការប្រើប្រាស់នូវសិទ្ធអំណាចសម្រាប់អនុវត្តមុខងារ ដូចជាសំដៅលើការអភិវឌ្ឍមូលដ្ឋាន ប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងសមធម៌ ដើម្បីឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន[79]។
- បន្តពង្រឹងការអនុវត្តនូវកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨[80] ដែលរួមមានជាយុត្តិសាស្ត្រ

[76] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ព្រឹត្តិបត្តិព័ត៌មាន ឆ្នាំទី ៧ លេខ ០៣៧ ចុះខែ វិច្ឆិកា ធ្នូ ២០១០ សម្រង់ប្រសាសន៍ អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជាពាក់ព័ន្ធនិងការងារកំណែទម្រង់រដ្ឋបាល

[77] សេចក្តីណែនាំ លេខ ០២ សណន ស្តីពីការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៨

[78] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ស្តីពីកំណែទម្រង់វិមជ្ឈការនិង វិសហមជ្ឈការតម្រូវអោយមានការចូលរួម ពីប្រជាពលរដ្ឋដើម្បីអភិវឌ្ឍមូលដ្ឋាន ថ្ងៃទី ៣ ធ្នូ ឆ្នាំ ២០១៨

[79] ដូចទី

[80] រាជរដ្ឋាភិបាលកម្ពុជាគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានទទួលពីគណៈរដ្ឋមន្ត្រីក្នុងសម័យអង្គប្រជុំពេញអង្គ ស្តីពីកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នាថ្ងៃទី ៩ មករា ២០១៥

- o សម្រាប់សេវាសាធារណៈ ជុំរុញអោយមានការផ្លាស់ប្តូរទស្សនៈទានក្នុងក្របខ័ណ្ឌនៃការផ្តល់សេវាសាធារណៈ របស់មន្ត្រីរាជការពីអ្នកគ្រប់គ្រងទៅជាអ្នកផ្តល់សេវា និងផ្តល់តម្លៃ ដល់អ្នកប្រើប្រាស់សេវា និង ជម្រុញអោយមានការកែទម្រង់របៀបរបបរចនាសម្ព័ន្ធការងារ ទៅជារចនាសម្ព័នប្រតិបត្តិ
- o សំរាប់ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ធ្វើអោយប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងគុណផលលើកកម្ពស់ គុណភាពនៃការបណ្តុះបណ្តាល
- o សំរាប់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភ រៀបចំប្រព័ន្ធចំណាត់ថ្នាក់ និង តារាង ប្រាក់បៀវត្សរ៍ ថ្មីព្រមទាំងប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភ ដំឡើងប្រាក់បៀវត្សរ៍ដោយផ្អែកលើផលិតភាព កំណើនសេដ្ឋកិច្ច និង ស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ច ជាដើម

- រដ្ឋាភិបាលត្រូវថាតើវិធានការបន្តធ្វើជំរឿនរកមន្ត្រីរាជការខ្មោចនៅតាមក្រសួង និង ក្រសួងសាមី ដើម្បីពង្រឹងការគ្រប់គ្រងប្រសិទ្ធភាព និង គុណភាពការងារសាធារណៈ[81]។

[81] គេហទំព័រ VOA news អំពីរដ្ឋាភិបាលធ្វើជំរឿនរកមន្ត្រីរាជការខ្មោច ឆ្នាំ ២០១០

# សេចក្ដីសន្និដ្ឋាន

យោងតាមសិក្សាស្រាវជ្រាវទៅលើប្រធានបទ គោលការណ៍អនុវត្តចំពោះមន្ត្រីរាជការនៅកម្ពុជាក្នុងការគ្រប់គ្រងសេវាសាធារណៈកន្លងមក បានសង្កេតប្រទេសកម្ពុជាមានការគ្រប់គ្រងរដ្ឋតាំងពីមុនសម័យអាណានិគមបារាំងដោយពេលនោះពុំទាន់លេចចេញឲ្យឃើញច្បាស់ និងចាប់ពីសម័យអាណានិគមបារាំងមកការគ្រប់គ្រងបានសម្ដែងចេញមកឲ្យកាន់តែឃើញយ៉ាងច្បាស់លាស់នូវការគ្របប់គ្រងមួយដែលស្ថិតក្នុងសម័យទំនើប ចាប់ទាំងពីពេលនោះមកប្រទេសកម្ពុជាមានការបែងចែកអំណាចក្នុងការរៀបចំគ្រប់គ្រងដែនដី។ ការបង្កើតឲ្យមានទ្រឹស្ដីក្នុងការអនុវត្ត និងការវិវត្តក្នុងការគ្រប់គ្រងមន្ត្រី និងការផ្ដល់សេវាសាធារណៈត្រូវបានចាប់ផ្ដើមបង្កើតយកមកអនុវត្តន៍ ក្នុងគោលបំណងបំរើផលប្រយោជន៍សាធារណៈ ហើយតាមទ្រឹស្ដី និងការអនុវត្តមួយចំនួនក៏បន្តអនុវត្តន៍រហូតមកដល់បច្ចុប្បន្ន ។

គោលការណ៍របស់មន្ត្រីរាជការក្នុងផ្ដល់សេវាជូនរាស្ត្រប្រជាត្រូវបានបង្កើតឲ្យមានតាមបែបប្រពៃណី និងមានគោលការណ៍ថ្មីដែលត្រូវបង្កើត ដូចជាគោលការណ៍អទត្តពលជាដើម ដែលគោលការណ៍ទាំងនេះត្រូវបានឈរលើមូលដ្ឋានគតិយុត្តនៃច្បាប់ដូចជា ៖ ច្បាប់កំពូលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ផ្អែកតាមច្បាប់ស្ដីពីសហាលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលបង្កើតឡើងនៅឆ្នាំ ១៩៩៤ និងមានបទដ្ឋានគតិយុត្តមួយចំនួនទៀតដូចជា ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីប្រកាស សេចក្ដីសម្រេច និងមានឯកសារពាក់ព័ន្ធមួយចំនួន សៀវភៅ អត្ថបទច្បាប់ ក៏ដូចជាសេចក្ដីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួងសាមី ឬអន្តរក្រសួង ដែលឯកសារទាំងនោះសុទ្ធសឹងតែជាសម្រឹតសម្រាំងយកខ្លឹមសារដែលពាក់ព័ន្ធទៅនឹងគោលការណ៍របស់មន្ត្រីរាជការក្នុងការគ្រប់គ្រងសេវាសាធារណៈ។ ឯកសារគតិយុត្តដែលបានចង្អុលបង្ហាញដល់មន្ត្រីរាជការក្នុងការផ្ដល់សេវារបស់ និងអំពីមុខនាទីរបស់ខ្លួនក្នុងការអនុវត្ត ក្នុងគោលដៅធ្វើយ៉ាងណាឲ្យការផ្ដល់សេវារបស់ខ្លួនប្រកបដោយតម្លាភាព គុណភាពភាព ប្រសិទ្ធផល និងប្រសិទ្ធផលខ្ពស់។

ដោយមានការបែងចែកយ៉ាងច្បាស់លាស់ និងការចង្អុលបង្ហាញពីគោលការណ៍អនុវត្តសម្រាប់មន្ត្រីរាជការក្នុងការផ្ដល់សេវាឲ្យបានយល់កាន់នៅគោលបំណងនៃគោលការណ៍នីមួយៗចង់បាន ។ ជាពិសេសបន្ទាប់ពីបានសិក្សាយ៉ាងម៉ត់ចត់ទៅលើគោលការណ៍នីមួយៗ រួចធ្វើឲ្យមានការទទួលយកគំនិតថ្មីដែលមិនទាន់មាន ក្នុងការកែលម្អនូវសកម្មភាពខ្លះរបស់មន្ត្រីរាជការ ដែលមានភាពអសកម្ម និងជួយសម្រួលដល់ការផ្ដល់សេវាសាធារណៈ ។

ដោយសារតែមានគោលការណ៍សម្រាប់ឲ្យមន្ត្រីរាជការ ក្នុងការអនុវត្តនេះទើបបានផ្ដល់នូវកាលានុវត្តភាពក្នុងការចូលរួមសកម្មភាពនៃសេវាសាធារណៈពីសំណាក់មជ្ឈដ្ឋានខាងក្រៅពីអង្គ

ការរដ្ឋ។ ការបង្ហាញឲ្យឃើញនូវរាល់បញ្ហាដែលកើតមាន នៅចំនុចដែលអវិជ្ជមានដែលបណ្តាលមកពីកម្សោយព័ត៌មានរបស់ប្រជាពលរដ្ឋ ពីសំណាក់របស់មន្ត្រីជាអ្នកផ្តល់សេវា។ ការបង្កើតឲ្យមាននូវការត្រួតពិនិត្យ ការចូលរួមរបស់អ្នកប្រើប្រាស់សេវាគឺមានសារៈសំខាន់បំផុតរបស់សេវាសាធារណៈ និងបានយល់ដឹងអំពីការគ្រប់គ្រងមន្ត្រីរាជការរបស់ព្រះរាជាណាចក្រកម្ពុជាផងដែរ។ ការជ្រើសប្រព័ន្ធក្នុងត្រួតពិនិត្យការងាររបសមន្ត្រីរាជការ ថាការផ្តល់សេវាជូនប្រជារាស្ត្រមានប្រសិទ្ធភាពដែរឬ ទេ។

សរុបមកការសិក្សាទៅលើការអនុវត្តចំពោះមន្ត្រីរាជការនៅព្រះរាជាណាចក្រកម្ពុជាក្នុងការគ្រប់គ្រងសេវាសាធារណៈពិតជាបានផ្តល់នូវពុទ្ធិបន្ថែមគ្នុងការជួយដោយការអនុត្តមន្ត្រីរាជការក្នុងការផ្តល់សេវាសាធារណៈ និងជួយដល់ការរាំងស្ទះ ដោយឈរលើបែបបទនៃច្បាប់ដែលមានចែង និងឈលើគោលគំនិតនៃការចូលរួមក្នុងន័យជួយអភិវឌ្ឍន៍ ក្នុងវិស័យសេវាសាធារណៈឲ្យកាន់តែល្អប្រសើរឡើង និងឆ្ពោះទៅមុខជានិរន្ត ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ក្នុងការផ្តល់សេវាសាធារណៈ។

# អនុសាសន៍

ប្រសិនបើអង្គភាព ឬ ស្ថាប័នទាំងអស់ចង់បានឲ្យប្រសើរនូវការសម្រេចរបស់ខ្លួន ឬ ធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ គេត្រូវគិតអំពីទំហំនៃជីវភាពនយោបាយរបស់រដ្ឋបាល។

**ឧទាហរណ៍៖** ការធ្វើកំណែទម្រង់ទៅលើទិដ្ឋភាពសេដ្ឋកិច្ច ឬ ត្រូវធ្វើកំណែទម្រង់ទៅលើគោលការណ៍ ឬ គោលដៅដែលទាក់ទងទៅនឹងការធ្វើឲ្យប្រសើរឡើងនៃជីវភាពនៃសេវាសាធារណៈ ( គួរធ្វើទំនើបកម្មនៃរដ្ឋបាលសាធារណៈ លុបបំបាត់ចោលភាពជាថៅហ្វាយ ឬ មេ និងលុបបំបាត់អំពើពុករលួយ អនុគ្រោះនិយម )។

ម្យ៉ាងវិញទៀតរាល់កំណែទម្រង់ មានទិដ្ឋភាពនយោបាយពីព្រោះកំណើននៃការធ្វើឲ្យប្រសើរឡើងបញ្ជាក់ពីជម្រៅដែលមានតម្លៃដែលត្រូវផ្តល់ជាអាទិ៍ភាព។

កំណែទម្រង់រដ្ឋបាលបញ្ជាក់ផងដែរពីការផ្ទេរចំណេះដឹង ដែលហួសពីចំនេះដឹងដែលត្រូវធ្វើនៅក្នុងពេលនៃសកម្មភាពធម្មតា។ ចំណេះដឹងទាំងនេះចេញមកពីការសិក្សាផ្ទៃក្នុងធ្វើឡើងជាដំណាក់កាល ឬ ស្វ័យប្រវត្តិហើយភាគច្រើនមកពីមជ្ឈដ្ឋានខាងក្រៅ។

កំណែទម្រង់រដ្ឋបាលគឺជាស្នាដៃរបស់អ្នកឯកទេសដែលអនុវត្តនូវចំនេះដឹងផ្សេងៗ អ្នកអនុវត្តផ្ទាល់នូវចំនេះដឹងចំណេះដឹងផទាំងនេះ ទាំងក្នុងមុខងារសាធារណៈ ក៏ដូចជាអ្នកផ្តល់យោបល់ជាទូទៅប្រើគំរូ ឬ វិធីសាស្ត្រវិភាគ និងផ្អែកលើចំណេះដឹងរបស់ពួកគេជាផ្នែកនៃចំនូល ( អភិបាលកិច្ចល្អ ) ។ ដូច្នេះ ត្រូវមានការធ្វើកំណែទម្រង់រដ្ឋបាលដែលត្រូវធ្វើ៖

- មើលឡើងវិញនូវបញ្ញត្តិដែលទាក់ទងរដ្ឋបាលសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់របស់រដ្ឋបាលតាមទស្សនៈដែលទុកសេវាសាធារណៈនៅក្នុងបេះដូងនៃគំរូសេដ្ឋកិច្ច ការអភិវឌ្ឍដោយតាមទាររបស់ប្រទេសកម្ពុជា ដើម្បីក្តាប់ឲ្យបាននូវអ្វីដែលចង់បាន។
- ធ្វើឲ្យប្រសើរឡើងអំណាចរបស់រដ្ឋរបស់រដ្ឋ ដោយសម្របខ្លួនទៅនឹងការផ្លាស់ប្តូរនៅមូលដ្ឋាន
- ធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈហើយលើកម្ពស់ធនធានមនុស្សរបស់ខ្លួន ជាជម្រើសនៃយុទ្ធសាស្ត្រក្នុងករណីណាដែលការទម្រង់ទិសបែបនេះអាចធ្វើជាមូលដ្ឋាននៃគំរូអភិវឌ្ឍដែលអនុញ្ញាតឲ្យរដ្ឋបាលតាក់តែង និងអភិវឌ្ឍក្នុងវិស័យផ្សេងៗ នយោបាយប្រកប ដោយប្រសិទ្ធភាព និងប្រសិទ្ធផល

- ជម្រុញផលិតភាពរបស់រដ្ឋបាលឲ្យមានកម្រិតខ្ពស់ ហើយគិតធ្វើយ៉ាងណាឲ្យរដ្ឋបាលមានការផ្លាស់ប្តូរនៅកម្រិតជាតិ និងអាចប្រដូចទៅនឹងការអភិវឌ្ឍនៅថ្នាក់អន្តជាតិ
- បង្កើតឲ្យមានគោលការណ៍អភិបាលកិច្ចល្អទុកដូចជាលក្ខខណ្ឌដំបូងដែលត្រូវរៀបចំ និងគ្រប់គ្រងសេវាសាធារណៈ តាមដានមើលឧត្តមានុភាពនៃអ្នកមានសមត្ថភាព សម្មាហរណកម្ម តម្លាភាព និងសមភាពនៃភ័ព្វសំណាង សម្រាប់ប្រជាជនខ្មែរទាំងពីរភេទ
- បង្ខំឲ្យមន្ត្រីរាជការគោរពទាមទារ គុណភាពតម្លាភាព គណនេយ្យភាព។ ករណីកិច្ចជាលក្ខខណ្ឌមួយចាំបាច់
- ត្រូវអនុវត្តធម្មនុញ្ញភាពនៃសេវាសាធារណៈ
- ត្រូវធ្វើឪកាសកម្មរដ្ឋបាលអេឡិចត្រូនិច ( E-government ) ដោយបង្កើតសេវាពីចម្ងាយហើយការចូលទៅប្រើឲ្យបានឆាប់ ហើយទទួលព័ត៌មានរួមគ្នាពីក្រសួង
- ការអនុវត្តគោលការណ៍ថ្មីនៃអភិបាលកិច្ចសាធារណៈ និងសំណើឈានមុខស្តីពីកំណែទម្រង់ផ្អែកលើបន្ទាត់ដឹកនាំ សម្តៅសម្រេចឲ្យបានគោលដៅកំណត់ និងកាតព្វកិច្ចផ្តល់គុណផល និងលទ្ធភាព និងត្រូវឲ្យតម្លៃផងដែរ ពី តក្ក នៃតម្លៃសេវាសាធារណៈក្នុងនោះមានគោលការណ៍ផលប្រយោជន៍ទូទៅ សមាហរណកម្ម យុត្តិធម៌ និងសុគតភាពសង្គម

ដូច្នេះវាជាគំរូរដ្ឋបាលមួយដែលមានប្រសិទ្ធភាព ដោយមានសុខដុមរូបនីយកម្មដោយមានគំរូអភិវឌ្ឍន៍ដែលចង់បាន ហើយឆ្លើយតបលទ្ធិបញ្ហាបច្ចុប្បន្ន និងអនាគត។

| ល/រ | **ចំណងជើង និងឯកសារគតិយុត្ត** | ទំព័រ | ផ្សេងៗ |
|---|---|---|---|
| ១ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា | | |
| ២ | ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឆ្នាំ ១៩៩៤ | ៦-៧ | |
| ៣ | ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រះរាជក្រម នស/រកម/០៨១៥/០១០ ចុះថ្ងៃទី ១២ សីហា ឆ្នាំ ២០១៥ | ៩៥ | |
| ៤ | ព្រះរាជក្រមលេខ នស/រកម/ ០២០១/០៣ ច្បាប់ស្តីពី អគ្គីសនីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ | ៩៧ | |
| ៥ | អនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៦២ អនក្រ.បក ( មាត្រា១ , មាត្រា ២ ) | ១៦ | |
| ៦ | អនុក្រឹត្យ លេខ ១៨ អនប្រ.កប ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីអំពី ការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់កក្រោមជាតិ ( មាត្រា១ , មាត្រា២ , មាត្រា២៩ ) | ២៤-២៥ | |
| ៧ | យោងតាមអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីក្រសួងមុខងារសោធារណៈមានមុខងារ និងភារកិច្ច | ១៦ | |
| ៨ | អនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មាត្រា៥ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៨ | ៥០-៥១ | |
| ៩ | សេចក្តីប្រកាសរបស់ក្រសួងសាធារណៈ និងដឹកជញ្ជូន លេខ ០៤៦ សក ធ្វើថ្ងៃ២៧ ខែ មករា ឆ្នាំ ២០១៧ | ១៥ | |
| ១០ | សេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដោយយោងតាមប្រកាសអន្តរក្រសួង លេខ ១៤៤១៤ ប្រ.ក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ | ១៦ | |
| ១១ | សេចក្តីប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ១៤៤១៤ ប្រក ( ប្រការ ២ ) | ១៦ | |
| ១២ | សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ១៣ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការរៀបចំទីតាំងគម្រោងសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១៣១៩ សជណ,ជក | ២១-២២ | |

| | | | |
|---|---|---|---|
| ១៣ | សេចក្តីប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសលេខ ១៨៣៨២ ប្រក ( ប្រការ ៤ , ប្រការ ៥ ) | | |
| ១៤ | ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៣៨៧១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧ | ២៥-២៦ | |
| ១៥ | តាមបញ្ញត្តិមុខងារសាធារណៈរបស់ប្រទេសថៃ ឆ្នាំ ២០០៨ | ៦ | |
| ១៦ | សេចក្តីណែនាំ លេខ ០២ សណន ស្តីពីការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៨ | ៥១-៥២ | |

## ឯកសារជាសៀវភៅ

| ល/រ | ឯកសារយោង ជាសៀវភៅ | ទំព័រ | ផ្សេងៗ |
|---|---|---|---|
| ១ | វចនានុក្រមសម្តេចសង្ឃ ជួន ណាត | | |
| ២ | តាមសន្ទានុក្រមបារាំង-ខ្មែរ នៃវាគស័ព្ទគតិយុត្ត | | |
| ៣ | Oxford Dictionary | | |
| ៤ | សៀវភៅនីតិរដ្ឋបាលទូទៅ សាស្ត្រាចារ្យ ឌឿក ពិដោរ ឆ្នាំ ២០០៩ | | |
| ៥ | សៀវភៅនីតិសាធារណៈ សាស្ត្រាចារ្យ ឌឿក ពិដោរ ឆ្នាំ ២០១៨ | | |
| ៦ | សៀវភៅទ្រឹស្តីរដ្ឋបាល សាស្ត្រាចារ្យ ឌឿក ពិដោរ ឆ្នាំ ២០១៨ | | |
| ៧ | សៀវភៅនីតិរដ្ឋបាលសាធារណៈ សាស្ត្រាចារ្យ គង់ ប៊ុនធី ឆ្នាំ២០១៥ | | |
| ៨ | សៀវភៅប្រព័ន្ធរដ្ឋបាលប្រទេសកម្ពុជា របស់សាស្ត្រាចារ្យ កៅ មុយ ថង ឆ្នាំ ២០០៨ | | |
| ៨ | សៀវភៅ " វិទ្យាសាស្ត្ររដ្ឋបាល " របស់លោក J.Chevallier ឆ្នាំ ២០០២ | | |
| ១០ | សៀវភៅ រដ្ឋបាលសម័យទំនើប សាស្ត្រចារ្យ កៅ មុយ ថង ឆ្នាំ២០០៧ | | |
| ១១ | ដកស្រង់ចេញពី ចំណេះដឹងទូទៅ ស្តីពីនិយមន័យវិសហមជ្ឈការ | | |

| | | | |
|---|---|---|---|
| ១២ | សុន្ទរកថារបស់ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពី "យុទ្ធសាស្ត្រចតុកោណ "ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទីមួយ នីតិកាលទី៣ នៃរដ្ឋសភានៅទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ | | |
| ១៣ | សៀវភៅ " វិទ្យាសាស្ត្ររដ្ឋបាល " របស់លោក J.Chevallier ឆ្នាំ ២០០២ | | |

## ឯកសារផ្សេងៗ

| ល/រ | ឯកសារយោង ផ្សេងៗ | ទំព័រ | ផ្សេងៗ |
|---|---|---|---|
| ១ | នាយកដ្ឋានរដ្ឋបាលសាធារណៈ និងគ្រប់គ្រងការអភិវឌ្ឍ ( DPADM ) ឆ្នាំ ( ២០០៦ ) | | |
| ២ | ឯកឧត្តម ប្រាក់ សុខ ក្នុងបទអត្ថាធិប្បាយនៅសាលាភូមិន្ទរដ្ឋបាល ឆ្នាំ ១៩៩៥ ក្នុងខណៈដែលជាឯកឧត្តមរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | | |
| ៣ | សាលារាជធានីភ្នំពេញ | | |
| ៤ | ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១៣១៩ សជណ.ជក | | |
| ៥ | សេចក្តីប្រកាសពត៌មានរបស់រាជរដ្ឋាភិបាល | | |
| ៦ | បណ្ណាល័យ គ.ជ.អ.ប ចុះថ្ងៃពុធ ទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ | | |
| ៧ | អង្គការតម្លាភាពកម្ពុជា | | |
| ៨ | អង្គការទិន្នន័យអំពីការអភិវឌ្ឍ(Open Development Cambodia) ថ្ងៃទី៨ ធ្នូ ២០១៧ អំពីវិមជ្ឈការនិងវិសហមជ្ឈការ | | |
| ៩ | គេហទំព័រ Ank News សារព័ត៌មានអនាគតថ្មី | | |
| ១០ | SHARES អំពីប្រព័ន្ធមជ្ឈការ ប្រព័ន្ធវិមជ្ឈការ វិសហមជ្ឈការ | | |
| ១១ | ចង្កោមសេវាសាធារណៈ របស់រាជរដ្ឋាភិបាល ឆ្នាំ ២០១០ | | |

| | | | |
|---|---|---|---|
| ១២ | សាលាត្រាជូ វាក្យស័ព្ទ ការគ្រប់គ្រងគុណផល ដកស្រង់ចេញពី ឧបសម្ព័ន្ធ៣នៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ | | |
| ១៣ | គេហទំព័រ VOA news អំពីរដ្ឋាភិបាលធ្វើជំរឿនរកមន្ត្រីរាជការខ្មោច ឆ្នាំ ២០១០ | | |
| ១៤ | រាជរដ្ឋាភិបាលកម្ពុជាគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានទទួលពីគណៈរដ្ឋមន្ត្រីក្នុងសម័យអង្គប្រជុំពេញអង្គ ស្តីពីកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នាថ្ងៃទី ៩ ខែមករា ឆ្នាំ២០១៥ | | |

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត **គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ** ហៅកាត់ "**គ.ក.រ**" ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំវិស័យកែទម្រង់រដ្ឋបាសាធារណៈ។

## ជំពូកទី២
## បេសកកម្មនិងសមាសភាព

**មាត្រា២ ._**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានបេសកកម្មផ្តួចផ្តើម រៀបចំ ដាក់ឲ្យដំណើការ និង តាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការសកម្មភាពនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ស្របតាមគោលនយោបាយ និង ការតម្រង់ទិសរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ ._**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសារជាណៈ មានភារកិច្ចដូចខាងក្រោម៖

- ផ្តួចផ្តើម និងលើកសំណើជូនរាជរដ្ឋាភិបាលនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ធ្វើឲ្យសម្រេចជោគជ័យនូវគោលដៅនៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ មានជាអាទិ៍ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ការកែទម្រង់បៀវត្សការ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ និងការពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ ដើម្បីគាំទ្រដល់ការបង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច និង កំណើនសេដ្ឋកិច្ចជាតិ
- លើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយ និងដាក់ចេញវិធានការចាំបាច់ សម្រាប់គាំទ្រដល់យន្តការនៃការកែទម្រង់រដ្ឋបាលសាធារណៈឲ្យប្រព្រឹត្តទៅប្រកបដោយថាមពល មានជំនឿទុកចិត្ត និងមានប្រសិទ្ធភាពខ្ពស់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- លើកសំណើជូនរាជរដ្ឋាភិបាលក្នុងការចេញសេចក្តីសម្រេច និង សេចក្តីណែនាំចាំបាច់ដល់ក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- លើកសំណើជូនរាជរដ្ឋាភិបាលក្នុងការដាក់ចេញនូវវិធានការ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការប្រើប្រាស់ធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- អនុវត្តដោយផ្ទាល់ និង សម្របសម្រួលជំរុញដល់ក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងការអនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ឲ្យដំណើរការគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួលបណ្តាសកម្មភាពរបស់ក្រសួងស្ថាប័ននានា ព្រមទាំងផ្តល់ជំនួយបច្ចេកទេសដែលទាក់ទងទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- សហការជាមួយស្ថាប័នកែទម្រង់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល សំដៅជំរុញល្បឿនកំណែទម្រង់អភិបាលកិច្ចក្នុងវិស័យសារជាណៈ

- តាមដានត្រួតពិនិត្យ និង វាយតម្លៃលើការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នៅតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃវឌ្ឍនភាពក្នុងការអនុវត្ត កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ជូនរាជរដ្ឋាភិបាល
- សហការ និង សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ក្នុងការស្វែងរកជំនួយបច្ចេកទេស និង ហិរញ្ញប្បទាន ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- ដឹកនាំ គ្រប់គ្រង និង ជំរុញការងារផ្សព្វផ្សាយព័ត៌មានស្តីពីគោលដៅ សកម្មភាព និងសមិទ្ធផលនៃការងារកែទម្រង់រដ្ឋបាលសាធារណៈ
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**មាត្រា៤ .-**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ជាប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | មួយរូប អនុប្រធាន |
| ៣. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | មួយរូប សមាជិក |
| ៤. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | មួយរូប សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | មួយរូប សមាជិក |
| ៦. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | មួយរូប សមាជិក |
| ៧. រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | មួយរូប សមាជិក |
| ៨. រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | មួយរូប សមាជិក |
| ៩. រដ្ឋលេខាធិការក្រសួងសុខាភិបាល | មួយរូប សមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | មួយរូប សមាជិក |
| ១១. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មួយរូប សមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងកិច្ចការនារី | មួយរូប សមាជិក |
| ១៣. រដ្ឋលេខាធិការក្រសួងផែនការ | មួយរូប សមាជិក |
| ១៤. រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | មួយរូប សមាជិក |
| ១៥. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | មួយរូប សមាជិក |
| ១៦. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | មួយរូប សមាជិក |
| ១៧. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | មួយរូប សមាជិក |
| ១៨. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | មួយរូប សមាជិក |

# ឧបសម្ព័ន្ធ ២

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
លេខ: ៥០៤៧ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ.ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១០

# ប្រកាសអន្តរក្រសួង
# មហាផ្ទៃ - សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# ស្តីពី
# ការកំណត់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញ អនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តី[illegible]ទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជារាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី[illegible] ខែវិច្ឆិកា ឆ្នាំ ២០០៦ [illegible]គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងលិខិតលេខ ១៦៨០ សជណ ចុះថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០[illegible] របស់ទីស្តីការគណៈរដ្ឋមន្ត្រី

# សម្រេច

ប្រការ ១ : ត្រូវបានកំណត់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលផ្តល់ជូនប្រជាពលរដ្ឋ ក្នុងមួយសន្លឹក តម្លៃ ១០.០០០រៀល (ដប់ពាន់រៀល) ។

ប្រការ២ : ប្រាក់ដែលប្រមូលបានពីអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរត្រូវដក ២.០០០រៀល( ពីពាន់រៀល) ក្នុងមួយសន្លឹក សម្រាប់ :

- ឧបត្ថម្ភដល់កងកម្លាំងប្រតិបត្តិការ ១.៥០០រៀល ( មួយពាន់ប្រាំរយរៀល)
- សេវាថែទាំឧបករណ៍ សំភារៈបច្ចេកទេស ៥០០រៀល ( ប្រាំរយរៀល) ។

ប្រការ ៣ : នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃដើម្បីចុះណែនាំអនុវត្តការប្រមូលអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ប្រការ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៥ : អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធមានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

...:
...:រដ្ឋមន្ត្រី
... សម្ដេចអគ្គមហាសេនាបតី
... ហ៊ុន សែន នាយករដ្ឋមន្ត្រី
...ជូនជ្រាប
... ៥
...អនុវត្ត
- កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៣

# ឧបសម្ព័ន្ធ ៤

# ឧបសម្ព័ន្ធ

# អនុក្រឹត្យ និង ច្បាប់នានា

# ជំពូកទី២
# អំពីមន្ត្រីអត្រានុកូលដ្ឋាន

## មាត្រា ៨ថ្មី.-

ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលខុសត្រូវការងារអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬ សង្កាត់ ដែលខ្លួនគ្រប់គ្រង ។

មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ។

## មាត្រា ៩.-

មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច ៖

- ទទួលពិនិត្យ កត់ត្រា រឿងហេតុសំខាន់ៗទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ មរណភាពនៃជនទាំងឡាយ ចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន
- ចេញសេចក្តីចម្លង ឬ សម្រង់នៃអត្រានុកូលដ្ឋាន ដែលមានក្នុងឆ្នាំមិនទាន់ដាច់
- កែតម្រូវអក្ខរាវិរុទ្ធ លើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ តាមលក្ខខណ្ឌមាត្រា ១៣ នៃអនុក្រឹត្យនេះ
- អនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍ និង ធ្វើបុណ្យបូជា ឬ បញ្ចុះសព
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋាន ដែលខ្លួនបានអនុវត្ត
- ចុះហត្ថលេខា និង បោះត្រា លើសំបុត្រអត្រានុកូលដ្ឋាន
- កែតម្រូវ ឬបដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទបញ្ញត្តិនៃច្បាប់
- ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទអោយបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និង ការគ្រប់គ្រង
- បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់ទៅ យកទៅតម្កល់ទុកនៅសាលាស្រុក ឬ ខណ្ឌផ្ទាល់ ០១ច្បាប់ និងនៅតុលាការខេត្ត ឬ ក្រុងសាមី ០១ច្បាប់
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬ សង្កាត់ អោយបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួន ចំពោះអត្រានុកូលដ្ឋាន និង បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងអំពីអត្រានុកូលដ្ឋាន
- ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភា ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ ឬ សង្កាត់ ជារៀងរាល់ខែ និង រាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាស្រុក ឬ សាលាខណ្ឌសាមី
- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

## មាត្រា ១០.-

រាល់ការអនុវត្តការងារអត្រានុកូលដ្ឋាន នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានទំរង់បែបបទ និង សំបុត្រអត្រានុកូលដ្ឋាន ដូចការងារអត្រានុកូលដ្ឋាន

ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ដោយប្រកាសរួម ។

**មាត្រា ១១.-**

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯកបរទេស ត្រូវមានមន្ត្រី ០១រូប នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល អោយទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដោយជូនព័ត៌មានទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះរវាងក្រសួងមហាផ្ទៃ និង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

## ជំពូកទី៣

## អំពីសៀវភៅអត្រានុកូលដ្ឋាន

**មាត្រា ១២.-**

ក្នុងឃុំ ឬ សង្កាត់នីមួយៗ ត្រូវមានសៀវភៅអត្រានុកូលដ្ឋាន សំរាប់កត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និង បញ្ជាក់មរណភាព ។

សៀវភៅនេះត្រូវធ្វើជា០២ច្បាប់ដូចគ្នា តាមប្រភេទនីមួយៗ តាមគំរូដែលកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

សៀវភៅនេះត្រូវចុះចំនួនសន្លឹក និង ចុះលេខរៀងសន្លឹក ពីសន្លឹកទី១ ដល់សន្លឹកចុងក្រោយ ។ សន្លឹកទី១ និង សន្លឹកចុងក្រោយត្រូវសរសេរជាអក្សរ និង ត្រូវចុះហត្ថលេខាពេញដោយអភិបាលស្រុក ឬអភិបាលខណ្ឌ ។ សន្លឹកទី២ និង សន្លឹកដទៃទៀតអាចចុះហត្ថលេខាសង្ខេប និង បោះត្រារបស់អភិបាលស្រុក ឬ ខណ្ឌគ្រប់សន្លឹក ។

**មាត្រា ១៣.-**

សៀវភៅអត្រានុកូលដ្ឋានទាំងអស់ មិនត្រូវអោយមាន **កោស ឆូត លុប សរសេរជ្រៀតថែម**ឡើយ ។ បើមាន កោស ឆូត លុប ត្រូវទុកពាក្យទាំងនោះអោយនៅមើលបាន ហើយសរសេរទឹកខ្មៅពណ៌ក្រហមលើរឹមទំព័រខាងឆ្វេងថា យល់ព្រមលុបប៉ុន្មានពាក្យ និង យល់ព្រមថែមប៉ុន្មានពាក្យ ទើបមន្ត្រីអត្រានុកូលដ្ឋាន អ្នករាយការណ៍ និង ឬ សាក្សី និង ឬ សាមីខ្លួន ចុះហត្ថលេខា ឬ ផ្តិតមេដៃស្តាំទាំងអស់គ្នា ។

ចំពោះសន្លឹកណា ដែលសរសេរខុស ត្រូវរក្សាទុកជាឯកសារ មិនអោយហែកចោលឡើយ ។

**មាត្រា ១៤.-**

ស្បៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកអោយប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ មករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី ៣១ ខែ ធ្នូ រៀងរាល់ឆ្នាំ ។

នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបញ្ជូនសៀវភៅតាមប្រភេទនីមួយៗ ០១ច្បាប់ ទៅសាលាស្រុក ឬខណ្ឌសាមី ដើម្បីត្រួតពិនិត្យ និង តម្កល់ទុកនៅទីនោះ និង បញ្ជូន ០១ច្បាប់ទៀតដូចគ្នា ទៅតម្កល់ទុកនៅតុលាការខេត្ត ឬ ក្រុងសាមី ដើម្បីមុខការតាមផ្លូវច្បាប់ ។

សៀវភៅអត្រានុកូលដ្ឋាន ដែលបានប្រើប្រាស់នៅស្ថានទូត ស្ថានកុងស៊ុល ឬស្ថានអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នៅខែមករាឆ្នាំបន្ទាប់ មកតម្កល់ទុក ០១ច្បាប់នៅក្រសួងមហាផ្ទៃ និង ០១ច្បាប់ទៀតមកតម្កល់ទុកនៅក្រសួងយុត្តិធម៌ ។

**មាត្រា ១៥.-**

មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំទុកដាក់ ថែរក្សាសៀវភៅអត្រានុកូលដ្ឋាន និងសំណុំឯកសារដែលពាក់ព័ន្ធការងារអត្រានុកូលដ្ឋានអោយបានល្អ និង រក្សាការសម្ងាត់របស់បុគ្គលម្នាក់ៗ ។

ចំពោះសាលាឃុំ ឬសង្កាត់ណាដែលមិនធានាសុវត្ថិភាព មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់នេះ ត្រូវផ្ញើសៀវភៅអត្រានុកូលដ្ឋានទៅរក្សាទុកនៅសាលាស្រុក ឬខណ្ឌសាមី ។ ពេលធ្វើអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាននោះ ត្រូវទៅធ្វើនៅសាលាស្រុក ឬខណ្ឌ ទៅតាមបែបបទដូចបានអនុវត្តនៅសាលាឃុំ ឬ សង្កាត់ ។

**មាត្រា ១៦.-**

ក្រសួងមហាផ្ទៃ មានភារកិច្ចរៀបចំសៀវភៅអត្រានុកូលដ្ឋាន អោយបានឯកភាពទូទាំងប្រទេស និងបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន អំពីរបៀបកត់ត្រាចូលក្នុងសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ និងធានាផ្គត់ផ្គង់សៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានអោយគ្រប់គ្រាន់ និងទាន់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន ។

## ជំពូកទី៤

## អំពីសំបុត្រកំណើត

**មាត្រា ១៧.-**

បើមានទារកកើត ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ ឬសង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះ មិនអោយហួស៣០ថ្ងៃ ដោយបញ្ជាក់អោយបានច្បាស់ថា ឪពុក និង ម្តាយ នៃទារកនោះមានខាន់ស្លា ឬឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍របស់ឪពុក និង ម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬ អ្នកនៅជិតខាងដែលបានឃើញ និង ដឹងឮផ្ទាល់ពីទារកនោះកើតអោយទៅចុះសៀវភៅកំណើត អោយបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និង ម្តាយទារកនោះជាប់ទៅជាមួយផង ។

**មាត្រា ១៨.-**

នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬ អាចយកឈ្មោះជីតាខាងឪពុក ឬ អាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។

ឪពុក ម្ដាយ ឬ អាណាព្យាបាល ជាអ្នកដាក់នាមខ្លួនអោយទារក ។

**មាត្រា ១៩.-**

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់អោយមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬសង្កាត់នៃទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និង ចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះដាក់ឱ្យ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំកំណើតទារកដែលរើសបាននោះ ដោយស្មាន និង ឈ្មោះឪពុក ម្ដាយដាក់ថាមិនស្គាល់ ។

បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារក ដែលរើសបាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយ នូវសំបុត្រកំណើតរបស់ទារកនោះ និង កំណត់ហេតុស្ដីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ។

**មាត្រា ២០.-**

ចំពោះទារក ឬកុមារដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយដែលពុំទាន់មានសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះ ត្រូវធ្វើ សេចក្ដីរាយការណ៍ និង នាំទារក ឬ កុមារនោះទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌលនោះ តាំងនៅ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានផ្ដល់សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតឱ្យ ។

**មាត្រា ២១.-**

ការសុំទារក ឬ កុមារពី មជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំទារក ឬ កូនពីឪពុក ម្ដាយ ធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តទៅតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។

កិច្ចសន្យាសុំកូនខាងលើនេះ ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ២២.-**

បើមានទណ្ឌិតណាម្នាក់សំរាលកូន ទីកន្លែងកំណើតនៃទារកនោះ ត្រូវយកតាមលំនៅដ្ឋានរបស់ម្ដាយ ឬឪពុក ។

**មាត្រា ២៣.-**

ទារកកើតពីឪពុក ម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ ។ នៅពេលធ្វើសំបុត្រកំណើត បើឪពុក ម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះ បានឆ្លើយទទួលស្គាល់ដោយជាក់លាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុក ឪពុក ម្តាយនោះថា ជាឪពុក ម្តាយរបស់កូននោះ ។

ករណីមានតែឪពុក ឬ មានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ ។

ក្រោយពេលឪពុក ឬ ម្តាយបានប្តឹងចុះក្នុងសៀវភៅកំណើត ឪពុក ឬ ម្តាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬ ម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

កូនឥតខាន់ស្លាដែលឪពុក ម្តាយបានទទួលស្គាល់ នឹងទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នា នឹងពេលចុះអាពាហ៍ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

**មាត្រា ២៤.-**

ក្រោយពេលចុះសៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់អោយអ្នករាយការណ៍ នូវសំបុត្រកំណើតច្បាប់ដើម ០១សន្លឹកទុកជាសម្គាល់ និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២៥ថ្មី.-**

បើមានទារកកើតហើយ ទុកអោយហួសរយៈពេល ៣០ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល ត្រូវប្តឹងសុំសំបុត្រកំណើតនេះពីមេឃុំ ចៅសង្កាត់សាមី ដោយបង់ប្រាក់ថ្លៃសំបុត្រកំណើតដល់អាជ្ញាធរឃុំ សង្កាត់ សាមី ចំនួន ១.០០០ (មួយពាន់) រៀល សំរាប់ប្រជាពលរដ្ឋមានទីលំនៅនៅក្នុងខេត្ត រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និង ៤.០០០ (បួនពាន់) រៀល សំរាប់ប្រជាពលរដ្ឋ ដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំបន្ថែមអំពីបែបបទ និង នីតិវិធីនៃការសុំ និង ការចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងករណីខាងលើនេះ ។

**មាត្រា ២៦.-**

ទារកកើតពីម្តាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬ ពីឪពុកជាពលរដ្ឋខ្មែរ ម្តាយជាជនបរទេស ឬ ពីឪពុកជាជនបរទេស ម្តាយជាពលរដ្ឋខ្មែរ ឪពុក ម្តាយនៃទារកនោះ អាចសុំចុះសៀវភៅកំណើតនៅឯប្រទេសនោះ តាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅ

**មាត្រា ៤១.-**

បើមានពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ ។ ពេលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាពដែលធ្វើនៅបរទេសនោះ ទៅចុះសៀវភៅនៅឃុំ ឬ សង្កាត់ ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់លាប់មុនចេញទៅបរទេស ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពថតចម្លងជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់អោយសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់ ។

បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយត្រឡប់មកប្រទេសកម្ពុជាវិញ អាចយកសំបុត្រមរណភាពនោះមកប្រើប្រាស់ជាផ្លូវការបាន ។

**មាត្រា ៤២.-**

ជនអន្តោប្រវេសន៍ និងជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬ អ្នកទទួលខុសត្រូវអាចទៅចុះសៀវភៅមរណភាពនៅសាលាឃុំ ឬសង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់ មុនពេលខ្លួនស្លាប់ ឬអាចទៅចុះសៀវភៅមរណភាពនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ។

បើចុះសៀវភៅមរណភាពនៅឃុំ ឬ សង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង ។

## ជំពូកទី៧
## អំពីសំបុត្របញ្ជាក់កំណើត

**មាត្រា ៤៣ថ្មី.-**

ពលរដ្ឋខ្មែរដែលកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំណើតប្រើប្រាស់ អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតបានតាមគំរូណែនាំថ្មី នៅសាលាឃុំ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដ នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលប្រវត្តិរូប ឬ ទទួលសោធននិវត្តន៍ត្រូវយកឯកសារប្រវត្តិរូប ឬ សោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីក្រសួង ស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតមិនត្រូវឱ្យខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារប្រវត្តិរូប ឬសោធននិវត្តន៍ជាផ្លូវការឡើយ ។

**មាត្រា ៤៤.-**

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់កំណើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់អោយសាមីខ្លួន ឬ ក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

## ជំពូកទី៨

## អំពីសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

**មាត្រា ៤៥ថ្មី.-**

ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ នៅមុនពេលដែលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយមិនទាន់បានចុះសៀវភៅអាពាហ៍ពិពាហ៍ សាមីខ្លួនទាំងពីររូបអាចសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជានីតិជន និង តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

**មាត្រា ៤៦.-**

ពេលមានសាមីខ្លួនប្តី និង ប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់អោយសាមីខ្លួនប្តី ប្រពន្ធ នូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬ សង្កាត់ ។

## ជំពូកទី៩

## អំពីសំបុត្របញ្ជាក់មរណភាព

**មាត្រា ៤៧ថ្មី.-**

ពលរដ្ឋខ្មែរដែលស្លាប់មុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាពបានតាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្ន ដោយនាំសាក្សីចំនួន ០២រូប ជានីតិជន ហើយមានទីលំនៅពិតប្រាកដ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៨.-**

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់មរណភាព រួចត្រូវប្រគល់ឱ្យអ្នកមកសុំនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំ ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ។

**មាត្រា ៥៣.-**

ពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬ សម្រង់អត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬ សុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬ កុងស៊ុល និង បោះត្រាផង ។

ការសុំចម្លង ឬ សម្រង់អត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវសុំចម្លង ឬ សុំស្រង់នៅក្រសួងមហាផ្ទៃ ឬ នៅក្រសួងយុត្តិធម៌ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ ។

## ជំពូកទី១១

## អំពីការទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីការងារអត្រានុកូលដ្ឋាន

**មាត្រា ៥៤.-**

សាមីខ្លួន និង ឬអ្នករាយការណ៍ និង ឬសាក្សី ត្រូវសម្តែងនូវការស្មោះត្រង់ ចំពោះការបញ្ជាក់អះអាងរបស់ខ្លួនអំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬ ឃើញផ្ទាល់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្តីពីអត្រានុកូលដ្ឋានតាមប្រភេទ ។

**មាត្រា ៥៥.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមានមន្ត្រីអត្រានុកូលដ្ឋានណាម្នាក់មានការឃុបឃិត ឬ ក្លែងបន្លំដោយចេតនា ក្នុងការធ្វើសំបុត្រអត្រានុកូលដ្ឋាន ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកមកវិញ និង ប្តឹងទៅតុលាការដើម្បីបដិសេធ និង សុំផ្តន្ទាទោសតាមច្បាប់ ។

## ជំពូកទី១២

## អំពីថវិកាអត្រានុកូលដ្ឋាន

**មាត្រា ៥៦.-**

ការបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និង ការបណ្តុះបណ្តាល អំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេស ត្រូវស្ថិតក្នុងបន្ទុកថវិការដ្ឋ ។

**មាត្រា ៥៧.-**

ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសុំបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និង ការបណ្តុះបណ្តាលការងារអត្រានុកូលដ្ឋាន ។

## មាត្រា ៥៨.-

ការសុំចុះសំបុត្រអត្រានុកូលដ្ឋាន កំណើត និង មរណភាព អ្នកមកសុំមិនតម្រូវឱ្យបង់ថ្លៃអ្វីឡើយ ។

ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និងការចុះសំបុត្រអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ ការសុំបញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និង បញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់ ។

រាល់ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋាន អ្នកមកសុំត្រូវបង់ថ្លៃក្រដាស និង ថ្លៃបិទតែមប្រើ ដើម្បីជាប្រយោជន៍សំរាប់ឃុំ ឬ សង្កាត់ និង ចំណូលថវិការដ្ឋ ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និង ថ្លៃតែមប្រើ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

# ជំពូកទី១៣

# អន្តរបញ្ញត្តិ

## មាត្រា ៥៩ថ្មី.-

**ក**-ការសុំបញ្ជាក់អត្រានុកូលដ្ឋានមាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាព ត្រូវទៅសុំសំបុត្រអត្រានុកូលដ្ឋាន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៥ថ្មី និង មាត្រា ៤០ថ្មី នៃអនុក្រឹត្យនេះ ។ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតអោយប្តឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

សំរាប់ឆ្នាំ ២០០២ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ត្រូវបានអនុញ្ញាតបើកប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ សីហា ហើយត្រូវបញ្ឈប់បញ្ជីត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ។

ចាប់ពីឆ្នាំ ២០០៣ តទៅ ត្រូវអនុវត្តបទបញ្ញត្តិ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា១៤ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ។

**ខ**-ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ប្រជាពលរដ្ឋដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋានរួមមាន បញ្ជាក់កំណើត និង បញ្ជាក់មរណភាព នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានខាងលើនេះនូវច្បាប់ដើម០១ សន្លឹក ដោយឥតគិតថ្លៃ ។

ចំពោះទារកដែលបានកើតក្នុងចន្លោះពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ហើយដែលមិនទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើត នៅពេលដែលឪពុក ឬ ម្តាយ ឬ អាណាព្យាបាល មកសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត អោយទាន់ពេលក្នុងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥នោះ នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម ០១សន្លឹក ដោយឥតគិតថ្លៃ ។

គ-ដើម្បីបង្កលក្ខណសម្បត្តិងាយស្រួលជូនប្រជាពលរដ្ឋ ក្នុងការចុះសៀវភៅអត្រានុកូលដ្ឋាន ឃុំ សង្កាត់ អាចចាត់ឱ្យមានការចុះសៀវភៅអត្រានុកូលដ្ឋានចល័តក្នុងឃុំ សង្កាត់របស់ខ្លួនតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦០.-**

ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជនណាម្នាក់ទៀត ។

**មាត្រា ៦១.-**

រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ចាស់ ដែលមានស្រាប់ពីសង្គមមុនៗ និង អត្រានុកូលដ្ឋានក្រោយឆ្នាំ ១៩៧៩ ហើយរក្សាទុករហូតដល់បច្ចុប្បន្ន សាមីខ្លួនត្រូវយកមកបង្ហាញមន្ត្រីអត្រានុកូលដ្ឋានបច្ចុប្បន្ន ដើម្បីចុះក្នុងសៀវភៅអត្រានុកូលដ្ឋានតាមគំរូថ្មី សម្រាប់ប្រើប្រាស់ទៅថ្ងៃក្រោយ ។

**មាត្រា ៦២.-**

ក្នុងករណីដែលពិនិត្យឃើញសំបុត្រអត្រានុកូលដ្ឋានចាស់ពីមុនណាមួយ ដែលមានលក្ខណៈពុំត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រមូលសំបុត្រអត្រានុកូលដ្ឋាននោះមកវិញ រួចណែនាំអោយសាមីជនបំពេញបែបបទសុំអត្រានុកូលដ្ឋានថ្មី ។

**មាត្រា ៦៣.-**

ហាមមនុស្សម្នាក់ចុះសៀវភៅអត្រានុកូលដ្ឋានក្នុងប្រភេទនីមួយៗ លើសពី ០១ដង និង នៅច្រើនកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី១៤

## អំពីទោសបញ្ញត្តិ

**មាត្រា ៦៤.-**

ជនណារាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬ យកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬរាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពី ០១ដង នៅទីកន្លែងដដែល ឬទីកន្លែងផ្សេង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រើប្រាស់អត្រានុកូលដ្ឋានក្លែង ត្រូវពិន័យ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៦៥.-**

មន្ត្រីអត្រានុកូលដ្ឋានណា សមគំនិត ឃុតឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានអោយប្រជាពលរដ្ឋដែលមកសុំ ឬ បានទារប្រាក់លើសច្បាប់កំណត់ពីប្រជាពលរដ្ឋសំរាប់ការងារអត្រានុកូលដ្ឋាន ត្រូវពិន័យជាប្រាក់ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។